អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2013, 13:15
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៥នាទី**

**សវនាការលើកទី២១០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោក រ៉ូជើ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក រេយ៍ន័រ ឃីត *(Mr. Raynor Keith)*

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត *(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោកស្រី បេនី យេ *(Ms.Beini YE)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

កញ្ញា អេលេន័រ ហ្វែណាន់ដេស *(Ms. Eleonor FERNANDEZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្ទីវ ហេដឌ័រ** (TCE-33)


សួរបន្តដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី....................................ទំព័រ ៣

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី ....................................ទំព័រ ៤៩

សួរដោយលោក ឡៅ ជុនធី ផ្ដើមពី....................................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឆ័រ ដែលនឹងសួរដេញដោលដោយភាគីពាក់ព័ន្ធនៃរឿងក្តីដែលនឹងអាចសួរបញ្ចប់ដោយតំណាងសហព្រះរាជអាជ្ញា។ ជាបន្តបន្ទាប់ គឺមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ក្រឡាបញ្ជីសវនាការលោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមអរគុណលោកប្រធាន។ នៅថ្ងៃក្នុងសវនាការនាថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយសារមូលដ្ឋានសុខភាព។

សាក្សីលោក ស៊ីវ ហេងឆ័រ ដែលត្រូវផ្តល់សក្ខីកម្មនៅបន្តនៅថ្ងៃនេះ មានវត្តមាននៅចំពោះមុខនេះស្រាប់។ សូមចប់សេចក្តីរាយការណ៍លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:០៦:៤៧]

**លោក ឃីត សេយ៍ន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពសួស្តីភាគីទាំងអស់ និងសួស្តីលោក ហេងឆ័រ។

លោកប្រធាន នៅពេលនេះខ្ញុំស្នើសុំពីរចំណុច។ ទី១ សំណុំឯកសារទាំងបួន ដែលលោក ហេងឌ័រ បានមានកាលពីថ្ងៃព្រហស្បតិ៍នោះ នៅពេលនេះសូមផ្តល់ឲ្យគាត់ឡើងវិញ។ ហើយចំណុចទី២ ខ្ញុំសូមផ្តល់នូវសំណុំឯកសារទី៥ ជូនទៅកាន់គាត់ផងដែរ។

នៅពេលនេះ លោកប្រធាន ខ្ញុំមានលិបិក្រម ឬក៏ អ៊ីនឌិច នេះមួយចំនួនទៀត។ ហើយដែលខ្ញុំគ្រងនឹងបញ្ជូនទៅអង្គជំនុំជម្រះរួមទាំងភាគីនៅក្នុងពេលសវនាការនេះ។ សូមអនុញ្ញាតលោកប្រធាន។

[០៩:០៧:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន! អស់លោក លោកស្រីចៅក្រមជាទីគោរព ភាគីទាំងអស់ជាទីគោរព។ ខ្ញុំមិនទាន់ដឹងថានៅក្នុងសំណុំឯកសារទី៥ ដែលសហព្រះរាជអាជ្ញាចង់ផ្តល់ទៅសាក្សីនេះទេ។ បើសិនជាឯកសារថ្មីវិញនោះ ដែលមាននៅក្នុងបញ្ជីកាលពីចុងសប្តាហ៍នេះ ដោយមានឯកសារកាសែត -- អត្ថបទកាសែតមួយចំនួនដែលបានផ្ញើតាមអ៊ីម៉ែល។ អ៊ីចឹងខ្ញុំសូមជំទាស់លើឯកសារទាំងនេះ ដោយសារក្នុងនោះមានមួយចំនួនដែលមិនមាននៅក្នុង*ខេស-ហ្វាល* ទេ។ ហើយយើងបានស្រាវជ្រាវផងដែរ ក៏ប៉ុន្តែយើងរកមិនឃើញ។ អ៊ីចឹងមុននឹងពេលផ្តល់ឯកសារនេះទៅសាក្សី អ៊ីចឹងខ្ញុំសូមបញ្ជាក់ថា ឯកសារនេះបានដាក់នៅក្នុងបញ្ជី -- សហព្រះរាជអាជ្ញាបានដាក់ចូលក្នុងបញ្ជីចុងសប្តាហ៍នេះ។ ក៏ប៉ុន្តែមិនទាន់មាននៅក្នុងសំណុំរឿងទេ។

[០៩:០៨:៥៣]

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំយល់អំពីការសង្កេតនេះ។ យើងមិនធ្វើការឆ្លើយតបទៅនឹងបញ្ហាអ៊ីម៉ែលនោះទេ។ ហើយខ្ញុំគ្រាន់តែផ្តល់ជូននូវលិបិក្រម ដែលយើងខ្ញុំដាក់ជូននេះ មិនមែនពាក់ព័ន្ធទៅនឹងបញ្ហាអ៊ីម៉ែលនោះទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសហ្នឹងយកមកចែកជូនដល់អង្គជំនុំជម្រះ និងភាគី។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ក៏មានបណ្តុំឯកសារមួយចំនួនទៀតសម្រាប់លោក ហេងឌ័រ ផងដែរនៅក្នុងសំណុំឯកសាររបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតផ្តល់ជូនទៅកាន់លោក ហេងឌ័រ ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារទាំងបួន *ហ្វាល* ហើយនិងឯកសារបន្ថែមនេះ យកទៅជូនសាក្សីពិនិត្យ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ នៅពេលនេះ លោកមានសំណុំឯកសារចំនួនប្រាំនៅចំពោះមុខលោក។ នៅពេលនេះ ខ្ញុំសូមសួរលោកសំណុំឯកសារទី២ សូមឲ្យលោកទាញយកសំណុំឯកសារទី២ យកមកពិនិត្យមើល។ សំណុំឯកសារទី២ *ថេបហ្វ័រ – ថេប៤*។ សំណុំឯកសារពីរថេប៤ ឯកសារ E3/573។ ការរៀបរាប់នៅក្នុងឯកសារនេះ លោក ហេងឌ័រ គឺជាប្រតិចារឹកនៃកំណត់សម្គាល់ដោយដៃ របស់លោក ហេងឌ័រ ធ្វើឡើងសម្ភាសជាមួយលោក អៀង សារី នៅថ្ងៃ០៤ ខែមករា ឆ្នាំ៩៩។

ដូច្នេះ ជាដំបូង ខ្ញុំសួរលោកថាតើលោកធ្វើការកត់ត្រាដោយដៃខ្លីៗដែរឬទេ នៅពេលដែលលោកសម្ភាសលោក អៀង សារី?

[០៩:១២:០០]

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** បាទ គឺខ្ញុំធ្វើដូច្នោះ។

**ស៖** ខ្ញុំសូមចូលទៅដល់ចំណុចដកស្រង់ នៅពាក់កណ្តាលទំព័រ ដែលក្នុងនោះលើកឡើងថា "ខៀវ សំផន បានក្លាយទៅជាសមាជិកគណៈមជ្ឈិម នៅក្នុងឆ្នាំ១៩៧៦។ ទោះបីជានៅក្នុងឆ្នាំ១៩៧៥ គាត់គឺជា -- គាត់បានចូលរួមដោយជាក់ស្តែងនៅក្នុងគណៈកម្មាធិការនោះ។ ក្នុងនាមជាប្រធាន៨៧០ ការបញ្ជូន និងការដកកម្មាភិបាល គឺត្រូវតែឆ្លងកាត់តុរបស់គាត់។ គាត់គេប្រាប់គាត់ -- គាត់នឹងត្រូវបានគេប្រាប់អំពីថាផ្នែកណាខ្លះត្រូវបានបញ្ជូនទៅចម្ការ ដើម្បីឲ្យគាត់បានដឹងច្រើនជាងខ្ញុំ"។ សូមបញ្ចប់ការដកស្រង់។ តើនេះជាអ្វីដែលលោក អៀង សារី ប្រាប់លោកអំពីលោក ខៀវ សំផន នេះដែរឬទេ? តើលោកនៅចាំទេ ចំណុចហ្នឹង?

**ឆ៖** បាទ គឺជាការរៀបរាប់របស់គាត់ប្រាប់ខ្ញុំ។

**ស៖** ខ្ញុំប្រហែលជាដកស្រង់លេខឯកសារខុស។ គឺខ្ញុំយោងអម្បាញ់មិញនេះ គឺឯកសារលេខ E3/573។ លោក ហេងឌ័រ ចំណុចដកស្រង់ដែលខ្ញុំទើបតែលើកឡើងអម្បាញ់មិញ ហើយលោកបញ្ជាក់ថាពិតជាត្រឹមត្រូវនោះ រួមទាំងពាក្យថា ការងារអ្នកនេះអ្នកនោះ ត្រូវបានគេបញ្ជូនទៅចម្ការ។ តើវាមានន័យយ៉ាងម៉េចដែរ ពាក្យថា“ចម្ការ”នេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សំដៅលើយ៉ាងម៉េចដែរ?

[០៩:១៣:៥១]

**ឆ៖** ចម្ការគឺជាកន្លែងធ្វើស្រូវ។ គឺជាកន្លែងដែលមិនមែនដាំស្រូវទេ គឺថាជាចម្ការដាំបន្លែបង្ការ។ ដូច្នេះតាមពាក្យនេះ ការបញ្ជូនទៅចម្ការ ឬក៏ស្រែ។ បានន័យថា មិនមែនស្រែសម្រាប់ដាំស្រូវទេ គឺទៅចម្ការ ឬក៏ដីដែលសម្រាប់ដាំបន្លែបង្ការ។

**ស៖** ប្រសិនបើលោកអាច អៀង សារី បានរៀបរាប់អំពីលោក ខៀវ សំផន។ ហើយគាត់បានលើកឡើងថា ឆ្លងកាត់តុគាត់ ការបញ្ជូន និងការដកកម្មាភិបាល ត្រូវតែឆ្លងកាត់តុគាត់។ តើខ្ញុំសូមសួរទៅលើពាក្យថា “ដក”នេះ។ នៅក្នុងកិច្ចសម្ភាសន៍ទាំងអស់ដែលលោកបានធ្វើឡើង ហើយតាមប្រភពអង្គហេតុផ្ទាល់តែម្តង សូមឲ្យលោកកុំធ្វើការទាយស្មាន ឬក៏លោកកុំធ្វើការផ្តល់ជាមតិយោបល់អី។ តើពាក្យ “ដក” មានន័យរបស់វាបង្កប់យ៉ាងម៉េចដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អាស្រ័យទៅលើបរិបទរបស់វា។ ជាការពិត ខ្ញុំសូមនិយាយអីចេះវិញ។ ពាក្យសាមញ្ញនៃពាក្យនេះ គឺទៅតាមន័យរបស់វាតាមការបកប្រែ ពាក្យថា“ដក”ហ្នឹងគឺថាមានន័យ “ដក” អ៊ីចឹង។ តើការដកហ្នឹងមានន័យជាក់លាក់យ៉ាងម៉េចនោះ គឺវាមានបំណងទុកឲ្យមានលក្ខណៈស្រពេចស្រពិលតាមពាក្យរបស់វា។ វាអាចមាន័យផ្សេងពីពាក្យដកចេញហ្នឹង។ បានន័យថាឧទាហរណ៍ថាអាចមានន័យថាដកចេញពីមុខតំណែងៗ ឬក៏ក្រោយមកកើតមានអ្វីទៀតចំពោះគាត់។ ក្នុងនេះបង្កប់ន័យ ដូច្នេះនៅពេលដែលគេប្រើពាក្យ។ ការប្រើពាក្យនេះ មិនអាចឆ្លើយតបទៅនឹងសំណួរចំណោទនេះបានទេ។ តើន័យវាពេញលេញយ៉ាងម៉េចនោះ ហើយការបង្កប់ន័យរបស់វានោះយ៉ាងម៉េចគឺថាវាមិនអាចមានន័យជាក់ស្តែងទេ។

[០៩:១៦:១៨]

**ស៖** តើពាក្យថា “ដក” នេះមានដែលគេប្រើក្នុងបរិបទនៃការចាប់ខ្លួនដែរឬទេ?

**ឆ៖** បាទ គេធ្លាប់ប្រើអ៊ីចឹង។ គេអាចដកចេញ គឺតាមរយៈការចាប់ខ្លួននេះឯង ហើយនិងវាអាចមានលទ្ធភាពផ្សេងទៀតដែលវាមានន័យក្រៅពីហ្នឹង។

**ស៖** នៅពេល អៀង សារី ប្រាប់លោកថា ខៀវ សំផន ធ្លាប់ជាប្រធាន៨៧០ តើវាមានភាពសង្ស័យជាក់ស្តែងណាមួយតាមសំឡេងដែល អៀង សារី គាត់និយាយនោះដែរឬទេ នៅពេលដែលគាត់លោកថា ខៀវ សំផន ជាប្រធាននោះ?

**ឆ៖** អត់មានទេ។

**ស៖** ក្រៅពីនិយាយអំពីលោក ខៀវ សំផន បានដក និង -- ការដក និងការបញ្ជូនកម្មាភិបាលត្រូវឆ្លងកាត់តុរបស់គាត់ក្នុងនាមជាប្រធាន៨៧០។ តើលោក អៀង សារី មានរៀបរាប់លម្អិតអំពីការទំនាក់ទំនងរបស់លោក ខៀវ សំផន ជាមួយនឹង៨៧០ ដែរឬទេ? ហើយគាត់មានបាននិយាយថាតើ ខៀវ សំផន ធ្វើអ្វីនៅទីនោះដែរឬទេ?

[០៩:១៧:៥០]

**ឆ៖** គ្មានអ្វីដែលនិយាយក្រៅតែពីសរសេរនៅក្នុងឯកសារនេះឡើយ។

**ស៖** នៅពេលនេះ ខ្ញុំចូលទៅដល់សំណុំឯកសារមួយឡែក។ សូមឲ្យលោកទុកសំណុំឯកសារអម្បាញ់មិញនេះទុកមួយឡែកសិនទៅ ហើយសូមឲ្យលោកយកសំណុំឯកសារទី៣ យកមកពិនិត្យមើលវិញម្តង។

លោក ហេដឌ័រ សំណុំឯកសារទី៣ *ថេប*៩ ឯកសារលេខ E190.1.7.72។ នៅខាងលើ ស្ទីវ ហេដឌ័រ សម្ភាសជាមួយនឹង វ៉ាន់ រិទ្ធ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៤ ស្រុកស្អាង ខេត្តកណ្តាល។ ជាដំបូងលោក ហេដឌ័រ ជាការណែនាំសេចក្តីផ្តើមបន្តិច ថាតើការសម្ភាសនេះ ជាមួយនឹង វ៉ាន់ រិទ្ធ ហ្នឹងរៀបចំឡើងដោយរបៀបណាដែរ?

**ឆ៖** តាមពាក្យរបស់អ្នកកាសែត គឺថា ខ្ញុំគ្រាន់តែសួរគាត់ថាគាត់រស់នៅទីណា? ហើយខ្ញុំទៅនិវេសនដ្ឋាន ឬក៏ផ្ទះរបស់គាត់ហ្នឹងដើម្បីទៅសួរគាត់តែប៉ុណ្ណោះ។

[០៩:១៩:៤៣]

**ស៖** នៅក្នុងសំណុំ -- នៅក្នុង*ថេប*លេខ៩ ដែលគេកត់ត្រាទុកនូវចំណុចដែលមាននៅក្នុងកិច្ចសម្ភាសន៍។ ក្រៅពីការសរសេរចូលដូច្នេះនោះ តើលោកមានធ្វើជាសរសេរជាកំណត់ហេតុផ្ទាល់ដៃខ្លួនឯងដែរឬទេ? កំណត់ហេតុឯកសារនេះសរុបប្រាំពីរទំព័រ។ ដូច្នេះ តើលោកអាចបញ្ជាក់បានដែរឬទេ តើលោកមានធ្វើការកត់ត្រាដោយផ្ទាល់ដៃខ្លីៗដែរឬទេ នៅពេលដែលលោកសម្ភាសជាមួយនឹង វ៉ាន់ រិទ្ធ នាពេលនោះ?

**ឆ៖** បាទ គឺខ្ញុំបានកត់ត្រា។

**ស៖** ប្រសិនបើយើងមើលទៅលើឯកសារ ដែលគេវាយបញ្ចូលនៅក្នុងនេះ *ថេប៩* ក្នុងនោះគឺបានរៀបរាប់ដូចតទៅ៖ "វ៉ាន់ រិទ្ធ បានបញ្ជាក់ថា ខៀវ សំភន គឺជាប្រធាន៨៧០ បន្ទាប់ពី ខឿន។ នៅក្នុងមុខនាទីនោះ វ៉ាន់ រិទ្ធ សម្របសម្រួលជាមួយនឹងគាត់ពាក់ព័ន្ធទៅនឹងបញ្ហាពាណិជ្ជកម្ម ហើយបានស្នើសុំសម្ភារៈ ដែលបញ្ជូនមកពីក្រសួង មជ្ឈិម តាមរយៈ៨៧០ មកកាន់ វ៉ាន់ រិទ្ធ។ គាត់មិនដឹងថាទិដ្ឋភាពការងាររបស់គណៈមជ្ឈិមនោះអ្វីខ្លះនោះទេ ដែល ខៀវ សំផន ធ្វើការងារ។ ក៏ប៉ុន្តែគាត់មិនបដិសេធថា វាមិនរួមបញ្ចូលទាំងបញ្ហាសន្តិសុខ និងយោធានោះទេ"។ តើលោកអាចបញ្ជាក់ទេ វ៉ាន់ រិទ្ធ គាត់បានរៀបរាប់ប្រាប់លោកដូច្នេះនៅក្នុងពេលសម្ភាស?

[០៩:២១:២៦]

**ឆ៖** បាទ គាត់រៀបរាប់តាមអ្វីដែលលើកឡើងក្នុងនេះ។

**ស៖** នៅក្នុងកថាខណ្ឌក្រោមទៀត ដែលកត់ត្រាដូចតទៅ តាមពាក្យសម្ដីដូចតទៅ៖ "នៅពេល ខៀវ សំផន ប្រាប់គាត់នៅក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៨ ដែលថាមជ្ឈិមចង់ឲ្យគាត់ធ្វើដំណើរទៅទស្សនកិច្ចកាន់ពាយ័ព្យពាក់ព័ន្ធបញ្ហាពាណិជ្ជកម្ម គាត់មានការភ័យខ្លាចថាអាចគេចាប់ខ្លួនគាត់"។ តើលោកអាចបញ្ជាក់បានដែរឬទេ ចំណុចនេះគឺ វ៉ាន់ រិទ្ធ គាត់បានប្រាប់លោកនៅក្នុងពេលលោកសម្ភាស?

**ឆ៖** បាទ គាត់បានឆ្លើយដូច្នោះមែន។

**ស៖** ចូលទៅដល់ទំព័រមួយទៀត ដែលអង់គ្លេស 007447760, បារាំង 00744418, ខ្មែរគឺមានលេខ 00742278 ហើយដែលពាក់ព័ន្ធនៅក្នុងឆ្នាំ១៩៧៨ គាត់លើកឡើងដូចតទៅ៖ "គាត់ (គាត់នេះសំដៅលើ វ៉ាន់ រិទ្ធិ) គាត់បានប្រាប់ទៅ ខៀវ សំផន នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ថាបដិវត្តន៍នៅតាមជនបទគឺជាការបរាជ័យមួយ ព្រោះមិនមានការលោតផ្លោះនោះទេ ក៏ប៉ុន្តែភាពអត់ឃ្លានជាក់ស្ដែងកើតឡើងទៅវិញ"។ បញ្ចប់ការដកស្រង់។ តើលោកអាចបញ្ជាក់ដែរឬទេ នៅក្នុងនេះគឺជាអ្វីដែល វ៉ាន់ រិទ្ធ បានឆ្លើយបញ្ជាក់ប្រាប់នៅពេលដែលមានការសម្ភាសជាមួយនឹងគាត់នោះ?

[០៩:២៣:០៤]

**ឆ៖** បាទ គឺគាត់ឆ្លើយដូច្នោះមែន។

**ស៖** សំណួរខាងក្រោមបន្តទៀត កុំឲ្យលោកធ្វើការទាយស្មាន សូមឲ្យលោកផ្អែកទៅលើប្រភពដែលលោកបានដឹង តាមរយៈការសម្ភាស ឬក៏តាមមធ្យោបាយផ្សេងទៀត។ តើលោកបានឃើញ

ឯកសារសម្ភារៈជាក់ស្តែង ដែលក្នុងនោះនិយាយអំពីលោក វ៉ាន់ រិទ្ធ នេះធ្វើការសម្របសម្រួលបញ្ហាពាណិជ្ជកម្មជាមួយនឹងលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** ប្រហែលនៅក្នុងបញ្ហាសម្ភារៈ -- ឯកសារសម្ភារៈទាំងអស់នេះវាអាចលេចចេញមែន ក៏ប៉ុន្តែខ្ញុំមិនអាចចាំទេថាតើវាមានលក្ខណៈស្រដៀងយ៉ាងម៉េចឯកសារទាំងអស់នោះ។ កិច្ចសម្ភាសន៍ធ្វើឡើងក្នុងឆ្នាំ២០០៥ គឺបានបង្ហាញចំណុចទាំងអស់នេះ ក៏ប៉ុន្តែខ្ញុំមិនចាំជាក់លាក់ថាមានឯកសារណាដែរឬទេនោះឡើយ។

**ស៖** តើលោកធ្លាប់បានឃើញក្រសួងពាណិជ្ជកម្ម ឯកសារក្រសួងពាណិជ្ជកម្មដែលក្នុងនោះបានលើកឡើង ខៀវ សំផន ឬក៏ ហែម នេះដែរឬទេ? តាមរយៈឯកសារទាំងអស់នោះ ឧទាហរណ៍ថាឯកសារក្រសួងពាណិជ្ជកម្មនោះ តើមានការលើកឡើងឈ្មោះ ហែម ឬក៏ឈ្មោះ ខៀវ សំផន ហៅ ហែម នេះដែរឬទេ?

[០៩:២៤:៤១]

**ឆ៖** ខ្ញុំបានឃើញឯកសារប្រភេទនោះ គឺនៅពេលដែលវាមាននៅក្នុងសំណុំឯកសារនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា។ ឯកសារទាំងអស់នោះ គឺថាខ្ញុំបានឃើញនៅពេលដែលខ្ញុំធ្វើការងារនៅ ក.ស.ច.ស – សហចៅក្រមស៊ើបអង្កេត– ឬក៏ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ក៏ប៉ុន្តែខ្ញុំមិនចាំនៅផ្នែកណានោះឡើយ។

**ស៖** ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀត សំណុំឯកសារទី៤ *ថេប*៤។ ឯកសារនេះដកស្រង់ចេញមកពី “បេក្ខជនប្រាំពីរនាក់សម្រាប់ការចោទប្រកាន់”។ ខ្ញុំសូមដកស្រង់ចេញពីទំព័រលេខ៩៣ ដែលទំព័រចុងក្រោយនៅក្នុងសំណុំឯកសារនេះ។ តើលោកឃើញទំព័រនោះហើយឬនៅ ទំព័រនោះគឺ ទំព័រ៩៣ នៅខាងលើខាងស្តាំ។ សូមដកស្រង់ចេញពីសៀវភៅនេះ៖ “ជាពិសេស (ការយោងនេះគឺថាយោងទៅលើ ខៀវ សំផន) ជាពិសេសនៅក្នុងមុខនាទីរបស់គាត់ជាប្រធាន៨៧០ ខៀវ សំផន គាត់មានវត្តមានជាអ្នកធ្វើកំណត់ហេតុនៅក្នុងពេលប្រជុំសម្ងាត់នៅឆមាសទី១ ឆ្នាំ៧៨ ដែលក្នុងនោះ ប៉ុល ពត, នួន ជា និង សុន សេន បានបញ្ជាឲ្យមានការបោសសម្អាត និងកាប់សម្លាប់លេខាភូមិភាគបូព៌ា សោ ភឹម ហើយនិងមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា និងកម្មាភិបាលនៅភូមិភាគបូព៌ាផ្សេងទៀត។ កំណត់ហេតុជើងទំព័រ៣៦១ យោងទៅលើឯកសារពីរ E3/1595 គឺការសម្លាប់ក្នុងលក្ខណៈលម្អិត នៅក្នុងឯកសារ *ហ្វាល អេកូណូមិករីវ្យូ*។ --

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឱ្យលោកសហព្រះរាជអាជ្ញាបញ្ជាក់ឱ្យបានយឺតៗនៅចំណុចលេខយោងជើងទំព័រដែលពួកគាត់បានលើកឡើងអម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់លេខជើងទំព័រចុងក្រោយ ដែលលោកលើកឡើងចុងក្រោយ អម្បាញ់មិញនេះសាជាថ្មីព្រោះអ្នកបកប្រែ បកប្រែមិនទាន់ទេ។

**លោក យឹត ឆេយ៍ន័រ៖**

លេខយោងនៅក្នុងសៀវភៅ "បេក្ខជនប្រាំពីរនាក់ដែលត្រូវចោទប្រកាន់" គឺលេខ៣៦១។ ឯកសារដែលគាំទ្រទៅលើលេខយោងទំព័រនោះគឺ E3/1915 និង E3/1567។

**ស៖** លោក ហេដឌ័រ! នេត ថាយ័រ -- សូមឱ្យលោករៀបរាប់លម្អិតបន្តិច តើលោកអាចរៀបរាប់បញ្ជាក់ដែរឬទេ នៅពេលណាដែរ ដែល នេត ថាយ័រ នេះបាននិយាយជាមួយនឹង ឌុច? សូមឱ្យលោកនិយាយអំពីព័ត៌មានលម្អិតបន្តិចមក តែកុំឱ្យលម្អិតច្រើនពេក។

[០៩:២៨:២៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** គាត់គឺ-- នេត ថាយ័រ គឺជាអ្នកកាសែត។ គាត់ធ្វើការនៅទីក្រុងបាងកក និងទីក្រុងភ្នំពេញ។ ជាពិសេសនៅក្នុងទីក្រុងភ្នំពេញគាត់ធ្វើការនៅទីក្រុងភ្នំពេញជាពិសេស។ ប្រហែលជានៅក្រោយសម័យអ៊ុនតាក់រហូតមកដល់ចុងទសវត្សរ៍ឆ្នាំ៩០ ហើយ នេត ថាយ័រ នេះគឺគាត់បានសម្ភាសជាមួយនឹង ឌុច ជជែកជាមួយនឹង ឌុច, ហើយ នេត ថាយ័រ គាត់មានវត្តមាននៅក្នុងពេលសម្ភាសប្រហែលជានៅដើមឆ្នាំ៩០ តាមខ្ញុំចាំមិនខុសនោះ។ គឺនៅពេលដែលគាត់សម្ភាសនោះ គឺថាមានវត្តមានមន្ត្រីមួយរូបពីឧត្តមស្នងការសិទ្ធិមនុស្សនៅក្នុងសម័យនោះ គឺខ្ញុំចាំបានប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ នៅក្នុងសំណុំឯកសារ៤ *ថេប៤* ដដែលផ្នែកដែលលោកកំពុងមើលនេះ ក៏ប៉ុន្តែឱ្យលោកមើលត្រឡប់ក្រោយ គឺទំព័រ៦៥ ឯកសារE3/48 "បេក្ខជនប្រាំពីរនាក់សម្រាប់ការចោទប្រកាន់" ទំព័រ៦៥ លេខយោងជើងទំព័រ២៣៤។ គឺបាន -- លោកយោងដូចតទៅ ការយោងនេះគឺថាទៅលើរបាយការណ៍។ "របាយការណ៍ទាំងអស់នេះពេលខ្លះលើកឡើងបញ្ជូនដោយផ្ទាល់ទៅ ប៉ុល ពត រួមទាំងមានអក្សរកាត់ ឬក៏ឈ្មោះហៅក្រៅរបស់គាត់ គឺ០០៩ ក៏ប៉ុន្តែជាញឹកញាប់របាយការណ៍ទាំងអស់

នេះ គ្រាន់តែដាក់ថាជូនបងៗ និងអង្គការ ឬក៏គណៈមជ្ឈិមតាមរយៈលេខកូដ៨៧០។ ក៏ប៉ុន្តែឯកសាររបាយការណ៍ទាំងអស់នេះជាញឹកញាប់ គឺត្រូវបានចម្លងជូនអ្នកទទួលមួយចំនួនដែលក្នុងនោះរួមទាំង នួន ជា។ ជាក់លាក់ជាងនេះ របាយការណ៍ទាំងអស់នេះត្រូវបានកំណត់សម្គាល់ថា ថតចម្លង និងបញ្ជូនចម្លងជូនទៅអ្នកដែលជាសមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់ ឬក៏ប្រាំនាក់ដែលជាធម្មតាស្នាក់នៅទីក្រុងភ្នំពេញ។ ប៉ុល ពត ហៅថាអ៊ំ។ នួន ជា ហៅថា អ៊ំនួន។ អៀង សារី ហៅថា បងវ៉ាន់ ហើយខ្មោច វន វ៉េត នេះត្រូវបានគេហៅថា បងវន។ ហើយខ្មោច សុន សេន នេះគេហៅថា បងខៀវ”។

[០៩:៣១:២៤]

នៅក្នុងលេខយោង២៣៤ គឺលោកបានបញ្ជាក់ថា “បញ្ជីឈ្មោះនោះជាទូទៅគេសរសេរដាក់ខាងក្រោមឯកសារ។ ដូចឯកសារនោះតែម្តង ជាទូទៅគឺថាឯកសារនោះបានវាយអង្គុលីលេខ។ ចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៨ បងខៀវនេះមិនបានគេចម្លងជូននោះឡើយ ដោយសារតែគាត់ត្រូវបំពេញឈរជើងនៅព្រំដែនវៀតណាម។ ពាក់ព័ន្ធទៅនឹងសមាជិកទាំងប្រាំ នៅក្នុងគណៈអចិន្ត្រៃយ៍នេះគឺថាបញ្ជីនោះរួមមានការសរសេរថា ចម្លងជូនទៅមន្ទីរ រួមទាំងដើម្បីទុកជាឯកសារផងដែរ”។ សូមបញ្ចប់ការដកស្រង់។

លោក ហេដឌ័រ សំណួរដែលខ្ញុំសូមសួរប្រហែល សូមឲ្យលោកបញ្ជាក់ប្រហែលទៅមើល៍ តើរបាយការណ៍ប្រភេទនេះ លោកធ្លាប់ឃើញប៉ុន្មាន ប្រហែលជាប៉ុន្មានដងដែរ គ្រាន់តែជាចំនួនប្រហែលប៉ុន្មានដងទៅបានហើយ?

**ឆ៖** តាមរបាយការណ៍ដែលបានសរសេរយោងនៅក្នុងអត្ថបទនេះ របាយការណ៍នោះជាការពិតទៅ គឺជាសារទូរលេខ គឺថាប្រហែលជាជាង១២ ដែលខ្ញុំធ្លាប់ឃើញ។

[០៩:៣២:៥៤]

**ស៖** សូមអរគុណ។ នៅពេលនេះ លោកសូមឲ្យលោកពិនិត្យមើលសំណុំឯកសារទី៥។ លោក ហេដឌ័រ សំណុំឯកសារទី៥ លិបិក្រមលេខ១ ឬក៏លេខ២ -- លោកអាចឆ្លើយទាំងពីរតែម្តង ឬក៏ទៅតាមលេខ១ ឬលេខ២ តាមដែលលោកឆ្លើយទៅបាន។ ឯកសារ E3/724 យុវជនទង់បដិវត្តខែកក្កដា ឆ្នាំ១៩៧៥ និងឯកសារទី២ E3/731 ទស្សនាវដ្តីទង់បដិវត្តលេខពិសេស ខែធ្នូ ឆ្នាំ៧៥ ទៅដល់ខែមករា ឆ្នាំ៧៦។ លោក ហេដឌ័រ ពាក់ព័ន្ធទៅនឹងឯកសារទស្សនាវដ្តីទង់បដិវត្ត សំណុំឯកសារបានបង្ហាញថា គឺថាខ្ញុំសូមលើកឡើងចំពោះឯកសារ “ទស្សនាវដ្តីទង់បដិវត្តនេះ” គេលើកឡើងថា គេស្នើសុំឲ្យលោកផ្តល់ឯកសារទស្សនាវដ្តីទង់បដិវត្តនេះពីរច្បាប់មកកាន់តុលាការនេះ តើលោកបានផ្តល់ជូនតុលាការនេះ

ប៉ុន្មានច្បាប់ដែរ តាមការស្នើសុំរបស់គេ?

**ឆ៖** យ៉ាងហោច ទស្សនាវដ្ដីទង់បដិវត្ត ឬក៏ទង់យុវជនទង់បដិវត្តនេះ គឺថាខ្ញុំអត់ចាំច្បាស់ទេ មិនដឹងថាមួយណា តែខ្ញុំបានផ្ដល់ឲ្យ។

**សៈ** យើងសរុបរួមតែម្ដងទៅ យុវជនទង់បដិវត្ត យុវជនបដិវត្ត ឬក៏ទស្សនាវដ្ដីទង់បដិវត្ត។ ខ្ញុំសូមសួរលោកតែម្ដង តើលោកបានឃើញឯកសារនេះលើកទី១នៅពេលណា? ឯកសារដើម ឬក៏ឯកសារចម្លង? ប្រហែលជាឆ្នាំណាដែរ ដែលលោកបានឃើញទស្សនាវដ្ដីទង់បដិវត្ត ឬក៏យុវជនទង់បដិវត្តនេះ តើលោកបានឃើញដំបូងនៅក្នុងឆ្នាំណា? ហើយជាឯកសារដើម ឬក៏ឯកសារច្បាប់ថតចម្លង?

[០៩:៣៥:៤៥]

**ឆ៖** ជាការពិតនៅឆ្នាំ១៩៨០ ប្រហែលជាឆ្នាំ៧៩ ក៏ប៉ុន្តែលើកដំបូងកម្រងឯកសារនោះ គឺថាប្រហែលជាក្នុងឆ្នាំនុំង ទស្សនាវដ្ដីទង់បដិវត្ត ឬក៏យុវជនទង់បដិវត្តនេះ។ គឺខ្ញុំមិនបានឃើញរហូតមកដល់ចុងទសវត្សរ៍ឆ្នាំ៨០ ទើបបានឃើញ។ ឯកសារដែលខ្ញុំត្រូវបានស្នើសុំពីតុលាការ ហើយខ្ញុំបានផ្ដល់ទៅជូនតុលាការនោះ គឺជាឯកសារដែលខ្ញុំបានឃើញនៅចុងទសវត្សរ៍ឆ្នាំ១៩៨០។ គឺវាជាឯកសារនៅក្នុងចំណោមសំណុំឯកសារទាំងឡាយដែលមាននៅក្នុងកម្រងទស្សនាវដ្ដីទង់បដិវត្ត យុវជនទង់បដិវត្ត ដែលឯកសារទាំងអស់នោះ គឺថានៅ តម្កល់ទុកនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ហើយដែលអ្នកកាន់បណ្ណសារនៅទីនោះ បានផ្ដល់ជូនមកឲ្យខ្ញុំ ហើយខ្ញុំក៏បានផ្ដល់ជូនទៅតុលាការតាមការស្នើសុំ។

**សៈ** នៅពេលដែលលោកនិយាយថា មាននៅក្នុងសំណុំឯកសារនៅទីនោះ សូមឲ្យលោកមើលឯកសារ *ថេប*១ គឺE3/724។ យើងអាចឃើញឯកសារដែលមាននៅក្នុងនេះ ទំព័រក្របវាគឺពណ៌ក្រហម បានន័យថាទំព័រក្របមុខពីរច្បាប់ហ្នឹងគឺថាមានពណ៌ក្រហម។ តើលោកអាចបញ្ជាក់ទេ ជាឯកសារប្រភេទហ្នឹងដែរឬទេ?

[០៩:៣៧:២៧]

**ឆ៖** បាទ ជាឯកសារប្រភេទហ្នឹង។ ខ្ញុំសូមបញ្ជាក់ នៅពេលដែលខ្ញុំឃើញឯកសារហ្នឹងមានច្បាប់ដើមជាច្រើននោះ គឺថាច្បាប់នោះជាច្បាប់ដើម មានពីរបីច្បាប់ជាន់គ្នា។ ហើយគឺមិនមានការថតចម្លងទេ នៅសម័យនោះនៅទីក្រុងភ្នំពេញ។ អ្នកកាន់បណ្ណសារនោះបានផ្ដល់ឯកសារហ្នឹង មួយច្បាប់ច្បាប់ដើមឲ្យខ្ញុំ ហើយអ្នកដែលអ្នកជាបណ្ណសារហ្នឹង ក៏មានឯកសារដូចខ្ញុំហ្នឹង មួយច្បាប់ដើមផងដែរ។ ខ្ញុំយកឯកសារហ្នឹងច្បាប់ដើមមួយច្បាប់ យើងអត់ថតចម្លងទេសម័យនោះ។ ដូច្នេះបានន័យថាខ្ញុំមានមួយ

ច្បាប់ ក៏មានគេមានច្បាប់ដែរ ជាច្បាប់ដើម។

**ស៖** បើសិនណាជាខ្ញុំហៅ -- បង្ហាញទំព័រនីមួយៗ និងឯកសារទី២ និងស្ថានភាពនៃទស្សនាវដ្តីដែលបានបង្ហាញជូន។ ឯកសារនេះ គឺជាឯកសារដែលលោកបានឃើញនៅពេលនោះ។ តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ គឺមាននៅក្នុងសំណុំរឿងដែលយកមកដាក់នៅទីនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[០៩:៣៨:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ បើខ្ញុំយល់មិនច្រឡំទេ គឺឥឡូវនេះ កំពុងតែបានបង្ហាញឯកសារទង់បដិវត្តពណ៌ក្រហមជូនទៅសាក្សី។ ហើយដើម្បីឲ្យកូនក្តីរបស់ខ្ញុំនៅបន្ទប់ខាងក្រោម អាចឃើញនូវឯកសារកូល័រតែម្តង ខ្ញុំសូមសុំឲ្យព្រះរាជអាជ្ញាបង្ហាញជូននូវឯកសារកូល័រពណ៌ក្រហមនេះ ឲ្យកូនក្តីខ្ញុំបានឃើញផង។

**លោក ឃីត រេយ៍ន័រ៖**

មិនបញ្ហាអីទេលោក ខ្ញុំសូមពន្យល់។ នៅក្នុងសំណុំរឿង E3/724 គឺមានកូល័រពណ៌ក្រហម ប៉ុន្តែយើងក៏មានថតចម្លងដែរ។ ខ្ញុំសូមជូនឯកសារនេះទៅមេធាវីការពារក្តី។

[០៩:៣៩:៥៣]

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ សូមលោកមើលទៅលើ*ថេប*ទី១ គឺE3/724 នៅទំព័រទី១ គឺបន្ទាប់ពីក្របខាងមុខមក។ នៅក្បាលទំព័រខាងលើគឺមានសំណេរដោយដៃជាភាសាអង់គ្លេស។ គឺវានៅវឹមទំព័រនោះតែម្តង គឺនៅផ្នែកខាងលើ។ សូមលោកមើលឯកសារ*ថេប*១ ដែលនិយាយអំពីទង់បដិវត្តចំនួនពីរច្បាប់នៅត្រង់នោះ។ ឬក៏ខ្ញុំផ្តល់ឱកាសជូនលោកនូវឯកសារនេះ គឺឯកសារទង់បដិវត្តចំនួនពីរច្បាប់នៅទំព័រខាងមុខ គឺទង់យុវជន យុវនារីខែកក្កដា ១៩៧៥។ ខ្ញុំសូមបង្ហាញផ្នែកផ្សេងៗត្រង់ឯកសារនេះ។ លោកអាចជម្រាបបានទេ ថាតើចំណាររនេះ ជាចំណាររបស់អ្នកណា ឬក៏អាចសួរទៅវិញបានថា តើអក្សរសរសេរដោយដៃនេះ ជាអក្សរអ្នកណាដែរ?

**ឆ៖** បាទ សូមទៅមើលទៅទំព័រខាងមុខសិន ចំណារដែលនិយាយពី១៩៧៥។ ខ្ញុំសូមបង្ហាញអំពីប្រភពឯកសារនេះ : អក្សរពណ៌ក្រហមដែលយើងបកប្រែទៅ -- គឺខ្ញុំជាអ្នកបកប្រែ -- ប្រហែលជាពេលនោះខ្ញុំអស់ប៊ិកទឹកក្រហមទៅ ដូចជាចំណារដ៏វែងនៅក្នុងឯកសារនុ៎ង អក្សរដែលៗបញ្ជាក់នៅរឹមទំព័រ ហើយនិងចំណារជាភាសាអង់គ្លេសទាំងអស់នេះ គឺខ្ញុំជាអ្នកសរសេរ។

[០៩:៤២:២៣]

**ស៖** សំណួរដដែលទាក់ទងទៅនឹងឯកសារទី២ គឺ“ទង់បដិវត្ត” ហើយបើលោកមើលទំព័រខាងមុខមានកំណត់ត្រាប៊ិកពណ៌ក្រហមជាថ្មីម្តងទៀតហើយ ទាំងនៅលើទំព័រនោះ ទាំងនៅលើទំព័រ ទាំងនៅរឹមទំព័រ។

**ឆ៖** បាទ គឺយើងបានកែប្រែកាលបរិច្ឆេទនៅទំព័រខាងមុខ ហើយចំណារទាំងអស់នេះ គឺជាចំណាររបស់ខ្ញុំ។

**ស៖** សូមអរគុណ។ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថាឯកសារទី១ គឺថា E3/724 អក្សរពណ៌ក្រហមគឺ E169/4.1.1 និងឯកសារទី២គឺE3/731។ អក្សរពណ៌ក្រហមគឺ E169. -- បាទ E169/4/1.1.2 គឺឯកសារលេខ៣។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[០៩:៤៤:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមត្រឡប់ទៅចំណុចដែលខ្ញុំលើកឡើងខាងដើមវិញ ដើម្បីងាយស្រួលតាមដានទៅនឹងការតាំងសំណួរ។ ខ្ញុំអត់មានឯកសារនៅលើអេក្រង់នៅលើកុំព្យូទ័រនេះទេ។ ដូច្នេះដើម្បីឲ្យកូនក្តីខ្ញុំតាមដាននូវឯកសារនេះបាន គឺថាចំណុចដែលយើង -- ដែលលើកឡើងនៅលើអេក្រង់នេះ គឺលោក នួន ជា នៅខាងក្រោមនោះ គឺមិនអាចឃើញឯកសារទង់បដិវត្តពណ៌*កូល័រអូរីហ្សីន* នេះទេ។ ដោយសារ -- ហើយចំណុចនេះជាចំណុចដែលយើងកំពុងតែពិភាក្សាគ្នា។ យើងបង្ហាញឯកសារយ៉ាងលឿននៅពេលនេះ។ បាទជម្រាបដោយត្រង់ គឺខ្ញុំមានការកត់ត្រា ហើយនិងអ្វីៗដែលបានលើកឡើង។ ខ្ញុំសូមឲ្យព្រះរាជអាជ្ញាបង្ហាញឃីតបន្តិច បង្ហាញឯកសារនេះឲ្យបានឃីតបន្តិច ដើម្បីផ្តល់ឱកាសឲ្យយើងទាំងអស់នៅក្នុងបន្ទប់សវនាការនេះមើលឃើញឯកសារទង់បដិវត្ត ពណ៌*កូល័រអូរីហ្សីន*នេះផង ហើយក៏ដើម្បីបង្ហាញទៅដល់

សាក្សីផងដែរ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំសូមបង្ហាញនូវឯកសារទី១ ដែលខ្ញុំបានលើកឡើងគឺ E3/169/4/1.1.1។ ខ្ញុំដឹងថានៅលើឯកសារ។ ហើយលោក ហេដឌ័រ សំណួរដែលនឹងចម្លើយពាក់ព័ន្ធទៅនឹងឯកសារនេះ លោកបានសរសេរដោយដៃ គឺលោកសរសេរដាក់ថា "៧/៧៥" តើនេះត្រឹមត្រូវទេ ដែលថាវាជាចំណារ ជាអក្សររបស់លោក?

[០៩:៤៦:១៦]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ត្រឹមត្រូវហើយជាអក្សររបស់ខ្ញុំ។

**ស៖** ហើយខ្ញុំសូមសួរទៅទំព័របន្ទាប់ទៀត សូមឲ្យបង្ហាញទំព័របន្ទាប់ជូនដល់សាក្សី។ បាទនៅត្រង់នេះយើងមានពាក្យជាអង់គ្លេស ដែលសរសេរនៅលើអត្ថបទភាសាខ្មែរនៅត្រង់ គែមទំព័រ នៅគែមទំព័រខាងលើ ហើយក៏មានអូសបន្ទាត់ផងដែរ។ ហើយចម្លើយរបស់លោក លោកឆ្លើយថា "នេះគឺជាសំណេរដោយដៃរបស់លោក"។ តើវាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ខ្ញុំសូមសួរត្រង់ទំព័រនេះតទៅទៀត។ បាទបន្ទាប់ពីទំព័រខាងមុខ -- សូមដាក់ទំព័រខាងមុខតែម្តងដើម្បីឲ្យបានមើលឃើញទាំងអស់នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនបានបង្ហាញនៅលើអេក្រង់ទេ។

[០៩:៤៧:២៣]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានសូមឲ្យផ្នែកអេ.វី បង្ហាញឯកសារនេះនៅលើអេក្រង់ ទំព័រ ERN គឺ 00809793។

លោកប្រធានខ្ញុំដឹងថា ផ្នែកខាងសោតទស្សន៍កំពុងតែរៀបចំហើយ ខ្ញុំសូមបង្ហាញ ERN ផងគឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ 00809793។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកសោតទស្សន៍ដាក់បង្ហាញឯកសារលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍តាមការស្នើសុំ

របស់តំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានគឺមាននៅលើឯកសារហើយ។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ស៊្មីវ ហេងឆ័រ មាននៅលើអេក្រង់របស់លោកទេបាទ? គឺថាខ្ញុំឃើញមានអក្សរសរសេរដោយដៃនៅក្បាលទំព័រ និងនៅគែមទំព័រក៏មានសរសេរប៊ិកក្រហមដែរ ហើយក្នុងនោះក៏មានអូសបន្ទាត់នៅលើឯកសារនេះផងដែរ។ ថាតើឯកសារសរសេរដោយដៃទាំងអស់នេះជាអក្សរលោកឬ?

[០៩:៤៩:២៦]

**លោក ស៊្មីវ ហេងឆ័រ៖**

**ឆ៖** បាទ ជាអក្សរខ្ញុំ។

**ស៖** សូមបន្តទៅឯកសារទី២ គឺនៅឯកសារ *ថេប២* ផ្នែកខាងក្រោយ ឯកសារ E3/169/4/1.1.2 ។ សូមបង្ហាញទំព័រទី១ ERN ជាភាសាខ្មែរ 00809826។

*(សម្រាករយៈពេលខ្លី)*

បាទ ឥឡូវនេះឯកសារនេះនៅលើអេក្រង់កុំព្យូទ័រហើយ។ លោកហេងឆ័រ នៅលើឯកសារនេះក្បាលទំព័រគឺមានសរសេរដាក់ថា ១២/៧៥ ដល់ ១/៧៦ ជាប៊ិកពណ៌ក្រហម។ តើនេះជាអក្សរដៃរបស់លោកឬ?

**ឆ៖** បាទ។

**ស៖** ទំព័របន្ទាប់សូមឲ្យផ្នែក អេ.វី បង្ហាញផងដែរ ERNជាភាសាខ្មែរ 00809829។ ឥឡូវនេះយើងមានទំព័រនេះនៅលើអេក្រង់ហើយ។ លើទំព័រនេះក៏មានសរសេរដោយដៃដែរ សំណេរដោយដៃនេះនៅគែមទំព័រនៃឯកសារនេះតែម្តង។ ហើយក្នុងនោះក៏មានគូសបន្ទាត់ទៅលើអក្សរនៅលើទំព័រនេះផងដែរ។ តើលោកអាចបញ្ជាក់បានទេ តើសំណេរដោយដៃនេះជាអក្សររបស់លោកឬ?

**ឆ៖** បាទ ជាអក្សររបស់ខ្ញុំហើយ។

[០៩:៥២:០៩]

**ស៖** តើលោកអាចជម្រាបបានទេ ឯកសារ *អូរីហ្សីន* ដើមនៃឯកសារនេះនៅឯណាដែរ?

**ឆ៖** តាមការដែលខ្ញុំចាំគឺខ្ញុំបានជូនឯកសារដើមមកឲ្យតុលាការនេះហើយ។

**សៈ** បាទ សូមអរគុណច្រើន។ ខ្ញុំសូមចូលទៅឯកសារ *ថេបព៣ – ថេបស្រ៊ី*។ ឯកសារ*ថេបស្រ៊ី* នេះគឺ E3/25 ជាឯកសារទង់បដិវត្តពិសេសចុះខែធ្នូ ១៩៧៦ រហូតដល់ខែមករា ១៩៧៧។ បាទខ្ញុំសូមស្នើការអនុញ្ញាតបង្ហាញឯកសារនេះផងដែរបង្ហាញត្រង់ទំព័រ ERN ជាភាសាខ្មែរ 00063039, ERN ជាភាសាអង់គ្លេស 00491424 និង ERN ជាភាសាបារាំង 00504049 នេះគឺជាសម្រង់។ លោកហេដឌ័រ លោកមានទេនៅត្រង់ទំព័រដោយមានចំណងជើងថា ការវាយខ្មាំងតាមរូបភាពនយោបាយ។ ហើយខ្ញុំសូមជូនឯកសារយោង ជាភាសាខ្មែរ។

ខ្ញុំសូមស្នើឱ្យផ្នែក អេ.វី បង្ហាញទំព័រខ្មែរគឺ 00063039។ លោក ហេដឌ័រ តើលោកមានទំព័រនេះជាភាសាអង់គ្លេសនៅចំពោះមុខទេដែលមានចំណងជើងថាការវាយខ្មាំងតាមរូបភាពនយោបាយ។

**ឆៈ** ខ្ញុំមានហើយ។ ខ្ញុំសូមឱ្យបង្ហាញភាសាខ្មែរនេះទាំងស្រុងតែម្តង។ ដោយសារខ្ញុំចង់បញ្ជាក់នូវពាក្យពេចន៍មួយចំនួន។ ខ្ញុំសូមអានផ្នែកនេះទាំងស្រុងតែម្តង។ ការវាយប្រហារខ្មាំងតាមរូបភាពនយោបាយ សូមបង្ហាញជូនជាឧទាហរណ៍មួយ ដូចជាការវ៉ៃដើម្បីដណ្តើមប្រជាជននៅទូទាំងពិភពលោកនេះ គេមិនដែលវាយប្រហារ វាយប្រយុទ្ធដើម្បីដណ្តើមប្រជាជនទេ។ មាគ៌ារបស់យើងវាយប្រយុទ្ធដើម្បីដណ្តើមប្រជាជន។ នៅពេលយើងដណ្តើមបាន យើងយកប្រជាជនម្នាក់ក៏យើងយក ពីរក៏យើងយក ១០០ក៏យើងយក ២០០ក៏យក ១០០០នាក់ក៏យើងត្រូវតែប្រមូលជាដើម។ល។ រហូតដល់យើងវាយប្រយុទ្ធ និងក្តាប់ប្រមូលបានប្រជាជនទីក្រុងភ្នំពេញទាំងអស់។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងនេះ គឺជាមាគ៌ាត្រឹមត្រូវហើយ។ មាគ៌ានេះមិនដែលកើតមាននៅក្នុងពិភពលោកទេ នៅពេលដែលខ្មាំងមានប្រជាជន ខ្មាំងមានទាំងយោធា ខ្មាំងមានទាំងសេដ្ឋកិច្ច។ ពេលណាខ្មាំងមិនមានប្រជាជន ខ្មាំងមិនមានកងទ័ព ខ្មាំងមិនមានកម្លាំងកងទ័ព កម្លាំងសេដ្ឋកិច្ចទេ។ ហេតុផលរបស់យើងនេះត្រឹមត្រូវហើយ។ ដូច្នេះមាគ៌ារបស់យើងគឺត្រឹមត្រូវហើយ។

[០៩:៥៦:១៩]

យើងវាយប្រយុទ្ធដើម្បីដណ្តើមប្រជាជននៅគ្រប់ទីកន្លែងទាំងអស់។ ឧទាហរណ៍មួយ ការវាយនៅបាណាម នៅក្នុងឆ្នាំ១៩៧៣ យើងបានដណ្តើមប្រជាជនទាំងអស់នៅទីក្រុងបាណាម ដែលជនជាតិវៀតណាម ជនជាតិចិន យោធា នគរបាល យើងដណ្តើមយកអ្នកណាទាំងអស់គឺដើម្បីពង្រឹងប្រជាជនពីខ្មាំង។ ហើយកថាខណ្ឌខាងក្រោមមកទៀតនេះ និយាយឃ្លាថា "ដោយសារតែយើងដណ្តើមយកប្រជាជន នៅពេលដែលយើងទាញយកប្រជាជនអស់ហើយ ពេលនោះគឺគេលែងមានកម្លាំងអីតទៅទៀត

ហើយ។ ហើយឃ្លាចុងក្រោយនៃកថាខណ្ឌនេះ កត្តាដែលប្រកបដោយសេចក្ដីសម្រេចចិត្តក្នុងការទទួលជ័យជម្នះបាននោះ គឺយើងដណ្ដើមយកប្រជាជន។ ឧទាហរណ៍យើងរំដោះឧដុង្គនៅឆ្នាំ១៩៧៤ យើងទាញយកប្រជាជន" ហើយនៅទំព័រផ្នែកខាងក្រោមគឺថា "នេះគឺជាមាគ៌ាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការគ្រប់គ្រង និងក្នុងការដណ្ដើមប្រជាជន"។ បញ្ចប់ការដកស្រង់។

លោក ហេដឌ័រ លោកបានផ្ដល់សក្ខីកម្មហើយអំពីពាក្យថា "ពង្រឹងប្រជាជនពីខ្មាំង"។ ចុះថា "ដណ្ដើមប្រជាជន និងអូសទាញប្រជាជន" យោងទៅតាមអង្គហេតុជាក់ស្ដែងនៃកិច្ចសម្ភាសន៍របស់លោក ឬក៏ប្រភពអង្គហេតុពិតប្រាកដណាមួយ ដោយមិនត្រូវការស្មាន ឬផ្ដល់ជាមតិយោបល់អីនោះ តើឯកសារអង្គហេតុនេះដែលយោងទៅលើឃ្លាប្រយោគដែលខ្ញុំបានលើកឡើងពាក្យថា អូសទាញប្រជាជន រឹបអូសប្រជាជន អូសទាញប្រជាជន ឬពង្រឹងប្រជាជននេះ មានន័យថាដូចម្ដេចដែរ?

[០៩:៥៨:២១]

**ឆ៖** បាទ។

**ស៖** ខ្ញុំមានឯកសារហ្នឹងហើយ។ មានឯកសារនេះនិយាយការវាយនៅក្រុងបាណាម ខ្ញុំមិនដឹងថានៅត្រង់ណាទេ ប៉ុន្តែលោកថា លោកមកដល់នៅខែកញ្ញា ១៩៧៣ ដោយយោងទៅលើប្រភពនៃអង្គហេតុផ្ទាល់តែម្ដងដោយមិនត្រូវការផ្ដល់ជាការស្មាន ឬក៏គំនិតយោបល់មួយណា ដែលព័ត៌មានពិតនិយាយអំពីការពង្រឹងប្រជាជននៅបាណាម នៅឆ្នាំ១៩៧៣ ពីប្រភពផ្សេងៗជាជាងការយោងឯកសារដែលយើងយកមកកំពុងតែនិយាយនេះ។ សូមលោកបញ្ជាក់បន្តិច?

**ឆ៖** ខ្ញុំមិនបានដឹង។ ឯកសារនេះអត់មាននៅក្នុង*ហ្វាល* នៅក្នុងកម្រងឯកសាររបស់ខ្ញុំទេពេលនេះ។

**ស៖** ពាក់ព័ន្ធទៅនឹងសំណួរខ្ញុំខាងដើមនៃព័ត៌មានអង្គហេតុទៅលើឃ្លាថារឹបអូស ឬក៏អូសទាញប្រជាជន។ ចម្លើយលោក លោកឆ្លើយថា បាទ។ ថាតើនៅក្នុងឯកសារណាដែលមានព័ត៌មានអង្គហេតុអំពីការរឹបអូសប្រជាជន ឬការអូសទាញប្រជាជននោះ?

[០៩:៥៩:១៣]

**ឆ៖** ខ្ញុំសូមនិយាយអំពីការបកប្រែនៅក្នុងបរិបទនេះបន្តិចសិន។ ពាក្យថា "អូសទាញ" ដូចគ្នាទៅនឹងពាក្យថា "ដកចេញ"។ នេះគឺជាឧទាហរណ៍មួយនៃពាក្យអង់គ្លេសថា "*រីមូវ៉ល*" ហ្នឹងមិនមានចាំបាច់រហូតដល់ថាចាប់ខ្លួនឯណានោះទេ។ គឺថាឯពាក្យថា "*ស៊ីហ្សឺស*" គឺថាពាក្យថា រឹបអូសនេះ ខ្ញុំកំពុង

តែគិតថាតើ ខ្ញុំគិតថាបកប្រែពាក្យនេះ៤០ឆ្នាំហើយ ខ្ញុំនៅតែមិនទាន់មានចម្លើយ។ ខ្ញុំសូមផ្តល់ឧទាហរណ៍មួយដើម្បីលោកយល់។ នេះគឺកិរិយាស័ព្ទមួយដែលគេប្រើដើម្បីរៀបរាប់ថា កុមារពីរនាក់វាយគ្នាដើម្បីដណ្តើមនំមួយដុំ ហើយម្នាក់គឺថា ម្នាក់គឺវាយដើម្បីដណ្តើម ដណ្តើមយកនំហ្នឹង ឬខ្លាំងពីរនាក់ ឬក៏រដ្ឋបាលនយោបាយពីរ វាយដើម្បីដណ្តើមគ្នាគ្រប់គ្រង ការគ្រប់គ្រងផ្នែកខាងរដ្ឋបាល ឬក៏អាចប្រើប្រាស់យោងទៅលើបូរណភាពដែនដីក៏ថាបានដែរ។ ហើយបើមើលទៅលើឃ្លាខាងក្រោមនោះ -- ឃ្លាហ្នឹងចង់និយាយពីវាយដណ្តើមប្រជាជន វាជាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងប្រជាជន និងដណ្តើមប្រជាជន។ នេះគឺន័យដូចគ្នាទេ។

[១០:០១:១៧]

ខ្ញុំមានបញ្ហាបន្តិចពាក់ព័ន្ធទៅនឹងការបកប្រែភាសាទៅជាខ្មែរ ពីពាក្យអង់គ្លេសនូវពាក្យថា *"កុងត្រូល"* នេះ គឺត្រួតត្រា។ មានន័យថា ក្តាប់ ក្តោបក្តាប់ វាមានន័យខុសៗគ្នា អាស្រ័យទៅលើបរិបទនីមួយៗ ថាតើពាក្យ *"ក្រោប"* នេះ គឺក្តោក្តាប់នៅក្នុងដៃតែម្តង។ ហើយក៏យើងប្រើពាក្យថា ក្តោបក្តាប់នេះ ក្តោបក្តាប់ដោយតាមបញ្ញាស្មារតីតែម្តង ក្តោបក្តាប់តាមរយៈខួរក្បាលរបស់យើង។ ដូចជាមាគ៌ានយោបាយ ក្តោបក្តាប់មាគ៌ានយោបាយ។ ឯពាក្យថា *"កុងត្រូល"* ជាពាក្យថាត្រួតត្រានេះ ខ្ញុំនិយាយដោយន័យថាត្រង់ ន័យអត្ថន័យរូបតែម្តង។ ហើយឃ្លាដទៃទៀត ដែលមានពាក្យហ្នឹង គឺថាគេប្រើប្រាស់ជាញឹកញាប់នៅក្នុងការផ្សព្វផ្សាយនៅតាមវិទ្យុនៅពេលនោះ។ ខ្ញុំច្បាស់ណាស់ថា គេប្រើនៅក្នុងឯកសារបក្សនាពេលនោះ ទោះជាចាំ៧៥ ទៅដល់៧៩ក្តី ហើយក៏បានប្រើប្រាស់ជាញឹកញាប់នៅពេលនិយាយជាមួយប្រជាជននៅមុនឆ្នាំ៧៥ជាដើម។ល។ ជាពាក្យពេចន៍ទូទៅហើយ ដែលគេប្រើជាទូទៅជាញឹកញាប់ហើយ។

[១០:០២:៥១]

**ស៖** សូមអរគុណ។ ខ្ញុំសូមបង្ហាញជូនឯកសារ *ថេប៤* គឺE3/1108 ជារបាយការណ៍។ ខ្ញុំសូមអានចំណងជើងនៃរបាយការណ៍នេះជូនលោក។ របាយការណ៍ កម្មវត្ថុ "កិច្ចប្រជុំដើម្បីអបអរសាទរទិវាខួបលើកទី២៣។ នេះជាសុន្ទរកថារបស់ ហ៊ូ យន់ នៅថ្ងៃទី៣០ កញ្ញា ៧៤ គណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជា គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានប្រមូលផ្តុំដើម្បីអបអរសាទរ ទិវាខួបលើកទី២៣នៃប្រវត្តិសាស្ត្រ នៃចលនាតស៊ូនៅស្រុកអមលាំង។ ព្រឹត្តិការណ៍នេះ មានរៀបចំឡើងដោយមានការចូលរួមពីសំណាក់ប្រជាជននៅក្នុងក្របខ័ណ្ឌខ្មែរក្រហម។ សមាជិកបក្ស និងប្រជាជន និងកង

ទ័ពរំដោះជាតិប្រជាជនមកពីគ្រប់ទីកន្លែង ដែលទាំងអស់គ្នាស្លៀកពាក់សុទ្ធតែខោអាវពណ៌ខ្មៅ"។ ប្រភពអង្គហេតុ សូមឲ្យលោកបង្ហាញប្រភពឯកសារនេះ ដោយយោងទៅលើកិច្ចសម្ភាសន៍តែម្តង។ សូមលោកកុំស្មាន ឬក៏កុំផ្តល់មតិ ថាតើទិវារំឭកខួបលើកទី២៣នៃប្រវត្តិចលនាតស៊ូដែលធ្វើឡើងនៅស្រុកអមលាំងហ្នឹង គឺលោកមានប្រភពព័ត៌មានមកពីណា?

**ឆ៖** វាហាក់បីដូចជាពាក្យដែលគេនិយាយពីរឿងរ៉ាវពីមាត់មួយទៅមាត់ ដែលផ្តល់ឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ បាទនៅពេលដែលគេរៀបចំនៃមីទិញ ហើយពាក្យពេចន៍ទាំងអស់នេះ គឺត្រូវកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រើនៅពេលហ្នឹង។ កាលបរិច្ឆេទគឺថា ជាការកំណត់ឡើងដោយបក្សតែម្តង គឺឆ្នាំ៧៤។ លោកសុំ។ -- ខ្ញុំមិនចង់បង្ហាញលោកនាំមុខលោកទេ ប៉ុន្តែថាតើវាអាច៧៣ ឬ៧៤ ឬយ៉ាងណា?

[១០:០៥:៤២]

**ឆ៖** បាទ ៥១។

**ស៖** ខ្ញុំសូមបង្ហាញលោកនៅទំព័រ៦នៃឯកសារដដែលនេះ។ ERN ជាភាសាអង់គ្លេស 0058 3824, ខ្មែរ 00383763, និងបារាំង 00788356។ បាទសូមដកស្រង់ ក្រោយមក នេះគឺយោងទៅលើសុន្ទរកថារបស់ ហ៊ូ យន់ នៅត្រង់ទំព័រ៦នៃឯកសាររបស់លោកនៅផ្នែកខាងក្រោមទំព័រ៦។ "ក្រោយមកអង្គការបានអនុវត្តផែនការដោយយោងទៅតាមពាក្យស្លោកថា ទី១ត្រូវវាយប្រយុទ្ធតាមជនបទ។ ហ៊ុមព័ទ្ធទីក្រុងនៅដំណាក់ -- ឡោមព័ទ្ធទីក្រុងដំណាក់ទី២ ដើម្បីទទួលជ័យជម្នះជាបន្តបន្ទាប់ ហើយនៅឆ្នាំ៧១ អង្គការបានសម្រេចអនុវត្តដែលកម្មាភិបាលទាំងអស់ត្រូវចាកចេញពីកងទ័ព
វៀតណាមទាំងអស់គ្នាតែម្តង"។ សំណួររបស់ខ្ញុំសួរថា យោងតាមព័ត៌មានពីអង្គហេតុ ថាតើមានការយោងឯកសារពាក់ព័ន្ធទៅនឹងផែនការដែលមានពីរដំណាក់កាល ទី១វាយតាមទីជនបទ, ទី២ ឡោមព័ទ្ធទីក្រុង។ សូមលោកបញ្ជាក់បន្តិច?

**ឆ៖** នេះគឺជាព័ត៌មានបែបក្លាស៊ីកនៅក្នុងកុម្មុយនីស្តចិនដែលខ្មែរក្រហមអនុវត្ត។ មានន័យថាខ្ញុំកំពុងតែនៅ -- វានៅចុងមាត់របស់ខ្ញុំ។ ជាឯកសារដែលបក្សកុម្មុយនីស្តកម្ពុជាបានយកមកយោង ប៉ុន្តែខ្ញុំគ្មានស្អីភ្ជាក់ផ្អើលទេ បើសិនណាជាវាមិនដូច្នេះទេ។

**ស៖** ឯកសារ *ថេប៥* យើងចូលទៅឯកសារ E3/118។ ERN ជាភាសាអង់គ្លេស 00166994, បារាំង 00845854 ដល់ 55, និងខ្មែរ 00846160 ដល់ 61។ នេះជាឯកសារដែលផ្សព្វផ្សាយតាមរយៈ

*ហ្វីប៊ីស* ចុះឆ្នាំ៧៥ សម្រង់ដែលមានចំណងជើងថា៖ "ខៀវ សំផន: ថ្ងៃទី២១ -- សារ ចុះថ្ងៃទី២១ និយាយពីជ័យជម្នះ សេវាផ្សព្វផ្សាយទីក្រុងភ្នំពេញ ក្នុងប្រទេសកម្ពុជានៅថ្ងៃ២១ ខែមេសា"។ ជាសេចក្តីថ្លែងការណ៍អបអរសាទរដោយឧបនាយករដ្ឋមន្ត្រីនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះជាតិកម្ពុជា និងប្រជាជនកម្ពុជា ដែលបានផ្សព្វផ្សាយដោយផ្ទាល់ និងបានកត់ត្រា។

[១០:០៩:៣៥]

កថាខណ្ឌទី៣ នៃសម្រង់សុន្ទរកថានេះ ខ្ញុំសូមដកស្រង់តែម្តង៖ "នេះគឺជាជ័យជម្នះប្រវត្តិសាស្ត្រមហាធំធេងរបស់ប្រជាជននិងប្រជាជាតិយើង។ ប្រជាជាតិយើងទាំងមូល និងកងទ័ពរំដោះជាតិកម្ពុជាក៏ដូចជាប្រជាជននៅនៅទូទាំងពិភពលោក និងបណ្តាប្រទេសជាមិត្តទាំងអស់ ទាំងជិត ទាំងឆ្ងាយ បានស្វាគមន៍មហាជ័យជម្នះនេះយ៉ាងកក់ក្តៅបំផុត។ នេះគឺជាការបើកឡើងនូវមាគ៌ាប្រកបទៅដោយភាពត្រឹមត្រូវ និងអនុញ្ញាតឲ្យប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិកម្ពុជានៅក្នុងការបង្កសង្គ្រាមប្រយុទ្ធជាមួយខ្មាំង ទាំងផ្នែកកងទ័ព ទាំងផ្នែកនយោបាយ ទាំងផ្នែកសេដ្ឋកិច្ច និងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងប្រជាជនចេញពីតំបន់ដែលគ្រប់គ្រង ហើយបានកម្ទេចខ្មាំងយ៉ាងជោគជ័យ ហើយយើងបានវាយប្រយុទ្ធឥតនឿយណាយ និងបានធ្វើឲ្យខ្មាំងរឹងស្ងួតទាំងផ្នែកនយោបាយ យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ ហើយនិងមិនមានទាំងស្បៀងអាហារ ស្រូវ អង្ករ រហូតដល់ចុងបញ្ចប់ខ្មាំងបានងាប់យ៉ាងកំសាក"។

បាទ នៅក្នុងឯកសារនេះ គឺលោកបានចាកចេញពីភ្នំពេញនៅមុនថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ តើលោកបានឮសូរការផ្សព្វផ្សាយនៅពេលនុ៎ងដែរឬទេ? ឬក៏មានឯកសារយោងណាមួយដែលផ្សព្វផ្សាយដោយ ខៀវ សំផន នោះដែរឬទេ?

[១០:១១:២៥]

**ឆ៖** ការផ្សាយនេះគឺបាន -- គឺបានខ្ញុំស្តាប់ឮនៅថ្ងៃទី២១ ខែមេសា ឆ្នាំ៧៥ ខ្ញុំបានស្តាប់ឮការផ្សាយនេះ។ ការចែកចាយឯកសារហ្វីប៊ីសនេះ ជាការពិតទៅគឺវាបានធ្វើជូនទៅកាន់ស្ថានទូតអាមេរិកនៅបាងកក រួមទាំងស្ថាប័នផ្សេងទៀត ហើយការបកប្រែនេះធ្វើឡើងដោយហ្វីប៊ីសតាមរយៈការផ្សព្វផ្សាយ។ ខ្ញុំជាការពិត ខ្ញុំបានធ្វើការតាមដានការផ្សព្វផ្សាយនៅទីក្រុងភ្នំពេញ ហើយខ្ញុំក៏បានទៅតាមនៅទីក្រុងបាងកកផងដែរ។ ដូច្នេះហើយ វាទំនងដែលថាខ្ញុំបានឃើញការផ្សព្វផ្សាយនេះនៅទីក្រុងបាងកកនៅក្នុងឆ្នាំ១៩៧៥ ខែមេសា។

**ស៖** ខ្ញុំនឹងលើកចំណុចនេះសាជាថ្មី ដោយសារពេលនេះខ្ញុំគិតថាមិនសមនឹងលើកឡើងបញ្ហានេះទេ។ បណ្ណសារនៅក្នុងទីក្រុងភ្នំពេញនោះត្រូវបានគេលុកលុយ រួមទាំងបណ្ណសារនៅទីក្រុងបាងកកផង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ជាការពិត។

**ស៖** សូមពន្យល់ មិនមែនរឿងរ៉ាវដោយផ្ទាល់ពីសម័យនោះទេ ក៏ប៉ុន្តែសូមឲ្យលោករៀបរាប់លោកទៅណាដែរ? លោកថាចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១១ ខែមេសា ត្រឹមត្រូវដែរឬទេ? លោកឆ្លើយថា ត្រឹមត្រូវ។ ចាប់ពីថ្ងៃ១១ ខែមេសា ឆ្នាំ៧៥ រហូតទៅដល់ចុងឆ្នាំ៧៥ តើលោកនៅម្ដុំណា? តើការចាប់អារម្មណ៍អ្វីដែលឲ្យលោកនៅប្រទេសកម្ពុជា? ហើយលោកទទួលបានឯកសារព័ត៌មានទាំងអស់នេះដោយរបៀបណាដែរ?

[១០:១៣:២២]

**ឆ៖** ខ្ញុំបានហោះចាកចេញពីប្រទេសកម្ពុជានៅថ្ងៃព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ៧៥។ យន្តហោះមកកាន់ទីក្រុងភ្នំពេញនោះ គឺមិនអាចចូលមកបានទេ។ ដូច្នេះហើយខ្ញុំដែលចង់ទៅទីក្រុងបាងកកនោះខ្ញុំបានទៅតាមរយៈព្រំដែនកម្ពុជា-បាងកក ហើយខ្ញុំបានទៅដល់ព្រំដែនថៃ-កម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ហើយមកត្រឹមថ្ងៃ១៥ ខែមេសា នេះគ្មានជើងហោះហើរណាអាចហោះចេញពីទីក្រុងភ្នំពេញនោះទេ។ ការកិច្ចសម្ភាសន៍គឺថា មនុស្សនោះក៏បានរត់ចេញពីព្រំដែនថៃ ខ្ញុំក៏បានជួប ហើយប្រហែលជាក្នុងឧសភា ឆ្នាំ៧៥ នោះគឺថាខ្ញុំចាំមិនខុស គឺថាខ្ញុំធ្វើដំណើរទៅប្រទេសឡាវ។ ខ្ញុំបាននៅប្រទេសឡាវនោះប៉ុន្មានខែ។ ហើយបន្ទាប់មកចេញពីឡាវ ខ្ញុំទៅតៃវ៉ាន់រហូតទៅដល់ពាក់កណ្ដាលឆ្នាំ រហូតដល់ពាក់កណ្ដាលឆ្នាំ៧៥ គឺថាខ្ញុំរាយការណ៍ពីតៃវ៉ាន់ ហើយក៏ខ្ញុំក៏បានធ្វើសិក្សាបញ្ហាចិននេះផងដែរ។ បន្ទាប់មកខ្ញុំត្រឡប់ទៅខូណែល បន្តការសិក្សាថ្នាក់ក្រោយឧត្ដមសិក្សារបស់ខ្ញុំ។ ហើយគឺវគ្គនោះ គឺថាខ្ញុំសិក្សាវគ្គវិទ្យាសាស្ត្រនយោបាយ។

ខ្ញុំទៅដល់មហាវិទ្យាល័យនៅខូណែលនៅ ខេណេធិខាត់ នេះក្នុងខែកញ្ញាឆ្នាំ៧៥។ ខ្ញុំសូមរំឭកអំពីសាកល វិទ្យាល័យ ខូណែល ខែកញ្ញា ឆ្នាំ៧៥។ លោកបានទៅដល់ ខូណែលនោះ តើលោកអាចពន្យល់ដែរឬទេ ថាលោកនៅទីនោះចាប់ពីខែកញ្ញាដល់ឆ្នាំ៧៦ ឬក៏ដល់ឆ្នាំណា? ក៏ប៉ុន្តែប្រសិនជាលោកនៅទីនោះ តើលោកបានទទួលព័ត៌មានទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យតាមរយៈណាដែរ ឯកសារសិក្សាស្រាវជ្រាវសារព័ត៌មាន ឬក៏តាមវិទ្យុ។ តើលោកបានបន្តការតាមដានព័ត៌មាន និងទទួលបាន

ព័ត៌មានពីប្រទេសកម្ពុជា តាមរបៀបណាដែរក្នុងខណៈពេលលោកនៅក្នុង នៅឯ ខូណែល ឯណោះ ចាប់ពីខែកញ្ញា ឆ្នាំ៧៥ ទៅនោះ។

[១០:១៥:៤៨]

**ឆ:** ចម្លើយគឺថា ខ្ញុំពិបាកណាស់នាពេលនោះទទួលព័ត៌មាន។ វាពិបាកក្នុងការទទួលយក ហ្វេស.ប៊ី.អាយ.អេស – សារព័ត៌មានហ្វ៊ីប៊ីស តាមរយៈ*យេឡូផេច* ហើយខ្ញុំក៏បានទៅបណ្ណាល័យរបស់ខេន័រ(?) ដែលក្នុងនោះគេចងក្រងជាសារព័ត៌មានលម្អិត ផ្តោតសំខាន់ទៅលើតំបន់ អាស៊ីជាពិសេសតំបន់អាស៊ីអាគ្នេយ៍ ហើយវាបានផ្សព្វផ្សាយផ្ទាល់ផងដែរ ហើយខ្ញុំបានតាមដានព័ត៌មានទាំងអស់តាមរយៈសារព័ត៌មាន ខ្ញុំបាន ខ្ញុំមានទំនាក់ទំនងមួយចំនួនជាមួយនឹងអ្នកសារព័ត៌មាន អ្នកកាសែតដែលផ្សាយអំពីបញ្ហាប្រទេសកម្ពុជាពួកគេនៅប្រទេសថៃ។ ខ្ញុំក៏មានទំនាក់ទំនងជាមួយមន្ត្រីសហរដ្ឋអាមេរិកបច្ចុប្បន្ន និងកាលពីមុនផងដែរ ទោះបីជានៅក្នុងប្រទេសថៃ ពួកគេនៅប្រទេសថៃក៏ដោយ។ ហើយជាពិសេសខ្ញុំអាចទាក់ទងជាមួយអ្នកដែលចូលរួមពាក់ព័ន្ធជាមួយនឹងការងាររបស់ប្រទេសកម្ពុជាព័ត៌មានទាំងអស់មួយចំនួនចេញមកពីអ្នកទាំងអស់នោះ។ ខ្ញុំក៏បានពិភាក្សាលម្អិតយ៉ាងយូរផងដែរ ជាមួយនឹងគណៈប្រតិភូបក្សកុម្មុយនីស្ត អាមេរិក ម៉ាក្ស-ឡេនីន ផងដែរ ដែលគាត់មកប្រទេសកម្ពុជា នៅពាក់កណ្តាលឆ្នាំ១៩៧៨។ ខ្ញុំក៏បានទាក់ទងជាមួយនឹង ដាច់មិន និង បេកឃ័រ ដែលមកប្រទេសកម្ពុជានៅចុងឆ្នាំ៧៨ ហើយនៅចុងឆ្នាំ៧៨ទៀតសោត ខ្ញុំបានជួបទាក់ទងដោយផ្ទាល់ជាមួយនឹងមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យដោយផ្ទាល់ ក្នុងនោះរួមមានលោក អៀង សារីដែលបានធ្វើដំណើរមកសហរដ្ឋអាមេរិកទីក្រុងញូវយ៉ក ចូលរួមជាមួយនឹងមហាសន្និបាតអង្គការសហប្រជាជាតិ។ នាពេលនោះ ខ្ញុំបានជួបគាត់ហើយគាត់ក៏បានអមដំណើរជាមួយនឹងសមមិត្តរបស់គាត់នៅក្នុងក្រសួង រួមទាំង អ៊ិន លន ហៅ ណាត ហើយគឺខ្ញុំនិយាយផងដែរ គឺថានៅក្នុងឆ្នាំ៧៤នោះគឺថា ខ្ញុំក៏បានធ្លាប់ជួបគាត់។ យើងបានជួបគ្នានិងពិភាក្សា ហើយគេបានរៀបចំឲ្យយើងខ្ញុំនេះជួបជាមួយគាត់ រួមទាំងអ្នកផ្សេងក៏អាចជួបគាត់ផងដែរជាមួយអ្នកសិក្សាស្រាវជ្រាវអ្នកសារព័ត៌មាន អ្នកដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ហើយក្រោយមក គេរៀបចំកិច្ចធ្វើដំណើរទស្សនកិច្ចរបស់យើងខ្ញុំទៅប្រទេសកម្ពុជានៅក្នុងឆ្នាំ៧៩។ ក៏ប៉ុន្តែគណៈប្រតិភូគឺបានធ្វើដំណើរទៅប៉េកាំង ដែលក្នុងឆ្នាំ៧៩នោះ មានការលុកលុយពីវៀតណាមខ្លាំងក្លា ហើយយើងខ្ញុំក៏បានធ្វើការទាក់ទងជាមួយនឹងអគ្គរដ្ឋទូតនៅទីក្រុងប៉េកាំងផងដែរ។ គាត់បានពន្យល់ប្រាប់យើងខ្ញុំថាវៀតណាមកំពុងតែប៉ុនប៉ងក្តាប់យកទីក្រុងភ្នំពេញ។ ហើយគេឲ្យយើងចាំបន្តិចសិនរហូតដល់

ពេលរបបកម្ពុជាប្រជាធិបតេយ្យនោះបណ្តេញវៀតណាមចេញពីប្រទេសកម្ពុជា។ មួយភ្លែតរបស់គេហ្នឹងគឺ យើងដឹងហើយ មិនដែលកើតឡើងទេ គឺគេមិនបានបណ្តេញវៀតណាមចេញនោះឡើយ។ បន្ទាប់មកពីប៉ៃកាំង ខ្ញុំបានទៅកាន់ទីក្រុងបាងកក ហើយខ្ញុំមកព្រំដែនកម្ពុជាថៃ នៅទីនោះហើយដែលខ្ញុំបានពិភាក្សាជួបជាមួយបុគ្គលមួយចំនួន ហើយក្រោយមកខ្ញុំបានធ្វើដំណើរចូលមកក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ នៅចុងរបបរបស់កម្ពុជាប្រជាធិបតេយ្យនៅដើមឆ្នាំ១៩៧៩។

[១០:២០:០២]

**ស៖** នៅក្នុងចម្លើយរបស់លោក លោកនិយាយអំពីឈ្មោះ អ៊ិន លន ហៅណាត។ តើគាត់ហ្នឹងមានតួនាទីអ្វី?

**ឆ៖** គាត់ហ្នឹងគឺកម្មាភិបាលល្បីមួយរូបនៅក្នុងភូមិភាគពិសេស។ គាត់ហ្នឹង និងកងកម្លាំងរបស់គាត់ហ្នឹងគឺថានៅតំបន់ពិសេស ប៉ុន្តែគាត់មិនបានចូលមកទីក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៥នោះទេ។ មុនដំបូងគាត់ចូលមកទីក្រុងភ្នំពេញក្នុងនាមជាប្រធានស-២១។ ហើយគាត់ក៏មានតួនាទីជាអ្នកនៅក្រោម សុន សេន នៅក្នុងសេនាធិការផងដែរ។ ហើយក្រោយមកនៅចុងឆ្នាំ៧៨ គឺគាត់ត្រូវបានគេបញ្ជូនជាមួយនឹងអ្នកដែលនៅក្នុងសេនាធិការផ្សេងទៀតឲ្យធ្វើការនៅក្រសួងការបរទេស។ ហើយទំនងជាអ្នកទាំងអស់នោះ ឬក៏មិនទំនង អ្នកទាំងអស់នោះដែលត្រូវបានគេសម្លាប់ចោលនៅក្នុងចុងឆ្នាំ៧៨ ដើមឆ្នាំ៧៩។

[១០:២១:០៨]

**ស៖** ខ្ញុំសូមឲ្យលោកមើលសំណុំឯកសារទី៥ សូមឲ្យលោក អ៊ីនឌិច លិបិក្រម សំណុំឯកសារលេខ៥នេះនៅទំព័រខាងមុខ លោកនឹងបានឃើញចំណុច៦ ទៅដល់១១។ នៅក្នុងនោះមានឯកសារ "នូវែល ឌុយ កាំបូដស៍" ដែលជាឯកសារបោះពុម្ពផ្សាយសារព័ត៌មាន។ ជាដំបូង ខ្ញុំសូមឲ្យលោកពិនិត្យមើលជាមុន។ ខ្ញុំនឹងបង្ហាញលោកនូវចំណុចប្រាំមួយ គឺថេប៦ ឯកសារ E3/1238។ លោក ហេដឌ័រ តើលោកអាចបញ្ជាក់បានដែរឬទេ លោកមានឯកសារហ្នឹងជាភាសាអង់គ្លេស និងបារាំង មែនដែរឬទេ?

ពាក់ព័ន្ធទៅនឹងឯកសារជាភាសាបារាំង យើងមានចំណងជើងដាក់ថា "នូវែល ឌុយ កាំបូដស៍"។ ឯកសារ E3/1238 គឺចុះខែមីនា ចុងខែមីនា ឆ្នាំ១៩៧៤ រហូតទៅដល់ខែមេសា។ នៅទំព័រខាងមុខទំព័រអង់គ្លេស គឺសូមឲ្យលោកពិនិត្យមើល ERN ជាភាសាអង់គ្លេសគឺ 00278739។ គឺសារថ្លែងនៅក្នុងថ្ងៃ២៧ ខែមីនា ពីសម្តេច នរោត្តម សីហនុ អបអរសាទរដល់លោក ខៀវ សំផន នៅក្នុងទស្សនកិច្ចរបស់--ក្នុងមិត្តភាពនៅក្នុងប្រទេសវៀតណាម។ "ខ្ញុំរីករាយណាស់ដែលលោកបានមកដល់ដោយជោគជ័យ នៅ

សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ហើយនៅពេលនេះ ខ្ញុំសូមធ្វើការសាទរចំពោះអៀង សារី, អៀង ធីរិទ្ធ ដែលទទួលជោគជ័យនៅក្នុងបេសសកម្មរបស់អស់លោក។ ការធ្វើទស្សនកិច្ចនៅក្នុងប្រទេសវៀតណាម និងប្រទេសកូរ៉េខាងជើងនាពេលខាងមុខ រួមទាំងប្រទេសចិន”។

នៅពេលនេះ ខ្ញុំសូមសួរលោក តើការទស្សនកិច្ច និងការអបអរសាទរនេះ នៅចុង -- នៅដើមខែមេសា ឆ្នាំ៧៥នោះដែរឬទេ? តើនៅពេលនោះ គណៈប្រតិភូដឹកនាំដោយ ខៀវ សំផន អៀង សារី បានធ្វើទស្សនកិច្ចទៅតាមបណ្តាប្រទេសមួយចំនួន។ តើអ៊ីចឹងដែរឬទេ?

[១០:២៣:៤៧]

**ឆ៖** ជាការពិត តាមឯកសារ ហ្វីប៊ីស អាប៊ុលឡាទីន នោះគឺថា គឺបានបង្ហាញដូច្នោះមែន។

**ស៖** ខ្ញុំមិនចូលទៅដល់ឯកសារទាំងអស់នេះ ដោយសារយើងមិនមានពេលវេលាគ្រប់គ្រាន់។ សូមលោកឲ្យមើលថេប៩ សំណុំឯកសារដដែលទេ ក៏ប៉ុន្តែថេប៩។ ថេប៩ ឯកសារលេខ E3/114 ទំព័រដែលខ្ញុំសូមពិនិត្យមើល គឺទំព័រ៧ ឯកសារដែលលោកមាននៅក្នុងដៃនេះជាភាសាអង់គ្លេស។ ERN គឺ00278056, បារាំងមានលេខ 00000093 ទៅដល់ 94, ខ្មែរមានលេខ 00662258។ មានចំណុចដកស្រង់ដូចរៀបរាប់ដូចតទៅ ក្រោមចំណងជើងថា៖ “ពួកក្បត់ភ្នំពេញត្រូវបានបំផ្លាញ និងខកចិត្តទាំងស្រុង ហើយជាពិសេសនៅលើសមរភូមិជួរមុខទាំងអស់”។

ចំណុចដកស្រង់នេះ ខ្ញុំសូមលើកឡើងដូចតទៅ៖ “ប៉ុន្តែនៅពេលដែលពួកគេបានរំដោះភ្នំពេញ កងទ័ពរំដោះកម្ពុជាបានធ្វើការវាយប្រហារនៅថ្ងៃទី១៤ ខែមីនា ប្រឆាំងនៅតាមកោះតាង និងនៅតាមដងទន្លេមេគង្គ ប្រហែលជា១គីឡូម៉ែត្រពីព្រះបរមរាជវាំងក្រុងភ្នំពេញ ក្នុងរយៈពេល១យប់១ថ្ងៃ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានរំដោះកោះទាំងនេះ ហើយកម្ទេចកងវរសេនាតូចរបស់ខ្មាំងបានមួយ និងបានជួយនាំប្រជាជនចំនួន៥ម៉ឺននាក់ទៅតំបន់រំដោះ”។ លោក ហេងឌ័រ ខ្ញុំសូមសួរឡើងវិញ នៅថ្ងៃ១៤ ខែមីនា ឆ្នាំ៧៤ តើលោកនៅចាំដែរឬទេ ហេតុការណ៍ដែលបើកការវាយលុកនៅទីតាំងកោះដាច់ ខ្សាច់កណ្តាល និងកោះឧញ៉ាតីលើទន្លេមេគង្គនោះ តើនេះជាអង្គហេតុដែលគេរៀបរាប់ពិតប្រាកដដែរឬទេក្នុងពេលនោះ?

[១០:២៦:៣៧]

**ឆ៖** ខ្ញុំមិនចាំហេតុការណ៍នេះ ជាក់លាក់នោះឡើយ។

**ស៖** នៅត្រង់ទំព័រដដែល ខ្ញុំសូមអានតទៀត “មួយថ្ងៃបន្ទាប់នៅថ្ងៃ១៥ ខែមីនា កងទ័ពប្រជាជន

រំដោះជាតិកម្ពុជាបានវាយប្រហារជាថ្មីម្តងទៀតយ៉ាងខ្លាំង និងដោយមិនឲ្យខ្មាំងដឹងមុននៅក្រុងឧដុង្គ។ ថ្ងៃទី១៨ ខែមីនា ៧៤ កងទ័ពប្រជាជនរំដោះកម្ពុជាបានរំដោះឧដុង្គទាំងស្រុង។ កងពលខ្មាំងត្រូវបានកម្ទេចហ្មត់ ហើយប្រជាជនចំនួន៣០.០០០នាក់នៃក្រុងនេះ និងតំបន់នៅជុំវិញ បានទៅដល់តំបន់រំដោះដោយជោគជ័យ។ ទាល់តែកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបំផ្លាញទាំងស្រុងនូវប្រព័ន្ធទីតាំងរដ្ឋអំណាចរដ្ឋបាល ជំរំឃុំឃាំង មជ្ឈមណ្ឌលសន្តិភាព នៅក្រុងឧដុង្គរួចហើយ ទើបពួកអាក្បត់ប្រញាប់ប្រញាល់បញ្ជូនកម្លាំងជំនួយដើម្បីដណ្តើមយកក្រុងឧដុង្គវិញ។ ប៉ុន្តែកម្លាំងជំនួយនេះ ត្រូវបានកម្ទេចយ៉ាងដំណំ និងសម្លាប់ជាច្រើននាក់”។ បញ្ចប់ការដកស្រង់។

សំណួរទី១ សួរ ខ្ញុំសួរពាក់ព័ន្ធទៅនឹងទីតាំងដែលលោកបានដឹងនាសម័យនោះ។ តើកងកម្លាំងរបស់ខ្មែរមុនពេលដែលវាយប្រហារនោះ តើពួកគេឈរនៅលើទីតាំងណាដែរ? ហើយព័ត៌មានដែលលើកឡើងនៅក្នុងនេះ គឺវាដូចទៅអង្គហេតុការពិតជាក់ស្តែងដែលលោកបាននាពេលនោះ ហើយនិងអង្គហេតុការណ៍ពិតដែលលោកបានដឹងនាក្រោយមកដែរឬទេ?

[១០:២៨:២៣]

**ឆ៖** ខ្ញុំមិនអាចនិយាយថា ខ្ញុំបានដឹងអំពីការបញ្ជារបស់ខ្មែរក្រហមវាយលុកទីតាំងនោះទេ ជាពិសេសទីតាំងជាក់លាក់ដូចដែលលោកបានលើកឡើង។ ខ្ញុំគ្រាន់តែអាចលើកបញ្ជាក់ថា នៅពេលប្រៀបធៀបជាមួយនឹងការផ្សព្វផ្សាយនៅក្នុងវិទ្យុ ហើយនិងការកត់ត្រានៅក្នុងនេះ ខ្ញុំបានឃើញនៅពេលនោះ ហើយគេក៏បានប្រាប់ខ្ញុំនៅក្នុងពេលដែលពួកគេនៅក្នុងសមរភូមិនោះផងដែរ។ ហេតុការណ៍មួយចំនួន គឺបានធ្វើឡើងតាមវិទ្យុផ្សព្វផ្សាយ ក៏ប៉ុន្តែហេតុការណ៍នោះ គឺថាពេលខ្លះទៅ មិនបានកើតឡើងនោះទេ។

**ស៖** នៅក្នុងនេះ គឺគេលើកឡើងអំពីជំរំឃុំឃាំង។ ប្រហែលជាលោកមិនចាំទេ។ នៅក្នុងថ្ងៃទី១ យើងនិយាយអំពីកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំគិតថាលេខយោង៨៣ ក្នុងលេខយោងជើងទំព័រ៨៣នោះ យោងទៅលើរបាយការណ៍ សេ.អ៊ី.អា របស់អាមេរិក ពាក់ព័ន្ធទៅនឹងជំរំឃុំឃាំងនៅខេត្តសៀមរាប។ នៅពេលនេះ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ពាក់ព័ន្ធនឹងអង្គហេតុដែលលោកបានដឹងដោយផ្ទាល់ កុំស្មាន ហើយកុំផ្តល់ជាមតិយោបល់។ តាមប្រភពអង្គហេតុជាក់ស្តែងដែលលោកបានដឹង តើមានជំរំឃុំឃាំងបានបង្កើតឡើងដែរឬទេ នៅមុនឆ្នាំ១៩៧៥?

**ឆ៖** សាធារណរដ្ឋខ្មែរបានបន្តបើកប្រតិបត្តិការមន្ទីរឃុំឃាំង ហើយនិងមានកន្លែងឃាត់ខ្លួនរបស់នគរបាលនៅក្នុងទីក្រុងភ្នំពេញ និងនៅតាមទីជនបទមួយចំនួន។ ពេលខ្លះទៅ គឺមានមន្ទីរឃុំឃាំងរបស់

ខាងយោធាបណ្ដោះអាសន្នផងដែរ ដែលគេបង្កើតឡើងនៅតាមទីតាំងក្រៅទីក្រុងភ្នំពេញ និងតាមទីរួមខេត្ត ក៏ប៉ុន្តែខ្ញុំគិតថាការចងចាំរបស់ខ្ញុំនេះវាអាចមិនបានគ្រប់ជ្រុងជ្រោយ និងវាមាននៅចំណុចខ្វះខាតផងដែរ។

[១០:៣០:៤៥]

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាឥឡូវដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញវិញ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ដោយមានសំណើសុំបន្ថែមពេលវេលាក្នុងការសួរដេញដោលសាក្សីរូបនេះ ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញថាសំណួររបស់សហព្រះរាជអាជ្ញាមានភាពពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងការពិភាក្សាដេញដោលចំពោះសាក្សីរូបនេះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចផ្ដល់ពេលវេលាតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាគឺសហព្រះរាជអាជ្ញាមានពេលវេលាពេញមួយព្រឹកនេះ។ បានន័យថា មួយវគ្គនៃសវនាការនេះរហូតដល់ថ្ងៃសម្រាកថ្ងៃត្រង់។ ហើយចំណែកឯកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះនឹងផ្ដល់ជូនតាមសំណើសុំគឺរយៈពេលប្រហែលជា១ម៉ោង៣០នាទី។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោក ហេដឌ័រ សំណុំឯកសារលេខ៥ *ថេប*១0 គឺឯកសារ "នូវែល ឌុយ កាំបូដស៍" 12.7 នៅខាងស្តាំលេខវា ឯកសារ E3/167។ ឯកសារចេញមកពីឯកសារ "នូវែល ឌុយ កាំបូដស៍" ភ្នាក់ងារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ ឯកសារនេះលើកឡើងអំពីសុន្ទរកថាថ្លែងដោយ ខៀវ សំផន នៅប្រទេសកូរ៉េខាងជើង។

[១០:៥៣:១៧]

នៅពេលនេះលោក ហេដឌ័រ ខ្ញុំសូមឱ្យលោកមើលទំព័រចុងក្រោយ គឺទំព័រ 00280591 នៅខាងឆ្វេងខាងលើ ទំព័រចុងក្រោយជាភាសាអង់គ្លេស។ ERN ជាភាសាអង់គ្លេស 0028 -- សូមអធ្យាស្រ័យខ្ញុំមើលទំព័រខុសហើយលោក ហេដឌ័រ សូមអធ្យាស្រ័យ។ ទំព័រនោះគឺទំព័រនេះ គឺទំព័រ ERN ដែលមានលេខ 00280586, ខ្មែរ 00596141, S00000122។ យោងនៅក្នុងនេះសរសេរថា៖ "ផ្ទុយមកវិញកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានវាយខ្លាំងដោយកម្លាំងក្លាំងក្លាពេញលេញ ហើយនៅពេលនេះ គឺបានឈរជើងនៅច្រកទីក្រុងភ្នំពេញ។ ហើយនៅក្នុងទីក្រុងភ្នំពេញ ដែលជាជំរំលាក់ខ្លួនពួកក្បត់ចុងក្រោយបានក្លាយទៅជាសមរភូមិដ៏ឆេះសន្ធោសន្ធៅក្រោមការបង្កើនសំពាធរបស់ប្រជាជន របស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ នៅថ្ងៃ១៨ មីនា កងទ័ពប្រជាជនរំដោះជាតិកម្ពុជាយើងបានរំដោះឧដុង្គដោយផ្តាច់ផ្តិលកងទាហានអាយ៉ងនៅទីនោះ រួមជាមួយនឹងកងជំនួយរបស់ពួកវា។ បានន័យថាខ្មាំង ៥០០០ នាក់ត្រូវបានសម្លាប់ ក្នុងនោះមាន១.៥០០នាក់ត្រូវបានចាប់ខ្លួន"។

លោក ហេដឌ័រ នៅពេលនោះតើលោកមានដឹង អំពីបញ្ហាឧដុង្គ ឬក៏សុន្ទរកថាថ្លែងណាមួយដែលពាក់ព័ន្ធទៅនឹងឧដុង្គ ឬក៏ការនិយាយយោងណាមួយដោយមេដឹកនាំអំពីបញ្ហាឧដុង្គនេះដែរឬទេ? ក្រោយពីថ្ងៃ១៨ ខែមីនា ឆ្នាំ៧៤ក្រោយពីបញ្ហាឧដុង្គនេះ តើលោកបានដឹងដែរឬទេ?

[១០:៥៥:៥០]

**ផ៖** ខ្ញុំគិតថាខ្ញុំបានអានទៅក្នុង ប្លូប៊ូឡាទីន របស់ខាងហ្វីប៊ីសនោះ នៅពេលដែលខ្ញុំនៅទីក្រុងភ្នំពេញនាពេលនោះ។

**ស៖** នៅពេលនេះខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀត ដែលពាក់ព័ន្ធទៅនឹង *ថេប*១៤។ នៅក្រោយថេបនោះគឺថាមានឯកសារដកស្រង់ចេញពីឯកសារ E3/1815 គឺសៀវភៅសរសេរដោយ ប៉ែន យៀរនិន: "តើប៉ុលពតកាន់អំណាចដោយរបៀបណា?" យើងបានយោងទៅលើចំណុចដកស្រង់នេះ រួចមកហើយនៅក្នុងសៀវភៅ។ នេះគឺជាបុរេកថារបស់លោក ប៉ែន យៀរនិន ហើយនៅក្នុងនោះគឺលោកបានលើកឡើងថានៅក្នុងខែមិថុនា ឆ្នាំ៧៤ យោងតាមប៉ុលពតគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំ និងសម្រេចធ្វើការវាយសម្រុកខ្លាំងក្លាមួយដើម្បីរំដោះទីក្រុងភ្នំពេញ និងតំបន់ដទៃទៀត។ ចំណុចយោងនេះយោងទៅលើលេខយោងជើងទំព័រទីមួយ ហើយលេខយោងទីមួយនេះគឺបានយោងទៅលើឯកសារជាភាសាបារាំងដែលពាក់ព័ន្ធនឹងការរំឭកខួបបក្សកុម្មុយនីស្តកម្ពុជា ហើយការប្រកាសដោយ ប៉ុល ពត ធ្វើឡើងនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧។ លោក ហេដឌ័រ ខ្ញុំសូមសួរលោក ថាតើលោកបានឃើញឯកសារដើមដែរឬទេ? ឬក៏លោកបានដឹងអំពីលោក ប៉ុល ពត ដែលគាត់បានយោងអំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជានៅក្នុងខែមិថុនា ឆ្នាំ៧៤។ តើលោកបានដឹងដែរឬទេ?

[១០:៥៧:៤៥]

**ផ៖** ដឹង លើកលែងតែចំណុចមួយដែលខ្ញុំគិតថា គួរតែខ្ញុំមើលឯកសារជាភាសាខ្មែរសិនថាតើគេប្រើពាក្យខ្មែរជាក់ស្តែងនោះយ៉ាងម៉េច? ពាក្យថា "*ខំមីតធី*" គណៈកម្មាធិការនៅក្នុងនេះគឺថាអត់មានសរសេរនៅក្នុងនេះផង។

**ស៖** ខ្ញុំអត់មានឯកសារជាភាសាខ្មែរទេ ប៉ុន្តែឯកសារបន្ទាប់ក្រោយនេះដែលខ្ញុំគ្រោងហ្នឹងសួរនិងមានជាភាសាខ្មែរ។ សូមឱ្យលោកមើល *ថេប*១៥ ខ្ញុំសង្ឃឹមថាលោកមានឯកសារជាភាសាអង់គ្លេសនិងខ្មែរផងដែរ។ សូមឱ្យលោកបញ្ជាក់ប្រាប់ខ្ញុំបើសិនលោកអត់មានភាសាខ្មែរ។ គឺឯកសារ E3/11 តើលោកមានទេជាភាសាខ្មែរ? បើអត់មានជួយប្រាប់ខ្ញុំ។ ឯកសារហ្នឹងនឹងបង្ហាញបន្តិចទៀតនេះ ខ្ញុំនឹងអានជាភាសាអង់គ្លេស។ ក្នុងពេលដែលខ្ញុំអានជាភាសាអង់គ្លេសនោះ ឯកសារខ្មែរគឺថានឹងលេចចេញតាមអេក្រង់ឱ្យលោកពិនិត្យនិងពិចារណា។ នៅពេលនេះខ្ញុំសូម -- លោកអាចបញ្ជាក់ជូនខ្ញុំបានដែរឬទេលោកហេដឌ័រ ឯកសារ E3/11 ឯកសារទស្សនាវដ្តីទង់បដិវត្តលេខពិសេស ខែកញ្ញា ឆ្នាំ៧៧។ តើលោកមានទេ ឯកសារហ្នឹង? ខ្ញុំឃើញថាលោកងក់ក្បាលបញ្ជាក់ថាមានហើយ។

នៅពេលនេះខ្ញុំឲ្យលោកមើលទំព័រ៣៦ ជាភាសាអង់គ្លេស, ទំព័រជាភាសាខ្មែរដែលខ្ញុំសុំដាក់លើអេក្រង់នោះ បើសិនជាអាចបញ្ចាំងបានគឺលេខ 00063162 រហូតទៅដល់លេខ 63។ បារាំងមានលេខ 00492836 ហើយវាជាទំព័រ៣៦ ជាភាសាអង់គ្លេស។ សូមឲ្យលោក ហេងឌ័រ ពិនិត្យមើលទៅ។ ចំណុចដកស្រង់នោះគឺថាមានសរសេរដូចតទៅ៖ “នៅដើមដំបូងយើងបានផ្តោតទៅលើការវាយប្រហារខ្មាំងតំបន់ដែលទន់ខ្សោយ ជាពិសេសនៅតាមទីជនបទ ដោយរួមជាមួយនឹងការវាយប្រហារតាមកងទ័ពដោយកងទ័ពព្រៃ និងកងទ័ពសាមញ្ញរបស់យើង។ ហើយយើងធ្វើយ៉ាងណាដើម្បីវាយកម្ទេចចាប់យកកម្លាំងនៅក្នុងភូមិ។ នៅក្នុងរបៀបនេះហើយយើងបានរំដោះ និងពង្រីកទៅតាមទីជនបទជារៀងរាល់ថ្ងៃហើយបានធ្វើឲ្យខ្មាំងនៅដាច់ឆ្ងាយ ហើយឡោមព័ទ្ធពួកវា ជាពិសេសឡោមព័ទ្ធទៅលើប្រជាជន។ នៅក្នុងពេលជាមួយគ្នា យើងបានបំបែកកងកម្លាំងរបស់ខ្មាំង មិនថាគ្រឿង -- កម្លាំងផ្គត់ផ្គង់ ឬក៏កម្លាំងរបស់វាបានថយចុះទៅៗ”។

នៅពេលនេះ លោក ហេងឌ័រ ខ្ញុំសូមផ្តល់ឯកសារជាភាសាខ្មែរទៅដល់លោក ហើយនៅលើអេក្រង់ក៏មានដែរ។

[១១:០១:១៩]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំអនុញ្ញាតសុំយកឯកសារជាភាសាខ្មែរនេះ ជូនទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

[១១:០១:៣៦]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេងឌ័រ ខ្ញុំសូមបន្តទៅមុខទៀត ត្រង់ទំព័រ៣៦ដដែល។ យើងឃើញថា មានជាការសង្ខេបទៅលើអ្វីដែលកើតឡើងនៅក្នុងឆ្នាំ១៩៧០ ទៅដល់៧៤។ ខ្ញុំសូមដកស្រង់ “នៅពេលខ្សែទំនាក់ទំនងនៅតាមផ្លូវដី និងផ្លូវទឹកត្រូវបានកាត់ផ្តាច់នៅឆ្នាំ១៩៧៤ ពួកចក្រពត្តិអាមេរិក និងបនក្បត់របស់វាគឺបនក្បត់ លន់ នល់ យល់ឃើញថាពួកវានៅដាច់ពីក្រុងភ្នំពេញ ហើយនិងនៅតាមទីជនបទផ្សេងទៀត។ នៅក្នុងអំឡុងស្ថានភាពនេះហើយ ដែលបក្សរបស់យើង មជ្ឈិមបក្សរបស់យើងនៅក្នុងពេលសន្និបាទ

ខែមិថុនា ឆ្នាំ១៩៧៤ គឺបានធ្វើការវាយសម្រុកធំមួយដើម្បីរំដោះទីក្រុងភ្នំពេញ និងប្រទេសទាំងមូល”។

ខ្ញុំសូមនឹងអានបន្តទៀត ដើម្បីឲ្យយើងយល់ “យើងប៉ានរឺផ្តាច់ព្រ័ត្រយ៉ាងនេះ ដោយយើងក្តាប់ស្ថានការណ៍ខ្លាំង និងយើងបាននៅក្នុងដៃពេញទី។ ទិសវាយផ្តាច់ព្រ័ត្ររបស់យើងចែងដូចតទៅ វាយភ្នំពេញផង វាយផ្តាច់មេគង្គក្រោមផង និងវាយទីរួមខេត្ត ដែលខ្មាំងនៅកាន់កាប់បណ្តោះអាសន្នផង ដោយវាយក្តាប់មេគង្គក្រោមជាគន្លឹះ ដើម្បីវាយភ្នំពេញផ្តាច់ព្រ័ត្រ ហើយវាយទីរួមខេត្តដើម្បីរួមផ្សំ។ តាមទិសសម្រេចមជ្ឈិមបក្សយ៉ាងនេះ យើងបានរៀបចំពង្រឹងពង្រីកកងទ័ពក្នុងរដូវវស្សាឆ្នាំ៧៤ យ៉ាងសកម្ម ទាំងផ្នែកនយោបាយ សតិអារម្មណ៍ និងចាត់តាំង។ ខាងមាគ៌ាប្រយុទ្ធតាមសមរភូមិ: កងទ័ពបដិវត្តន៍យើងទាំងមូលក្តៀវក្លា និងបំពេញភារកិច្ចវាយផ្តាច់ព្រ័ត្ររបស់បក្ស ហើយប្តេជ្ញាដោយវីរភាពខ្ពស់បំផុត”។ សូមបញ្ចប់ការដកស្រង់។

[១១:០៣:៥១]

លោក ហេងឆ័រ សូមលោកកុំស្មាន កុំផ្តល់ជាមតិយោបល់ ផ្អែកទៅលើអង្គហេតុសុទ្ធសាធតែម្តង។ តើព័ត៌មាននៅក្នុងនេះ ក្រៅពីសុន្ទរកថារបស់ ប៉ុល ពត ដែលលោកចង់មើលជាភាសាខ្មែរ ក្រៅពីសុន្ទរកថាជាភាសាខ្មែររបស់ ប៉ុល ពត ឬក៏ក្រៅពីព័ត៌មាននៅក្នុងទស្សនាវដ្តីទង់បដិវត្តនេះ កម្មវត្ថុប្រធានបទរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រជុំនៅក្នុងខែមិថុនា ឆ្នាំ៧៤ ក្នុងពេលសន្និបាតនោះ តើបានសម្រេចធ្វើការវាយសម្រុកខ្លាំងក្លា ដើម្បីរំដោះទីក្រុងភ្នំពេញដែរឬទេ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ចម្លើយនេះប្រហែលជាមិនពេញចិត្តលោកទេ ក៏ប៉ុន្តែខ្ញុំអាចបញ្ជាក់ថាអ៊ីចឹងមែន។ ខ្ញុំមិនអាចបញ្ជាក់ថា ការប្រជុំនៅទីណានោះទេ។ ពាក់ព័ន្ធទៅនឹងការបកប្រែមជ្ឈិមបក្ស បាទ គឺគណៈកម្មាធិការមជ្ឈិមបក្សដែលក្នុងនេះ គេយោង។

**ស៖** ប្រសិនបើយើងមើលស្ថានភាពនៅក្នុងពេលនេះ គឺថាគេនិយាយថាគណៈកម្មាធិការនៃបក្សកុម្មុយនីស្តកម្ពុជាប្រជុំ។ ដូច្នេះតើចម្លើយរបស់លោកនៅពេលដែលគេនិយាយថាគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា តើវាជាមជ្ឈិមបក្ស ឬក៏អ្វីដែរ? គឺនៅក្នុងនេះ គេនិយាយថានៅក្នុងពេលគណៈសន្និបាតរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា តើសំដៅលើអ្វីដែលគណៈកម្មាធិការមជ្ឈិមនេះ?

[១១:០៥:៤១]

**ឆ៖** វាគ្រាន់តែវាយោងទៅលើមជ្ឈិមបក្ស តែក្នុងលក្ខណៈពាក្យមួយស្រពិចស្រពិលតែប៉ុណ្ណោះនៅក្នុងនេះ។ ខ្ញុំបានមើលទៅក្នុងឯកសារហ្នឹង និងឯកសារនេះទាំងអស់តែម្តង។ ជាពិសេសនៅក្នុងប្រយោគដូចដែលលោកបានលើកឡើង។

**ស៖** លោក ហេងឌ័រ ឲ្យលោកនិយាយមើល៍ពាក្យថា "*ផាតធី សិនធើ*" ជាភាសាខ្មែរគេបកយ៉ាងម៉េចដែរ គឺអ្វីដែរលោក?

**ឆ៖** គឺគេហៅថា "មជ្ឈិមបក្ស"។ ហើយពាក្យថា *"ខនហ្វើរិន"* នោះគឺបានបកប្រែត្រឹមត្រូវរួចមកហើយនៅក្នុងឯកសារនេះ។

**ស៖** ហើយនិងការវាយសម្រុកធំធេងទៅលើទីក្រុងភ្នំពេញ និងតាមទីជនបទក៏បកត្រូវដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលមជ្ឈិមបក្សរបស់យើងក្នុងពេលសន្និបាតមជ្ឈិមបក្សខែមិថុនា ឆ្នាំ៧៤ គឺគេបញ្ជាក់បានត្រឹមត្រូវ។

[១១:០៧:០០]

**ស៖** ខ្ញុំសូមសួរសំណួរបញ្ជាក់ថា តើវាត្រឹមត្រូវ ឬមិនត្រឹមត្រូវ? តើលោកបានដឹងដែរឬទេ សន្និបាត ឬក៏កិច្ចប្រជុំរបស់មជ្ឈិមបក្សក្រោយខែមិថុនា ឆ្នាំ៧៤ មានរៀបចំម្តងទៀតដែរឬទេ?

**ឆ៖** សន្និបាត ឬក៏ការប្រជុំទាំងអស់នោះ គឺជាពាក្យដែលគ្រាន់តែលើកឡើង ដូចថាចេញពីមាត់របស់គេដោយចៃដន្យតែប៉ុណ្ណោះ ពាក្យហ្នឹងគឺសំដៅទៅលើការប្រជុំពេញអង្គរបស់បក្សរបស់គេ។ ដូច្នេះហើយពាក្យថាមជ្ឈិមបក្សនោះ គេប្រើក្នុងនេះគឺវាស្រពិចស្រពិល ពាក្យថា "*ខនហ្វើរិន*" – សន្និបាត ឬប្រជុំពេលនោះ គឺថាជាកិច្ចប្រជុំរួមមួយធំចំណោមក្រៅពីបក្សទៅទៀត។ ក្នុងខែឧសភា ឆ្នាំ៧៥នោះ គឺថាវាមាននូវសន្និសីទ ឬក៏កិច្ចប្រជុំមួយ ក៏ប៉ុន្តែអាចប្រជុំហ្នឹងមួយទៀត។

[១១:០៨:០៥]

**ស៖** សូមឲ្យលោកគិតបន្តិច ដោយសារតែនៅទីនេះ គឺថាលោកយោងទៅលើអង្គហេតុដែលលោកបានដឹងតែប៉ុណ្ណោះ។ ជាពិសេសអំពីយើងហៅថា កិច្ចប្រជុំ ឬសន្និបាតរបស់មជ្ឈិមបក្សក្នុងខែមិថុនា ឆ្នាំ៧៤ អ៊ីចឹងសិនចុះ។ ក៏ប៉ុន្តែឲ្យលោកគិតបន្តិចក្នុងរយៈពេល២០នាទី ក្នុងពេលដែលខ្ញុំសួរសំណួរក្នុងពេលនេះ តើលោកអាចជួយពន្យល់យើងខ្ញុំបានដែរឬទេ ថាតើមានប្រភពអ្វីដែលលោកអាចបញ្ជាក់ថានៅពេលនោះ គឺមានការប្រជុំ ឬសន្និបាតរបស់មជ្ឈិមបក្សខែមិថុនា ឆ្នាំ៧៤នោះ មានឯកសារអ្វីជា

មូលដ្ឋានសំអាង?

**ឆ៖** *(គ្មានការបកប្រែ)*

**ស៖** លោកបានឆ្លើយរួចមកហើយ។

**ឆ៖** បាទ គឺខ្ញុំឆ្លើយរួចមកហើយ។

**ស៖** លោកបានឆ្លើយរួចមកហើយនៅក្នុងពេលមុនដែលថា មុនដំបូងលោក ខៀវ សំផន គឺជាសមាជិកបម្រុង តែក្រោយមកគឺជាសមាជិកពេញសិទ្ធិ។ តើលោកអាចបញ្ជាក់ត្រង់ចំណុចនេះដែរឬទេ?

[១១:០៩:២២]

**ឆ៖** ជាការពិត មានសន្និបាតបក្សមួយនៅក្នុងខែមករា ឆ្នាំ៧៦។ តាមខ្ញុំដឹងគឺលោក ខៀវ សំផន បានឡើងតំណែងពីសមាជិកត្រៀមរួចទៅដល់ជាសមាជិកពេញសិទ្ធិ។

**ស៖** *ថេប*១៦ សំណុំឯកសារ៥ដដែល។ សុំឲ្យលោកពិនិត្យមើល ឯកសារ E3/687 គឺរបាយការណ៍របស់កាសែត "ញូវយ៉កថាមស៍" ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៨២។ ក្នុងនេះគឺរៀបរាប់អំពីមេដឹកនាំនិរទេសបីរូប យោងទៅរកសម្តេច សីហនុ, សុន សេន និង ខៀវ សំផន។ អង់គ្លេស 00122280, ខ្មែរគឺ 00651187 ហើយទំព័របារាំង គឺទំព័រចុងក្រោយ។ នៅពេលដែលគេយោងទៅលើ ខៀវ សំផន នោះ គឺអត្ថបទនេះសរសេរដូចតទៅ៖ "ហើយគាត់ទទួលស្គាល់ថា ប្រជាជនកម្ពុជារាប់លាននាក់បានជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់តំបន់ជនបទ ដោយសារតែសេចក្តីសម្រេចសម្ងហាភាព"។ តើលោកមានបានចូលរួមក្នុងការសម្រេចចិត្តនោះដែរឬទេ? លោក ខៀវ សំផន បានញញឹមស្ងួត ហើយឆ្លើយជាភាសាបារាំងថា បាទ ប្រាកដណាស់"។ បញ្ចប់ការដកស្រង់។

លោក ហេងឆ័រ ផ្អែកទៅលើព័ត៌មានការពិតដែលលោកបានដឹង កុំធ្វើការទាយស្មាន ឬក៏កុំបញ្ចេញមតិយោបល់។ ព័ត៌មានអង្គហេតុការពិតដែលលោកបានទទួលនោះ ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន នេះ តើគាត់មានបានចូលរួមការសម្រេចសម្ងហាភាពក្នុងការបញ្ជូនប្រជាជនពីទីក្រុងភ្នំពេញ ទៅកាន់តំបន់ជនបទដែរឬទេ?

[១១:១១:៣៣]

**ឆ៖** ខ្ញុំមិនចាំទេ។ នៅក្នុងសំណុំឯកសាររបស់ខ្ញុំ គឺគិតថាអត់មានទេ។ លើកលែងនៅក្នុងកិច្ចសម្ភាសន៍របស់ខ្ញុំដែលខ្ញុំបានទៅសម្ភាសក្នុងឆ្នាំ២០០៥។ ប្រសិនបើមាននោះ គឺមាននៅក្នុងហ្នឹង។

**ស៖** នៅពេលនេះ គឺថាឲ្យលោកមើល *ថេប*១៨ គឺកម្រងអង្គការលើកលែងទោសអន្តរជាតិ។

សូមឲ្យលោកទុកចោលឯកសារដំបូងសិនទៅ ដែលក្នុងលើកឡើងថ្ងៃ១៨ ខែ--

**អ្នកបកប្រែ៖**

សូមអនុញ្ញាតពីលោកប្រធាន ឲ្យតំណាងសហព្រះរាជអាជ្ញាជួយបញ្ជាក់ថ្ងៃខែ និងលេខឯកសារឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាបញ្ជាក់ពីថ្ងៃខែឆ្នាំ និងលេខឯកសារឡើងវិញ។ អំមិញនេះ គឺអ្នកបកប្រែបកប្រែមិនទាន់ទេ។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** ឯកសារគឺ ដែលខ្ញុំមិនយោងទេ គ្រាន់តែខ្ញុំបញ្ជាក់គឺឯកសារ D84/2.3 ចុះថ្ងៃ១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារបន្ទាប់គឺឯកសារ E3/3864 គឺលិខិតផ្ញើពីអង្គការលើកលែងទោសអន្តរជាតិ ជូនទៅដល់លោក ខៀវ សំផន ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ កម្មវត្ថុនៅក្នុងនោះ គឺស្ដីអំពីប្រជាជនទាំងឡាយនៅក្នុងប្រទេសថៃដែលត្រូវបានបញ្ជូនត្រឡប់មកអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យវិញ។

[១១:១៣:៣១]

នៅក្នុងនេះ ក៏ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀតដែរ។ នៅក្នុងកម្រងឯកសាររបស់លោក គឺទំព័រចុងក្រោយនៃថេបរបស់លោក ឯកសារ E3/3311 គឺលិខិតមួយច្បាប់ផ្ញើមកពីអង្គការលើកលែងទោសអន្តរជាតិ។ ហើយប្រសិនបើខ្ញុំសូមដកស្រង់ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ចំណងជើងគឺមានសរសេរដូចតទៅ -- បាទ ជាសេចក្ដីប្រកាសព័ត៌មានទេ ខ្ញុំសូមអធ្យាស្រ័យ។ ចំណងជើងគឺ “អង្គការលើកលែងទោសអន្តរជាតិ ព្រួយបារម្ភចំពោះការមិនឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ អង្គការលើកលែងទោសអន្តរជាតិនៅក្នុងថ្ងៃនេះ គឺថ្ងៃ០៨ ឧសភា ថ្ងៃអាទិត្យ ឆ្នាំ៧៧ បង្ហាញអំពីការព្រួយបារម្ភដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ខកខានមិនបានឆ្លើយតបនឹងសេចក្ដីអំពាវនាវកាលពីមុន និងការសាកសួរនានា។ អង្គការសិទ្ធិមនុស្សអន្តរជាតិបានលើកឡើងថា នៅក្នុងខែកុម្ភៈ ឆ្នាំនេះ គឺខ្លួនបានអំពាវនាវប្រធានរដ្ឋ ខៀវ សំផន ឲ្យពិចារណាទៅលើជោគវាសនាពលរដ្ឋកម្ពុជា២៦នាក់ ដែលត្រូវបានបង្ខំឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ដោយប្រទេសថៃ នៅក្នុងខែវិច្ឆិកា ឆ្នាំ៧៦។ ជនទាំង២៦នាក់នោះ ជាកសិករ ក៏ប៉ុន្តែក្នុងរួមមានកុមារអាយុ១១ឆ្នាំផងដែរ។ ក្រោយមកត្រូវបានគេរាយការណ៍ថាត្រូវបានសម្លាប់ចោលក្រោយពួកគេបានត្រឡប់មកប្រទេសកម្ពុជា។ សេចក្ដីអំពាវនាវទៅដល់ប្រធានរដ្ឋ

ខៀវ សំផន គឺមាននៅក្នុងលិខិតមួយច្បាប់ ដែលក្នុងនោះយោងទៅលើរបាយការណ៍ចោទប្រកាន់អំពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការធ្វើបាបជនស៊ីវិលដោយកម្មាភិបាលមូលដ្ឋាននៅតាមតំបន់មួយចំនួននៃប្រទេសកម្ពុជា។ ដូចដែលបានសាកសួរដោយអង្គការលើកលែងទោសអន្តរជាតិទៅដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ លិខិតនេះនៅតែពុំទទួលបានចម្លើយនាពេលនេះដដែល”។ បញ្ចប់ការដកស្រង់។

[១១:១៥:៤២]

លោក ហេដឌ័រ ផ្អែកទៅលើអង្គហេតុការពិតដែលលោកបានទទួលបាន និងបានដឹង មិនឲ្យស្មាន ឬក៏មិនបញ្ចេញយោបល់ទេ។ តើអង្គហេតុនិងចំណុចដែលរៀបរាប់នៅក្នុងលិខិតសេចក្ដីប្រកាសព័ត៌មាននេះ ថាតើការឆ្លើយតបផ្លូវការ ឬក៏មិនផ្លូវការបានធ្វើឡើងតាមរយៈការឆ្លើយតបដោយផ្ទាល់តែម្តង ឬក៏ដោយប្រយោលដែរឬទេចំពោះការស្នើសុំការលើកលែងទោសអន្តរជាតិនេះ?

**ឆ៖** ខ្ញុំសូមឆ្លើយថាអត់មានបានឆ្លើយទេ អត់មានបានឆ្លើយតបនោះទេ ដោយសារតែសំណុំឯកសារអង្គការលើលលែងទោសអន្តរជាតិត្រូវបាន -- ខ្ញុំពិនិត្យមើលនៅពាក់កណ្ដាល និងចុងឆ្នាំ១៩៨០ គឺគ្មានភស្តុតាងណាមួយបង្ហាញថាគាត់បានឆ្លើយតបទៅនឹងការអំពាវនាវស្នើសុំនេះទេ។

**ស៖** លោកបាននិយាយអម្បាញ់មិញថាចុងឆ្នាំ៨០ នៅពេលដែលលោកជួប អៀង សារី និង ណាត នៅក្នុងសន្និបាត មហាសន្និបាតអង្គការសហប្រជាជាតិនៅបុរីញូវយ៉ក។ ក្នុងអំឡុងពេលនុំង តើលោក អៀង សារី, ណាត ឬក៏អ្នកផ្សេងទៀតមានទំនាក់ទំនងជាមួយនឹងកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ហើយធ្លាប់បានប្រាប់លោកថា គេបានឆ្លើយតប រដ្ឋាភិបាលបានឆ្លើយតបចំពោះការប្ដឹងតវ៉ារបស់ជនភៀសខ្លួន រួមទាំងការឆ្លើយតបទៅនឹងសេចក្ដីអំពាវនាវរបស់អង្គការលើកលែងទោសអន្តរជាតិដែលលើកឡើងអំពីការសម្លាប់ក្រៅប្រព័ន្ធតុលាការនៅកម្ពុជាប្រជាធិបតេយ្យនោះ?

[១១:១៧:៣៦]

**ឆ៖** ខ្ញុំមិនចាំថាមានប្រភពណាលើកឡើងប្រាប់អ៊ីចឹងឲ្យខ្ញុំដឹងនោះទេ។ ឯកសារដែលខ្ញុំបានមើលនោះ គឺឯកសារសាធារណៈផ្ញើជូនទៅអង្គការសហប្រជាជាតិដោយ អៀង សារី ក៏ប៉ុន្តែវាមិនបានផ្ញើជូនដោយផ្ទាល់ឲ្យខ្ញុំនោះទេ។

**ស៖** តើលោកអាចបញ្ជាក់ទេ គឺលិខិតដែល អៀង សារី ផ្ញើទៅកាន់អង្គការសហប្រជាជាតិនោះថាវាជាការឃោសនា ឬក៏ជាការពិតជាក់ស្ដែង ដែលឆ្លើយតបទៅនឹងសំណើនាពេលនោះ? តើលោកអាចបញ្ជាក់អំពីលក្ខណៈនៃការលើកឡើងនៅក្នុងលិខិតនោះដែរឬទេ?

**ឆ៖** តាមខ្ញុំចាំជា -- ដោយខ្លី ខ្ញុំអាចនិយាយដោយខ្លីថាវាជាការឃោសនា ហើយវាមិនត្រឹមត្រូវទេ អ្វីដែលលើកឡើងក្នុងពេលនោះ។

**ស៖** ខ្ញុំសូមអធ្យាស្រ័យ ដោយសារខ្ញុំសួរលោកម្តងឆ្នាំនេះ ម្តងឆ្នាំនោះ ក៏ប៉ុន្តែនេះជាការរកស្វែងរកភស្តុតាង។ លោកបានលើកឡើងថា លោកបានមកដល់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ៧៣, ខ្ញុំមិនដឹងខែទេ ប្រហែលជាខែកញ្ញា បើសិនជាខ្ញុំចាំ, បន្ទាប់មកលោកនៅរហូតទៅដល់ថ្ងៃ១១ ឆ្នាំមួយពាន់ប្រាំ -- ថ្ងៃ១១ ខែកញ្ញា ឆ្នាំ៧៥ ទើបលោកទៅទីក្រុងបាំងកក។ ខ្ញុំសូមសួរលោកអំពីស្ថានភាពមនុស្សធម៌នៅក្នុងទីក្រុងភ្នំពេញវិញម្តង ជាដំបូងខ្ញុំសូមឲ្យលោកធ្វើការបង្ហាញជារូបភាពឲ្យយើងបានដឹងចំពោះប្រជាជននៅក្នុងឆ្នាំ១៩៧៤។ នៅពេលដែលលោកនៅក្នុងប្រទេសកម្ពុជាឆ្នាំ៧៤ តើចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជាឆ្នាំ៧៤ នេះមានការកើតឡើងដែរឬទេ? សូមលោកជួយពន្យល់។

[១១:១៩:៣២]

**ឆ៖** តាមខ្ញុំចាំ ជាទូទៅឃើញមានការកើនឡើងក្នុងអំឡុងពេលនោះ ក្នុងពេលដែលខ្ញុំនៅក្នុងប្រទេសកម្ពុជា។

**ស៖** លោកនិយាយអំពីលំនៅដ្ឋាន លោកបាននិយាយថានៅក្នុងប្រាំងឆ្នាំ៧៤ ឆ្នាំ៧៥ ការបាញ់ផ្លោងគឺថាបានកើនឡើងក្នុង៧៤ និង ឆ្នាំ៧៥ នៅក្នុងរដូវប្រាំង។ តើលោកអាចបញ្ជាក់បានដែរឬទេ តើមានការកើតឡើងនៅក្នុងឆ្នាំ៧៤, ៧៥ នោះដែរឬទេ?

**ឆ៖** បាទ គឺមានដូច្នោះមែន។

**ស៖** លោកបាននិយាយថ្ងៃថា ថ្ងៃ១៥ ខែសីហា ឆ្នាំ៧៣ ដែលក្នុងពេលនោះគឺថាជាការបញ្ចប់ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ ហើយលោកនិយាយថា រដូវប្រាំងឆ្នាំ៧៣-៧៤ និងរដូវប្រាំងឆ្នាំ៧៤-៧៥ គឺលោកនិយាយអំពីការទម្លាក់គ្រាប់បែក។ លោកបានរៀបរាប់ទាំងអស់នោះ តើព័ត៌មានទាំងអស់នោះ គឺថាលោកបានដឹង ហើយមានការទម្លាក់គ្រាប់បែកអ៊ីចឹងមែន ហើយលោកបានធ្វើជាត្រង់សេដើម្បីជ្រកកោនផងដែរ។ តើអ៊ីចឹងដែរឬទេ?

[១១:២០:៥៣]

**ឆ៖** ខ្ញុំ តាមខ្ញុំចាំគឺនៅក្នុងរដូវក្តៅឆ្នាំ៧៤ និងដើមឆ្នាំ៧៥ ឬក៏រហូតទៅដល់ចុងឆ្នាំ៧៥ គឺមិនមែនជារដូវប្រាំងដែលមានទឹកលិចនោះទេនៅតាមតំបន់ដែលមានភក់ និងទឹកតិចតួចនោះ។

**ស៖** ខ្ញុំនៅពេលនេះសួរអំពីឆ្នាំ៧៥វិញម្តង យើងបានដឹងហើយថាតាមកិច្ចសម្ភាសន៍ដែលលោក

បានធ្វើឡើង ហើយយើងក៏បានសួររួចរាល់អស់ដែរ។ ការវាយសម្រុកចូលទីក្រុងភ្នំពេញចាប់ផ្ដើមនៅម៉ោងមួយព្រឹក ថ្ងៃទី០១ មករា ឆ្នាំ៧៥។ តាមលោកដឹងអ្នកស្រុក អ្នកនៅទីក្រុងភ្នំពេញពីថ្ងៃ០១ ខែមករា ឆ្នាំ៧៥នោះ តើអំឡុងពេលហ្នឹងហើយដែលលោកបានដឹងថា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ៧៥ទៅការវាយសម្រុកកាន់តែខ្លាំងឡើង ហើយការទម្លាក់គ្រាប់បែកក៏បានកើតឡើងផងដែរនៅពេលនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** នៅចុងឆ្នាំ១៩៧៤ បើទោះជាមានការបាញ់ផ្លោងដោយកាំភ្លើងធំពីនិរតីក៏ដោយ ពេលខ្លះគឺថាមានសមរភូមិមានការបាញ់ថយចុះ ហើយសាធារណរដ្ឋខ្មែរបានយល់ឃើញថា ខ្មែរក្រហមគឺកំពុងតែដកថយ។ ហើយគេគិតថាខ្មែរក្រហមកំពុងតែចុះទន់ខ្សោយផ្នែកយោធា ហើយអនុព័ន្ធជប៉ុនដែលខ្ញុំបានលើកឡើងកាលពីមុនអ៊ីចឹង តាមប្រភពស្ថានទូតនានាបានប្រាប់ខ្ញុំនាពេលនោះថា នៅពេលដែលថយចុះនោះ គឺគេគ្រាន់តែធ្វើការផ្ដោតសំខាន់ដើម្បីមកវាយទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ គឺការវាយនោះថយចុះនៅក្នុងថ្ងៃចន្លោះ៣១ ខែធ្នូ ឆ្នាំ៧៤ និង០១ ខែមករា ឆ្នាំ៧៥។

[១១:២៣:១០]

នៅថ្ងៃទី០១ មករា ឆ្នាំ៧៥ នៅម្ខាងទន្លេមេគង្គ យើងឃើញថាមានសាធារណរដ្ឋ មានកងកម្លាំងរបស់សាធារណរដ្ឋខ្មែរ ហើយត្រូវបានកងកម្លាំងខ្មែរក្រហមហ្នឹងវ៉ៃទម្លាក់ចូលទឹកផងដែរ។ ហើយនៅក្នុងពេលនោះ គឺថាខ្ញុំបានធ្វើដំណើរទៅតាមទីកន្លែងទីតាំងយោធា ដែលកំពុងតែមានការរួញថយចុះ។ នៅថ្ងៃនោះ គឺខ្ញុំបានធ្វើដំណើរទៅតាមព្រំដែនរបស់ទាហាន ហើយខ្ញុំបានធ្វើការពិភាក្សា និងជជែកជាមួយនឹងទាហានរបស់សាធារណរដ្ឋខ្មែរ។ ហើយខ្ញុំបានគិតថា ពួកគេមានការភ័យខ្លាចនៅពេលដែលស្ថានទូតខ្ញុំប្រាប់ថាស្ថានទូតរបស់អាមេរិកចាប់ផ្ដើមជម្លៀសមន្ត្រីរបស់គេចេញពីទីក្រុងភ្នំពេញ ហើយទាហាននាពេលនោះគឺថាមានការខកចិត្ត និងអស់សង្ឃឹម។

ស្ថានភាពនៅក្នុងទីក្រុងភ្នំពេញវិញ ដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង។ គឺមានភាពច្របូកច្របល់ ហើយមានការបោកបញ្ឆោតផ្នែកនយោបាយ។ ខ្ញុំគិតថាពីមុនខ្ញុំមិនបានលើកឡើងថា ប្រហែលជាខ្ញុំលើកឡើងដែរចំណុចហ្នឹង។ ខ្ញុំបាន -- ខ្ញុំមានទំនាក់ទំនងល្អជាមួយនឹងកម្មករ និងនិស្សិតក្នុងពេលនោះ ហើយខ្ញុំចាប់អារម្មណ៍ទៅលើបញ្ហាថា មានអ្វីកើតឡើងប្រសិនបើខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ។

[១១:២៤:៥៣]

មាននិស្សិត មានមេដឹកនាំនិស្សិតសាកលវិទ្យាល័យមួយ ដែលខ្ញុំចាំឈ្មោះ គុណ ធនថាណាវ៉ាត់

ហៅ ពេញ។ ខ្ញុំបានសួរសំណួរហ្នឹងទៅកាន់គាត់។ គាត់ជាមេ ដឹកនាំនិសិត្សនៅសកលវិទ្យាល័យ។ ខ្ញុំសួរថាមានអ្វីកើតឡើងក្រោយខ្មែរក្រហម នៅថ្ងៃទី០៨ និងថ្ងៃ០៩ ខែមេសា ខ្ញុំលើកឡើងថា តើបដិវត្តន៍នឹងធ្វើអ្វីប្រសិនបើបានរំដោះទីក្រុង? គាត់បានឆ្លើយប្រាប់ខ្ញុំថា "លោកមិនបាច់ព្រួយបារម្ភទេ គេនឹងឲ្យទៅតាមទីស្រែ"។ ខ្ញុំអត់យល់ពេលនុំង។ ខ្ញុំមិនជឿតាមអ្វីដែលគាត់ប្រាប់នោះទេថាអ៊ីចឹងកើតឡើងនោះ។ ក៏ប៉ុន្តែក្រោយមក ក្រោយរំដោះភ្នំពេញទើបមានស្ថានភាពអ៊ីចឹងមែន។ ខ្ញុំជាអ្នកកាសែត ហើយខ្ញុំកន្លែងហ្នឹងគឺខ្ញុំខុស ហើយខ្ញុំមិនជឿទៅលើការដែលប្រាប់អ៊ីចឹង។ ក៏ប៉ុន្តែក្រោយមកគឺថាផែនការហ្នឹង គឺគេអនុវត្តដូច្នោះមែន ក្រោយពីជម្លៀសទីក្រុងភ្នំពេញ ក្រោយពេលរំដោះ។

**ស៖** តើលោកដឹងទេ តើមេដឹកនាំនិស្សិតសកលវិទ្យាល័យហ្នឹងគាត់មានទំនាក់ទំនងយ៉ាងម៉េចជាមួយមេដឹកនាំផ្សេងទៀតដែលលាក់ខ្លួន ឬក៏មេដឹកនាំផ្សេងទៀតដែលជាប់ពាក់ព័ន្ធដែរឬទេ?

**ឆ៖** មនុស្សមួយចំនួននៅក្នុងប្រព័ន្ធស៊ើបការណ៍របស់ខាងស្ថានទូតបរទេសនោះគឺលើកឡើងថាគាត់ជាអ្នកមានទំនាក់ទំនងជាមួយនឹងពួកអ្នកទៅលាក់ខ្លួននៅក្នុងព្រៃ ឬក៏អ្នកមានទំនាក់ទំនងផ្សេងទៀតហើយក្រោយមក គឺខ្ញុំដឹងថាគាត់ប្រហែលជាត្រូវបានគេយកទៅឃុំនៅស-២១ ឆ្នាំ៧៧។ ខ្ញុំបាត់ដំណឹងទាក់ទងជាមួយនឹងគាត់។

[១១:២៦:៥៦]

**ស៖** នៅពេលនេះខ្ញុំសួរលោកអំពីករណីថាតើបាទ ខ្ញុំសួរជាលក្ខណៈប្រវត្តិសាស្ត្រឆ្នាំ៧៣។ លោកនៅក្នុងប្រទេសកម្ពុជា ៧៤ ក៏លោកនៅក្នុងប្រទេសនេះដែរ ៧៥ក៏លោកនៅ។ តើការផ្គត់ផ្គង់តាមដងទន្លេមេគង្គមកពីសៃហ្គន នោះយ៉ាងម៉េចដែរ? តើស្ថានភាពតាមដងទន្លេមេគង្គ ផ្លូវទឹកដងទន្លេមេគង្គនោះយ៉ាងម៉េចដែរ? ការផ្គត់ផ្គង់នោះយ៉ាងម៉េចនៅក្នុងទីក្រុងភ្នំពេញ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាល់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីវ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះ ដោយសារតែសំណួរនេះស្នើសុំឲ្យសាក្សី ផ្តល់ជាមតិយោបល់។

[១១:២៧:៥៥]

**E1/223.1**

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំអប្បាញ់មិញនេះមិនធ្វើសេចក្ដីណែនាំមុនពេលដែលខ្ញុំសួរសំណួរ។ ដូច្នេះហើយខ្ញុំសូមណែនាំទៅដល់សាក្សីសិន។ សូមលោកកុំបញ្ចេញមតិយោបល់ កុំស្មាន ផ្អែកទៅលើព័ត៌មានអង្គហេតុផ្ទាល់ដែល លោកបានឃើញបានដឹង ឬក៏ដែលគេផ្ដល់ឲ្យលោក។ តើលោកអាចជួយពន្យល់បានដែរឬទេអំពីព័ត៌មានពាក់ព័ន្ធទៅនឹងការផ្គត់ផ្គង់តាមដងទន្លេមេគង្គ តើយ៉ាងម៉េចដែរ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ស្ថានភាព ឬក៏បញ្ហានេះគឺខ្ញុំបានយកមកពិភាក្សាជាមួយនឹងអនុព័ន្ធយោធាមួយចំនួនផងដែរ។ វាបង្ហាញយ៉ាងច្បាស់ចំពោះអនុព័ន្ធរួមទាំងខ្ញុំឲ្យបានដឹងថា ការផ្គត់ផ្គង់ស្បៀងអាហារ និងគ្រាប់យុទ្ធភណ្ឌនោះពីវៀតណាមខាងត្បូងតាមដងទន្លេមេគង្គ គឺជាផ្លូវទឹកផ្គត់ផ្គង់មួយដ៏សំខាន់ខាងផ្នែកសេដ្ឋកិច្ចដើម្បីឲ្យទីក្រុងភ្នំពេញរស់រានមានជីវិតបន្តទៀត។ ហើយខ្ញុំចាំថា ខ្ញុំបានពិភាក្សាជាក់លាក់ជាមួយនឹងអនុព័ន្ធមួយជាមួយនឹងខាងអាមេរិក។ ខ្ញុំបានសួរគាត់នៅខាងអនុព័ន្ធយោធាអាមេរិកនេះ ថាតើមានអ្វីកើតឡើងប្រសិនបើគេកាត់ផ្ដាច់ផ្លូវមេគង្គនោះ។ គាត់បានឆ្លើយជាមួយខ្ញុំទៅលើបញ្ហាហ្នឹង ហើយប៉ុន្មានសប្ដាហ៍ក្រោយមកគឺគេកាត់ផ្ដាច់ទន្លេមេគង្គ ហើយមានកងទ័ពគេឈរជើងនៅទន្លេមេគង្គ ហើយក្បួននាវាដែលឡើងមកទន្លេមេគង្គនេះត្រូវបានគេបាញ់ដើម្បីកាត់កុំឲ្យក្បួននោះឡើងមកតាមទន្លេមេគង្គ។

[១១:២៩:៥៣]

**ស៖** តើនៅពេលនោះលោកលើកឡើងថា មានមីន ដែលគេកប់មីនផងដែរនៅក្នុងពេលនោះ។ តើមកពីណាដែរ ហើយគេធ្វើយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំចាំ តាមខ្ញុំចាំ គឺគេប្រាប់ខ្ញុំថា មីនដែលគេដាក់នៅតាមដងទន្លេនោះ គឺថាដោយភូមិភាគបូព៌ានិងភូមិភាគពិសេស។ ខ្ញុំមិនចាំថាខ្ញុំបានទៅកន្លែងនោះមើលដោយខ្លួនឯងផ្ទាល់ ឬក៏យ៉ាងណានោះទេ ខ្ញុំមិនប្រាកដទេ។ ដូច្នេះ ខ្ញុំមិនប៉ាននិយាយបញ្ហានេះដោយផ្ទាល់នោះឡើយ។ ក្រោយមកនៅ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ ការឃោសនាបានលើកឡើង ហើយមានរូបថតបានផ្ដិតផងដែរ។ នាវាដែលបានព្យាយាមបើកឆ្លងមកនោះ គឺថាត្រូវបានផ្ទុះដោយមីននេះ នេះគឺព័ត៌មានដែលខ្ញុំទទួលបាននេះតាមអនុព័ន្ធរបស់អាមេរិក។

**ស៖** ទាក់ទងទៅនឹងចំនួនឧបត្ថម្ភ -- ចំនួនការឧបត្ថម្ភមកភ្នំពេញហ្នឹងមានច្រើនទេ?

[១១:៣១:១៩]

**ឆ៖** បាទថាមានការកាត់បន្ថយទាំងពីច្រកហ្នឹងតែម្តង មានតែមធ្យោបាយដឹកនាំតាមយន្តហោះហើយចំណីអាហារ ហើយនិងគ្រាប់រំសេវកាន់តែថយចុះឡើង ថយចុះ។

**ស៖** ទាក់ទងទៅនឹងព័ត៌មានអង្គហេតុដោយមិនត្រូវស្មាន ឬផ្តល់ជាយោបល់ទេលោក។ តើលោកអាចផ្តល់អំពីព័ត៌មានអង្គហេតុទាក់ទងទៅនឹងការផ្គត់ផ្គង់តាមជើងអាកាស តើមានការសម្របសម្រួលអីយោគយល់ដោយមធ្យោបាយណាមួយទេ?

**ឆ៖** ខ្ញុំហាក់បីដូចជាមិនច្បាស់លាស់បន្តិចត្រង់នេះ។ តាមផ្លូវជើងអាកាសនេះ គឺថាពេលខ្លះនេះខ្ញុំនិយាយតែប៉ុន្មានថ្ងៃ ឬប៉ុន្មានសប្តាហ៍មុនថ្ងៃទី១១ ខែមេសា ខ្ញុំមិនច្បាស់ទេចំណុចនេះ។

[១១:៣២:២៣]

**ស៖** ទាក់ទងទៅនឹងមន្ទីរពេទ្យវិញម្តង គឺនៅចុងឆ្នាំ៧៤ ទៅដល់ខែមេសា ៧៥។ តើលោកបានទៅមើលមន្ទីរពេទ្យណាមួយមានព័ត៌មានជាក់ស្តែងណាមួយទៅលើជនស៊ីវិលដែលរងរបួសសម្រាកនៅមន្ទីរពេទ្យ -- ខ្ញុំនិយាយពីជនស៊ីវិលដែលត្រូវបានគេព្យាបាលនៅមន្ទីរពេទ្យ នៅក្នុងមន្ទីរពេទ្យ ឬជុំវិញទីក្រុងភ្នំពេញនោះទេ លោកដឹងទេ?

**ឆ៖** ខ្ញុំមិនបានទៅមើលដូច្នេះទេ។

**ស៖** លោកបានផ្តល់សក្ខីកម្មពីមុនមកដោយលើកឧទាហរណ៍ អំពីការកាប់សម្លាប់ ឬក៏ប្រជាជនបានប្រាប់លោកអំពីការកាប់សម្លាប់ ឬលោកបានឃើញសាកសពនៅឧដុង្គ គឺនៅខែមីនា ១៩៧៤ហើយក្នុងនោះក៏ដូចជានៅកំពង់ចាមផងដែរ។ ដូច្នេះសំណួររបស់ខ្ញុំ គឺចាប់តាំងពីពេលលោកមកដល់នៅឆ្នាំ៧៣ រហូតដល់ថ្ងៃទី១១ ខែមេសា ៧៥ ដោយមិនមានការនិយាយស្មានៗ ការផ្តល់ជាយោបល់អីផ្សេងៗគឺដោយយោងតែទៅលើព័ត៌មានអង្គហេតុជាក់ស្តែងតែម្តង ទោះជាតាមរយៈកិច្ចសម្ភាសន៍របស់លោកក្តីតើមានការរាយការណ៍អំពីការកាប់សម្លាប់រង្គាលទៅលើជនស៊ីវិលដែរទេ? ការកាប់សម្លាប់ជនស៊ីវិលដោយរង្គាលដោយកងទ័ពខ្មែរក្រហមដែរឬទេ?

[១១:៣៤:១២]

**ឆ៖** មានរបាយការណ៍មួយចំនួនដែលរៀបរាប់អំពីរឿងរ៉ាវ ប៉ុន្តែពិបាកហ្នឹងបញ្ជាក់អះអាងដែរដោយសារថាវាពិបាកទៅដល់កន្លែងទីតាំងដែលគេរាយការណ៍ហ្នឹង ប៉ុន្តែ ដោាន រ៉ង*(តាមសូរស័ព្ទ)* គាត់បានធ្វើការទៅលើកិច្ចការនេះ។

**ស៖** តើលោកមានសម្ភាសជនភៀសខ្លួនដែលហូរចូលមកទីក្រុងភ្នំពេញដូចជានៅចុងឆ្នាំ៧៤

រហូតទៅដល់ដើមឆ្នាំ៧៥ ដែរទេ?

**ឆ៖** ខ្ញុំបានសម្ភាសខ្លះដែរ។ ខ្ញុំខិតខំប្រឹងប្រែងណាស់ដែរ តែមិនបានទទួលជោគជ័យគួរជាទីពេញចិត្តទេ។ ខ្ញុំព្យាយាមទាក់ទងដើម្បីសម្ភាសជាមួយប្រជាជនដែលជាប់ទាក់ទងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាដែរ។

**សៈ** ពាក់ព័ន្ធទៅនឹងអង្គហេតុព័ត៌មានដោយមិនត្រូវផ្តល់ជាមតិ ឬក៏យោបល់ទេនោះ។ តើមានឯកសារនិយាយអំពីការពិតណាមួយដែលថាខ្មែរក្រហមមានទំនាក់ទំនង ឬក៏មានសំណើពីភ្នាក់ងារសង្គ្រោះអន្តរជាតិ ដើម្បីស្នើសុំជួយខ្មែរក្រហមដោយប្រការណាមួយដែរទេ?

**ឆ៖** តាមដែលខ្ញុំដឹង ដូចជាមិនមានទេ។

[១១:៣៥:៥៦]

**សៈ** ជនភៀសខ្លួនដែលលោកបាននិយាយជាមួយ ឬសម្ភាស តើជនភៀសខ្លួនទាំងនោះហ្នឹងភៀសខ្លួនចេញមកពីកន្លែងណាដែរ?

**ឆ៖** ខ្ញុំប្រើពាក្យជាទូទៅតែម្តង គឺគេភៀសខ្លួនចេញពីសមរភូមិប្រយុទ្ធរបស់ខ្មែរក្រហម ព្យាយាមចេញពីអំពីការគំរាមកំហែង ការទម្លាក់គ្រាប់បែក ការបាញ់ផ្តោងដោយកងទាហានរបបសាធារណរដ្ឋខ្មែរ។ ទោះបីជាគេរៀបរាប់រឿងនេះក៏ដោយ ខ្ញុំព្យាយាមថាតើមានអ្វីកើតឡើងចំពោះរឿងរ៉ាវនេះ។ អ៊ីចឹងអ្វីដែលគេរៀបរាប់ប្រាប់ខ្ញុំ គ្រាន់តែជាការស្មានៗ។ ដូច្នេះវាមានការគិតទៅតាមមធ្យោបាយ។ ពិបាកនឹងយកមកធ្វើជាមូលដ្ឋានដែរចំពោះប្រជាជនដែលប្រាប់ខ្ញុំហ្នឹង មិនដឹងថាគាត់មានការដឹងដោយផ្ទាល់ឬយ៉ាងណាទេ។

**សៈ** សូមអរគុណ។ យើងសូមចូលទៅឯកសារទី២។ ខ្ញុំសង្ឃឹមថាលោកមានប្រតិចារឹកដែលលោកសម្ភាសជាមួយ អៀង សារី នៅខែធ្នូ ឆ្នាំ១៩៧៦ គឺ E3/89។ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងកិច្ចសម្ភាសន៍របស់លោកនេះ។ កំណត់ត្រានេះគឺថា ស្ទីវ ហេដឌ័រ សម្ភាសលោក អៀង សារី ដូចតទៅៈ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងបញ្ហាប្រល័យពូជសាសន៍។ សូមសួរលោកមើល តាមការវាយតម្លៃទៅលើស្ថានភាពនេះ។ យោងទៅតាមភស្តុតាងដែលខ្ញុំបានឃើញកន្លងមក គឺយើងមានផែនការអីប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ។

[១១:៣៨:២៩]

ប៉ុន្តែគឺអំពើប្រល័យពូជសាសន៍បង្កើត គឺដោយសារតែគោលនយោបាយពីរដែលវាមានបញ្ហា

បរាជ័យ។ ទី១ មានផែនការអនុវត្ត ដោយអង្គការមហាជន គឺដោយការបង្ខិតបង្ខំ និងដោយជឿនលឿនបំផុត។ ទី២ មានផែនការអនុវត្ត គឺធ្វើការជាតិតូបនីយកម្មខ្មែរ ដោយលឿនបំផុត។ ទី៣ អ្នកណាម្នាក់ប៉ោនតវ៉ាជំទាស់ ឬខកខានមិនបានអនុវត្តផែនការនេះអាចត្រូវបានគេចាត់ទុកថាជាខ្មាំង ឬពួកក្បត់ជាតិ និងក្បត់បក្ស។ ដោយសារផែនការទាំងនេះត្រូវបានពិចារណាថាចាំបាច់ណាស់ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាហ្នឹងក្លាយទៅជារបបសង្គមនិយមមួយដ៏ខ្លាំង ឯករាជ្យចេញពីពួកចក្រពត្តិ និងវៀតណាម។ ទី៤ អ្នកណាម្នាក់ដែលត្រូវបានគេចោទប្រកាន់ថាជាខ្មាំង ឬជាពួកក្បត់ អាចត្រូវបានចាប់ខ្លួនដោយក្រុមសន្តិសុខ ធ្វើទារុណកម្ម បង្ខំសួរចម្លើយ ដើម្បីឆ្លើយដាក់អ្នកដទៃទៀត ហើយក្រោយមកត្រូវគេសម្លាប់ចោល។ សិទ្ធិអំណាចក្នុងការចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ គឺកើតមានឡើងជាផ្លូវការ ឬមិនផ្លូវការពីមជ្ឈិម ចុះរហូតទៅដល់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក រហូតធ្លាក់ទៅដល់ថ្នាក់សហករណ៍ឯណោះ និងនៅក្នុងចំណោមជួរកងទ័ព។ ហើយការប្រើប្រាស់ការធ្វើទារុណកម្មនេះ ត្រូវបានបង្កើតឡើងដោយតាមរបៀបរបបច្រើន ដោយយោងទៅតាមចំនួនខ្មាំង។ ហើយនៅក្នុងពេលជាមួយគ្នានេះ ការខកខានខាងផ្នែកយោធា និងនយោបាយរបស់បដិវត្តបណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងច្រើន ហើយមានការចោទប្រកាន់តែច្រើនៗឡើង ថាមានការក្បត់នៅក្នុងជួរបក្ស ដែលនាំឲ្យកើតមាននូវអំពើប្រល័យពូជសាសន៍។ បើទោះណាជាមិនមានផែនការបែបដូច្នោះក៏ដោយ"។ បញ្ចប់ការដកស្រង់សម្តី អៀង សារី។

[១១:៤១:១៨]

នៅត្រង់នេះ លោកលើកឡើងចំណុច៤៧ ទៅលើ អៀង សារី ហើយទី១ ចំណុចទី២ ចំណុចទី៣ និងចំណុចទី៤។ សំណួររបស់ខ្ញុំ តើលោកលើកយកចំណុចទាំងបួននេះ ឬក៏លោកសរសេរជាចង្កោមសំណួរយ៉ាងដូច្នេះ មុននឹងលោកសួរពាក្យនេះ ទៅលោក អៀង សារី នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអន្តរាគមន៍នៅពេលនេះ ព្រោះថាយើងចូលដល់ដែនកំណត់មួយដែលស្មុគស្មាញ។ ខ្ញុំសូមពន្យល់។ ខ្ញុំយល់អំពីរបៀបដែលសហព្រះរាជអាជ្ញាចោទសំណួរនេះ។ គឺជារបៀបមួយដែលមានល្បិច។ ដើម្បីឲ្យនិយាយអំពីបទប្រល័យពូជសាសន៍ដោយលោក ស្ទីវ ហេដឌ័រ។ ខ្ញុំសូមរំឭកថា ដូចដែលយើង

បានលើកឡើង លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានលើកឡើង នៅពេលដែលគាត់សួរសំណួរទៅអ្នកជំនាញ ហ្វីលីព ស្សូត អំពីបញ្ហានៃការកំណត់និយម ឬក៏ការកំណត់បទចោទ ដែលមិនអាចនិយាយចេញពីអ្នកជំនាញនោះទេ។ អ៊ីចឹងលោក ហេងឌ័រ មិនមែនអ្នកជំនាញទេ។ អ៊ីចឹងគាត់មិនអាចនិយាយបានទេ។ អ៊ីចឹងការសម្ភាសរបស់លោក ស្ទីវ ហេងឌ័រ ជាមួយ អៀង សារី ដែលមានឯកសារដាក់ចូលធ្វើជាភស្តុតាងហើយ ក៏ប៉ុន្តែយើងនៅទីនេះ យើងសុទ្ធតែជាអ្នកច្បាប់ ហើយយើងដឹងថាសំណួរដែលសហព្រះរាជអាជ្ញាទើបតែចោទទៅលោក ស្ទីវ ហេងឌ័រ ហ្នឹង គឺថាចង់សំដៅ ចង់និយាយអំពីការកំណត់បទចោទ ប្រភេទបទចោទ។

[១១:៤៣:៣០]

អ៊ីចឹងសូមរំឭកពីសំណួរដែលលោក ស្ទីវ ហេងឌ័រ លើកឡើងទៅលោក អៀង សារី នេះ ឡើងវិញ។ សហព្រះរាជអាជ្ញាដែលសួរនេះ គឺថាមិនអាចនិយាយលម្អិតអំពីបញ្ហាកំណត់បទចោទនេះទេ ហើយពីព្រោះថាវាជាការកំណត់ប្រភេទបទចោទ ហើយនិងការផ្តល់គំនិតផ្ទាល់ខ្លួន។ អ៊ីចឹង ក្នុងដំណាក់កាលយើងនេះនៃការជម្រះសេចក្តីយើងនេះ យើងមិនត្រូវអនុញ្ញាតឲ្យសួរបែបនេះទេ លោកប្រធាន។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន គោលបំណងនេះ មិនមែនអំពីបញ្ហាប្រល័យពូជសាសន៍ដែលជាបទល្មើសស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការនេះទេ។ ខ្ញុំមិនដឹងថា តើមេធាវីការពារក្តីនៅទីនេះទេ កាលពីសប្តាហ៍មុន ប៉ុន្តែខ្ញុំបានលើកឡើងហើយ គឺថាសំណួរត្រូវតែសួរទៅដល់ភស្តុតាងដែលសាក្សីបានសម្ភាសនៅពេលនោះ។ ដូច្នេះ ខ្ញុំគ្រាន់តែសួរអំពីកិច្ចសម្ភាសន៍របស់គាត់ជាមួយប្រជាជននៅពេលនេះ។ ខ្ញុំមិនបានផ្តួចផ្តើមឡើងសួរអំពីអំពើប្រល័យពូជសាសន៍។ ថាតើគាត់រៀបចំនឹងសំណួរបួននេះសួរទៅអ្នកដែលគាត់សម្ភាសដោយរបៀបណា?

សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបន្តទៅទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដោយជាក់លាក់តែម្តង គឺថាយើងយល់ព្រមឲ្យសួរ និយាយអំពីកិច្ចសម្ភាសន៍របស់លោក ស្ទីវ ហេងឌ័រ ហើយនិងលោក អៀង សារី ក៏ប៉ុន្តែបញ្ហាគឺថា នៅពេលដែលយើងនិយាយពី

ការកំណត់ប្រភេទបទចោទដែលមិនមែននៅក្នុងវិសាលភាពការជម្រះសេចក្ដីយើង ហើយជាការកំណត់ប្រភេទបទចោទរបស់លោក ស្ទីវ ហេដឌ័រ ធ្វើទេ ជាគំនិតផ្ទាល់ខ្លួនរបស់គាត់។ អ៊ីចឹងខ្ញុំមិនយល់ទាស់អីទេ ក៏ប៉ុន្តែនៅពេលដែលព្រះរាជអាជ្ញាលើកបញ្ហានិយាយមកដូចថាយោងតែទៅលើកិច្ចសម្ភាសន៍នេះទាំងស្រុងនេះ គឺថាវាមិនពាក់ព័ន្ធនឹងផ្នែកច្បាប់ទេ។ វាមិនមែនជាបញ្ហាធម្មតាទេនៅទីនេះ។ បើយើងឧទាហរណ៍បើយើងមានកិច្ចសម្ភាសន៍របស់លោក ស្ទីវ ហេដឌ័រ ជាមួយអ្នកផ្សេងៗជាច្រើននោះ ហើយគាត់មិននិយាយអំពីការកំណត់ប្រភេទបទចោទនោះៗ មិនបញ្ហាអ្វីទេ។ ប៉ុន្តែទាក់ទងទៅ-- ទាក់ទងទៅនឹងការកំណត់ប្រភេទបទចោទ ហើយនិងទាក់ទងទៅនឹងរបៀបសួររបស់សហព្រះរាជអាជ្ញានេះនោះ វាមិនត្រូវលើកមកនិយាយកន្លែងនេះទេ។ ហើយជាពិសេសហ្នឹងលោក ស្ទីវ ហេដឌ័រ ហ្នឹងគាត់មិនមែនជាអ្នកជំនាញនោះទេ។ អ៊ីចឹងកាលណាយើងសួរសំណួររបៀបបែបនេះ គឺថាកាលមុននោះចៅក្រមមិនបានអនុញ្ញាតទេ ពេលដែលគេសួរទៅលោក ហ្វីលីព ស្ប៊ត នោះ។ អ៊ីចឹង សូមឲ្យគោរពសេចក្ដីសេចក្ដីរបស់តុលាការពីមុនមក សួរបែបនេះមិនអនុញ្ញាតទេពីមុននោះ។

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសន្យាថាឈប់ប្រើពាក្យ “ប្រល័យពូជសាសន៍” ទៀតហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៧:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានផ្ដល់នាទីឲ្យខ្ញុំថាឲ្យខ្ញុំហ្នឹងបដិសេធដល់ការជំទាស់របស់ -- ការសម្ភាសលោក អៀង សារី នោះផ្សេង ហើយនិងការវិភាគផ្នែកលើបទប្រល័យពូជសាសន៍ហ្នឹងខុសៗគ្នា។ អ៊ីចឹងលោកសហព្រះរាជអាជ្ញាអាចបន្តសំណួរបាន។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោក ហេដឌ័រ លោករៀបចំចំណុចប្អូននៅពេលដែលលោកចាប់ផ្ដើមធ្វើកិច្ចសម្ភាសន៍។ សូមលោកបញ្ជាក់ចំណុចនេះបន្តិច។

[១១:៤៨:១៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ដោយសារតែឧបសគ្គនៃការធ្វើដំណើររបស់ខ្ញុំទៅកាន់ប៉ៃលិនដោយអាជ្ញាធរថៃ នៅពេលហ្នឹង គឺថា អៀង សារី ត្រូវធ្វើដំណើរពីប៉ៃលិនទៅចាន់បុរីដើម្បីជួបខ្ញុំនៅទីនោះ។ យើងមានពេលវេលាច្រើនដើម្បីរៀបចំ។ តាមការចងចាំរបស់ខ្ញុំ ដោយសារតែពេលនោះខ្ញុំត្រូវចាប់ផ្ដើមធ្វើការស្រាវជ្រាវដើម្បីសញ្ញាប័ត្រ ភី.អេជ.ឌី បណ្ឌិតរបស់ខ្ញុំ ខ្ញុំត្រូវរកចំណុចណាដែលត្រូវមកសួរ។ ចំណុចដែលត្រូវមកសួរនោះ គឺថាពេលនោះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់យល់អំពីបញ្ហាផ្លូវច្បាប់អីនោះទេ។ ហើយខ្ញុំដឹងដោយសារខ្ញុំមើល -- ហើយខ្ញុំមិនដឹងថា -- ហើយ អៀង សារី ហ្នឹងក៏អត់មានសញ្ញាណាមួយដែលគាត់ដឹងអំពីច្បាប់ទម្លាប់នោះដែរ។ គឺខ្ញុំមិនបានគិតឃើញថាប្រើពាក្យ “ញុះញង់”អីដើម្បីទទួលបានចម្លើយពីគាត់នោះទេ ដើម្បីឆ្លើយមកនឹងចំណុចទាំងបួនដែលខ្ញុំបានលើកឡើងនៅពេលនោះទេ។

[១១:៤៩:៣១]

**ស៖** ឥឡូវហ្នឹងឆ្លើយពាក់ព័ន្ធទៅនឹងចម្លើយរបស់ អៀង សារី ទៅនឹងចំណុចទាំងបួន។ ពាក្យរបស់ អៀង សារី ទី១ គឺថា ខ្ញុំៗក៏ឃើញថារឿងវាកើតឡើងតាមរបៀបនេះដែរ។ តើនេះជាការឆ្លុះបញ្ចាំងនូវអ្វីដែល អៀង សារី បានប្រាប់ទៅលោក ឆ្លើយទៅនឹងសំណួរទី១របស់លោកដែរឬទេ?

**ឆ៖** បាទ។

**ស៖** ក្នុងឃ្លាទី៣ អៀង សារី ឬក៏ឯកសារហ្នឹងនិយាយថា អៀង សារី ឆ្លើយថា៖ “ប៉ុន្តែដូចដែលលោកទើបលើកឡើង អំពើដែលប្រព្រឹត្តឡើងដោយមនុស្សមួយចំនួន ដែលពួកគេបណ្ដាលឲ្យមានការឈឺចាប់ដល់ប្រជាជនយ៉ាងច្រើន។ នេះតាមការយល់ឃើញរបស់ខ្ញុំទៅលើការយល់ឃើញរបស់លោក”។ តើលោកអាចបញ្ជាក់បានទេ ថានេះគឺជាអ្វីដែលលោកឆ្លើយទៅនឹងសំណួរ ជាចម្លើយទៅនឹងសំណួរទី១របស់លោកឬ?

**ឆ៖** បាទ។

**ស៖** ហើយមានការតក់ត្រាបន្តទៅទៀតនូវនឹងចម្លើយរបស់ អៀង សារី ឆ្លើយទៅលោក “ដូច្នេះដូចដែលលោកលើកឡើងអីចឹង ដោយសារតែបដិវត្តន៍ត្រូវបានគេធ្វើឲ្យជួបប្រទះនូវបញ្ហាកាន់តែច្រើនឡើងៗ ចំនួនមនុស្សដែលគេចោទថា ធ្វើខុស។ ខ្ញុំគិតឃើញថា ខ្ញុំយល់ឃើញថាគ្មានទោសពៃរ៍អ្វីដូចលោកយល់អីចឹងដែរ”។ តើនេះគឺជាអ្វីដែលលោកឆ្លើយទៅនឹងសំណួររបស់លោកនោះទេ?

[១១:៥១:២៤]

**ឆ៖** បាទ។

**ស៖** ហើយការកត់ត្រានេះបន្តទៅទៀតថា "អៀង សារី៖ ហើយចំណុចពីររបស់លោក ទី១ គឺថាចំណុចនេះអាចត្រូវបានគេធ្វើឡើងដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាមានមូលដ្ឋានគ្រឹះ កាន់តែជឿនលឿនលឿនជាងវៀតណាម។ ដូច្នេះ វៀតណាមិនអាចរត់ទាន់យើងទេ ហើយនិងមិនអាចមកត្រួតត្រាកម្ពុជាបាននោះទេ។ នេះគឺជាការពិតហើយ នេះគឺជាការពិតទាំងស្រុង នេះគឺជាការយល់ឃើញរួមនៅក្នុងចំណោមថ្នាក់ដឹកនាំ"។ តើនេះគឺជាអ្វីដែលលោក អៀង សារី ឆ្លើយទៅនឹងសំណួររបស់លោកមែនទេ?

**ឆ៖** បាទ។ ខ្ញុំគិតថាឃើញថា ប្រហែលជាដោយសារ ជាពិសេសគឺថាយើងដាក់ជាអង់គ្លេស "*អ៊ុន វៀតណាម*" លឿនជាងនៅវៀតណាម។

[១១:៥២:៣២]

**ស៖** សំណួរទី២ របស់លោក គឺបន្ទាប់ -- អង់គ្លេស 00417600, ខ្មែរ 00062453។ "សំណួរដោយ ស្ទីវិន ហេដឌ័រ៖ តើពីចំណុចណា -- ចាប់ផ្តើមពីចំណុចណាទៅ ដែលនាំឲ្យមានការធ្វើសេចក្តីសម្រេចចិត្ត និងការយល់ជារួមទៅត្រូវតែធ្វើកិច្ចការក្នុងលក្ខណៈបែបហ្នឹង? ចម្លើយរបស់ អៀង សារី ទី២៖ គឺថានៅពេលដែលយើងទទួលបានជ័យជម្នះពីពួកចក្រពត្តិឈ្លានពាន។ សញ្ញានេះត្រូវបានបង្កើតឡើងតាំងពីពេលនោះមកម្ល៉េះ ក៏ប៉ុន្តែរហូតមកដល់ចុងឆ្នាំ១៩៧៥ ដែលថាវាជាការចាំបាច់បំផុតដែលត្រូវអនុវត្តរបបកុម្មុយនីស្តឲ្យបានជឿនលឿន ដើម្បីកុំឲ្យយួនវាមកលេបទឹកដីកម្ពុជា។ នេះគឺជាអំពើដែលត្រូវបាន -- ដែលទើបយើងចាប់ផ្តើមធ្វើសកម្មភាពនេះឡើង។ ប៉ុន្តែគំនិតយោបល់ដែលថាវៀតណាមអាចនឹងលេបត្របាក់ទឹកដីកម្ពុជា វៀតណាមអាចនឹងចូលគ្រប់គ្រងកម្ពុជាចាប់តាំងពីពេលនោះមក"។ ថាតើនេះវាឆ្លុះបញ្ចាំងនូវអ្វីដែល អៀង សារី បានប្រាប់លោកនៅពេលដែលលោកសម្ភាសគាត់នៅពេលនោះឬយ៉ាងណា?

**ឆ៖** បាទ។

[១១:៥៤:១៦]

**ស៖** សំណួរបន្ទាប់សួរដោយ "លោក ស្ទីវ ហេដឌ័រ៖ តើមានកិច្ចប្រជុំនៅថ្នាក់គណៈមជ្ឈិមដែរទេ នៅចុងឆ្នាំ១៩៧៥ ដែលគោលដៅជាក់លាក់មួយចំនួនត្រូវបានគេកំណត់ឡើង? អៀង សារី ឆ្លើយ៖ នៅខែកញ្ញា ១៩៧៥ មានកិច្ចប្រជុំមួយដែលត្រូវសម្រេច ថាតើយើងត្រូវធ្វើយ៉ាងម៉េច ដើម្បីកុំឲ្យវៀត-

ណាមមកត្រួតត្រាកម្ពុជា”។ សំណួររបស់លោក៖ “តើចំណុចនេះសម្រេចឡើងដោយគណៈអចិន្ត្រៃយ៍ ឬដោយគណៈកម្មាធិការមជ្ឈិម? ឆ្លើយ៖ គឺគណៈអចិន្ត្រៃយ៍ទេ មិនមែនគណៈមជ្ឈិមទេ គឺគណៈអចិន្ត្រៃយ៍”។ ស្មីវ ហេដឌ័រ សួរ៖ អ៊ីចឹងក្នុងនោះតើអ្នកណាខ្លះនៅក្នុងគណៈអចិន្ត្រៃយ៍ហើយអ្នកណាចូលរួមប្រជុំ? អៀង សារី ឆ្លើយ៖ គណៈអចិន្ត្រៃយ៍ហ្នឹងបើតាមខ្ញុំមើលទៅសឹងតែទាំងអស់គ្នាហ្នឹងគឺថា ប៉ុល ពត, នួន ជា, សោ ភឹម, ខ្ញុំ, សុន សេន និង តាម៉ុក? ស្មីវ ហេដឌ័រ សួរ៖ តាម៉ុកដែរ។ ចុះ វ៉ន វេត ដែរឬទេ? អៀង សារី ឆ្លើយ៖ វន វេត បាទគឺ វន វេត ហ្នឹងដែរ។ ស្មីវ ហេដឌ័រ សួរ៖ ចុះ ខៀវ សំផន? “អត់ទេ ក៏ប៉ុន្តែខៀវ សំផន មានវត្តមានដែរ”។ “បាទ មានវត្តមានប៉ុន្តែមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេឬ?” អៀង សារី ឆ្លើយ៖ គាត់មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ។ ស្មីវ សួរ៖ ចុះតាញឹម មកពីខាងភូមិភាគពាយ័ព្យ? អៀង សារី ថា៖ ភូមិភាគពាយ័ព្យកាលហ្នឹងគាត់មិនទាន់ចូលជាសមាជិកអចិន្ត្រៃយ៍នៅឡើយទេ ប៉ុន្តែគាត់បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ។ កុយ ធួន ហ្នឹងក៏ចូលរួមប្រជុំដែរ។ ក៏ប៉ុន្តែគាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ ខ្ញុំចាំបានប៉ុណ្ណឹង។ ស្មីវ ហេដឌ័រ សួរ៖ អស់ហើយ? អៀង សារី ថា៖ មានមេទ័ពមួយចំនួនដែរ មានមេទ័ពដែរ។ បញ្ចប់ការដកស្រង់។ តើនេះគឺជាកំណត់ត្រាត្រឹមត្រូវនូវអ្វីដែល អៀង សារី ឆ្លើយទៅនឹងលោក ពេលលោកសម្ភាសគាត់នោះឬយ៉ាងណា?

[១១:៥៦:៤៤]

**ឆ៖** បាទអ៊ីចឹងហើយ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ ខ្ញុំមិនបង្ហាញឯកសារនេះទេ ដោយសារខ្ញុំមិនមានពេលវេលាច្រើន។ តាមព័ត៌មានអង្គហេតុដែលលោកដឹង ដោយមិនត្រូវស្មាន មិនត្រូវបញ្ចេញជាគំនិតយោបល់ផ្ទាល់ខ្លួន ដោយយោងតែកិច្ចសម្ភាសន៍ដែលលោកបានសម្ភាស ឬក៏អង្គហេតុជាក់ស្តែងណានោះ តើមានព័ត៌មានអង្គហេតុណាមួយអំពីការជម្លៀសប្រជាជនជាបន្តបន្ទាប់ក្នុងចំនួនដ៏ច្រើនពីកន្លែងណាមួយនៃប្រទេសកម្ពុជាទៅកាន់ភូមិភាគពាយ័ព្យដែរឬទេ ក្រោយខែមេសា ១៩៧៥។ អ៊ីចឹងខ្ញុំមិនសួរលោក អំពីការជម្លៀសប្រជាជននៅថ្ងៃ ១៧ មេសា ៧៥ នោះទេ។ ខ្ញុំសួរថាតើមានការជម្លៀសប្រជាជនជាក្រោយៗមកទៀតទេ?

**ឆ៖** បាទ មានការនិយាយអំពីរឿងនេះច្រើន។ តាមការសម្ភាសរបស់ខ្ញុំទាក់ទងទៅនឹងពេលនោះ ខ្ញុំសិក្សាស្រាវជ្រាវអំពីអត្រាមរណៈវាមានចង្កោមសំណួរ ដែលខ្ញុំសួរទៅអ្នកដែលខ្ញុំត្រូវសម្ភាស

ថាតើគេនៅត្រង់ណា នៅទីណានៅក្នុងរបបខ្មែរក្រហមពី៧៥ ទៅ៧៩ ហ្នឹង។ ប្រហែលជា១៥០០នាក់ ខ្ញុំសម្ភាសបើតាមខ្ញុំចាំ ខ្ញុំសាកសួរនោះ និយាយខ្ញុំសួរៗចង់ដឹងអំពីអត្រាមរណៈ ហើយថាតើប្រជាជនត្រូវបានគេជម្លៀសក្រោយពី៧៥ មកពីកន្លែងមួយទៅកន្លែងមួយទៀតទេ ហើយប្រជាជនជាច្រើនឆ្លើយថាពួកគាត់ត្រូវបានគេជម្លៀសជាបន្តបន្ទាប់យោងទៅតាមចង្កោមសំណួរនេះមានអ្នកឆ្លើយជាច្រើនបញ្ជាក់ថា ទោះបីជាខ្ញុំសួរដាច់ដោយឡែកយ៉ាងណាក៏ដោយ គឺថាមានការរៀបរាប់បញ្ជាក់ប្រាប់ខ្ញុំថាមានការជម្លៀសក្រោយៗទៀតជាបន្ទាប់។ ជាពិសេស ជម្លៀសចេញពីភូមិភាគនិរតី និងភូមិភាគបូព៌ាឆ្ពោះទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគបស្ចិមនៅពេលនោះ។

[១១:៥៩:៣២]

**សះ** តើព័ត៌មានដែលលោកកំពុងតែយកមកយោងនេះ ថាតើការជម្លៀសនេះជាការជម្លៀសដោយស្ម័គ្រចិត្ត ឬក៏ជាការជម្លៀសដោយបង្ខំ?

**ឆះ** ទាំងពីរហ្នឹងបើតាមដែលខ្ញុំអាចនិយាយទៅបាន។ ខ្ញុំមិនបានវិភាគអំពីទូរលេខនោះ តែប្រជាជនខ្លះគាត់ត្រូវបានគេអូសទាញ បញ្ចុះបញ្ចូលនូវអ្វីដែលគេប្រាប់ពួកគាត់ថា កាលណាទៅកន្លែងថ្មីនៅភូមិភាគពាយព្យហ្នឹងគឺមានចំណីចំណុក មានបាយទឹកហ្នឹងគ្រាន់បើជាង ហើយនៅ -- មកពីភូមិភាគបូព៌ាក៏គេនិយាយអ៊ីចឹងដែរ។ ហើយរហូត -- នេះគឺជាអ្វីដែលប្រជាជនកម្ពុជាជឿជាក់យ៉ាងធំធេងថាពេលហ្នឹងនោះ នៅភូមិភាគពាយ័ព្យហ្នឹងគឺជាកន្លែងដែលគេផលិតបានផលស្រូវច្រើនណាស់ ដោយសារតែដីវាទូលំទូលាយ អ៊ីចឹងការដកស្ទូងហ្នឹង គឺថាវាបានផលច្រើន។ ដូច្នេះ បើសិនណាជាពួកគាត់ទៅដល់ភូមិភាគពាយ័ព្យហ្នឹង ជីវិតរស់នៅប្រហែលជាគ្រាន់បើ។ អ្នកខ្លះគាត់ស្ទាក់ស្ទើរដែរ គាត់ស្ទាក់ស្ទើរចំពោះផលដំណាំដែលគាត់ដកស្ទូងហើយនៅកន្លែងគាត់ហើយនៅចុងឆ្នាំ១៩៧៥ គាត់គិតអំពីថា យើងខំប្រឹងប្រែងដកស្ទូងដល់ហើយ។ ដូច្នេះបើយើងចេញទៅគេនឹងស៊ីស្រូវអង្ករយើងទាំងអស់ហើយ។ ហើយអ្នកណាទៅដឹងការធ្វើដំណើរទៅភូមិភាគពាយ័ព្យ ឬបស្ចិមនោះ ដូច្នេះមានប្រជាជនខ្លះគាត់ថាគាត់ត្រៀមខ្លួនរួចរាល់ដើម្បីទៅ អ្នកខ្លះអត់ចង់ទៅទេ។

[១២:០១:១៣]

**សះ** ចុះអ្នកដែលមិនចង់ទៅនោះវិញនោះ សូមលើកឧទាហរណ៍បន្តិចបានទេ? តើមានការបង្ខំដោយរបៀបណា ដោយមធ្យោបាយណា ដើម្បីអូសទាញពួកគេឲ្យទៅកាន់តំបន់មួយដែលគេថាមានស្រូវអង្កររហូបចុកច្រើនហ្នឹង?

**ឆ៖** ខ្ញុំនិយាយដោយងាយ គឺគេប្រាប់ប្រជាជនថា ត្រូវតែទៅទោះពួកគេមិនចង់ទៅក៏ដោយចំនួនមនុស្សដ៏ច្រើនលើសលប់ត្រូវទៅ គឺជាការចាំបាច់ដែល គឺថាពួកគេដឹងថានឹងមានអ្វីកើតឡើងបើគេមិនទៅទេ។ បើមិនគោរពតាមបញ្ជាទេ គឺត្រូវបានគេចាប់ខ្លួនយកទៅដាក់ក្នុងមន្ទីរសន្តិសុខ ហើយក្រោយមកអាចនឹងត្រូវគេយកទៅសម្លាប់ចោល។

**ស៖** ទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅក្រោយពីទៅដល់ទីនោះ តើវាពាក់ព័ន្ធទៅដល់ជីវភាពរស់នៅ ឬវាពាក់ព័ន្ធទៅដល់ការស្លាប់អីដែរឬទេ? តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើលក្ខខណ្ឌរស់នៅរៀបម៉េចដែរ ក្រោយគេទៅដល់កន្លែងដែលគេយល់ឃើញថា មានស្រូវអង្ករហូបចុកច្រើនហ្នឹងប៉ុន្មានខែក្រោយមកទៀតនុ៎ង?

[១២:០២:៥៦]

**ឆ៖** ខ្ញុំអាចនិយាយបានថា ជាទូទៅស្ថានភាព គឺកាន់តែអាក្រក់ឡើង នៅបណ្ដាទីកន្លែងដែលគេ -- លើសពីកន្លែងដែលគេធ្លាប់រស់នៅពីមុនទៅទៀត។

**លោក ឃីត វេយ៍ន័រ៖**

លោក ហេងឌ័រ សូមអរគុណ។ ខ្ញុំសល់ពេលបន្តិចបន្តួចដែរ ខ្ញុំសូមបញ្ជាក់ថា ឥឡូវនេះខាងការិយាល័យសហព្រះរាជអាជ្ញាអស់សំណួរហើយ។ ខ្ញុំសូមជូននាទីនេះទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីតាំងសំណួរទៅទៀតមុននឹងឈប់សម្រាកពិសាបាយថ្ងៃត្រង់នេះ។

សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមមានសំណើមួយលឿនទេ ថាតើលោកប្រធានគិតថា នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីបញ្ចប់ទៅនៅសារណានិងសំណើរបស់ -- ចុងបញ្ចប់ទៅ តើនឹងអាចស្ដាប់សំណើនិងសារណារបស់យើងយខ្ញុំការស្នើសុំកាលពីសប្ដាហ៍មុនបានទេ?

[១២:០៤:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការរំឭកលើសំណើនោះ។ អង្គជំនុំជម្រះនឹងធ្វើកិច្ចការនោះនៅក្រោយពេល

ដែលអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីរូបនេះ ដែលនឹងសួរដេញដោលដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមមេធាវីជ្រាប។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីឬទីកន្លែងណាមួយនៅជិតសាលសវនាការនេះសម្រាប់សាក្សីរូបនេះ សម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅវេលាម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:១២]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីវ ហេងឆ័រ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាសួរអស់លោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី។ ជម្រាបសួរសហភាតាទាំងអស់។ ខ្ញុំឈ្មោះ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**ស៖** ខ្ញុំចោទសំណួរទៅកាន់លោកមួយចំនួន មិនយូរដូចសហព្រះរាជអាជ្ញាទេ។ លោកបានឆ្លើយនៅថ្ងៃទី១០ កក្កដា ទៅសហព្រះរាជអាជ្ញាថា ក្រៅពីឯកសារដែលបានដាក់បញ្ចូលតៅសំណុំរឿង ក្រៅពីឯកសារនៅក្នុង *ក្លាសសឺ* ទាំងប៉ុន្មានដែលលោកមាននៅចំពោះមុខលោកនេះ។ លោកបានក៏សរសេរផងដែរ នូវឯកសារជាច្រើនទៀត ហើយនិងបានផ្តល់កិច្ចសម្ភាសន៍ជាច្រើនទៀតដែរ។ ខ្ញុំចោទសំណួរទាក់ទងទៅនឹងឯកសារដែលមាននៅក្នុងសំណុំរឿង ហើយនិងឯកសារផ្សេងៗទៀត ពីព្រោះថាលោកជាសាក្សី ហើយលោកអាចផ្តល់សក្ខីកម្មលើអ្វីដែលលោកបានឃើញ។ ហើយសំណួរខ្ញុំនឹងផ្តល់ទៅលើដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះជាទូទៅ។

[១៣:៣៥:៣៥]

ខ្ញុំនឹងចាប់ផ្តើមនិយាយអំពីប្រធាបបទទី១ ដែលខ្ញុំចាប់អារម្មណ៍ចាប់ពីថ្ងៃទី០១ ឧសភា ឆ្នាំ១៩៧៣ ទៅដល់ឆ្នាំ៧៥ លោកនិយាយថា លោកនៅប្រទេសកម្ពុជានៅភ្នំពេញកាលណោះ ក្នុងរយៈពេលនុ៎ង។ ហើយលោកបានជម្រាបថា លោកបានស្តាប់ជនភៀសខ្លួនមិនច្រើនប៉ុន្មាន។ អានេះបើតាមខ្ញុំស្តាប់ឮតាមរយៈការបកប្រែជាភាសាបារាំងកាលពីព្រឹកមិញ។ អ៊ីចឹងទោះបីជាមានមិនសូវច្រើនក៏ដោយ ខ្ញុំចង់ដឹងថា តើពួកគាត់បាននិយាយអ្វីប្រាប់លោកខ្លះ ចន្លោះពីឆ្នាំ៧៣ ទៅដល់ឆ្នាំ៧៥នេះ។ លោកបាននិយាយថាជនភៀសខ្លួនដែលមកពីរំដោះ។ សំណួរទី១របស់ខ្ញុំដូចតទៅនេះ តើពួកគាត់មានបាននិយាយទាក់ទងទៅនឹងលក្ខខណ្ឌជីវភាពរបស់ប្រជាជននៅតំបន់រំដោះដែរឬទេ? ពួកគាត់មានបាននិយាយប្រាប់ចំណុចនេះដែរឬទេ? ហើយបើបាននិយាយប្រាប់វិញនោះ តើនិយាយអ្វីខ្លះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ក្នុងរយៈពេលនោះ គឺពីឆ្នាំ១៩៧៣ដល់១៩៧៥ គឺថាខ្ញុំមិនមានព័ត៌មានអ្វីច្រើនអំពីស្ថានភាពនៃតំបន់រំដោះនោះទេ។ ព្រោះថានៅពេលហ្នឹង គឺខ្ញុំមានព័ត៌មានទូទៅទេ ទាក់ទងទៅនឹងការរៀបចំក៏ដូចជាការដំណើរការនានា ហើយខ្ញុំមានការពិភាក្សាមួយចំនួនទាក់ទងទៅនឹងការផលិតស្រូវអង្ករដែល

ចាប់ផ្តើម ដែលជាការចាប់ផ្តើមនៅសហករណ៍ជាដើមនោះ។ ហើយពេលខ្លះ ខ្ញុំជជែកអំពីការសម្លាប់មនុស្ស ប៉ុន្តែនិយាយជារួមទៅ គឺថាក្នុងរយៈពេលនោះ ខ្ញុំព្យាយាមធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ជាការពិតខ្ញុំមិនបានធ្វើអ្វីបានច្រើននោះទេនៅពេលនោះ។ គឺដូចជាទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់របបខ្មែរក្រហម ដូចជាគោលនយោបាយ ឬក៏បញ្ហាអ្វីៗផ្សេង គឺមិនជាបានច្រើនណាស់ណានោះទេ។ ដូច្នេះ អ្វីដែលខ្ញុំអាចឆ្លើយបាន គឺថាខ្ញុំមានព័ត៌មានតិចតួចបំផុតនៅក្នុងចន្លោះពីឆ្នាំ៧៣ ដល់៧៥នោះ។ គឺថាមិនមានលើសពីអ្វីដែលខ្ញុំបានបញ្ជាក់ប្រាប់រួចមកហើយនោះទេ។ ឧទាហរណ៍ដូចជា ការវាយប្រយុទ្ធ គឺថាត្រូវពួកជប៉ុនប្រាប់ខ្ញុំមកជាដើម ប៉ុន្តែចំពោះព័ត៌មានលម្អិត សូម្បីតែការរៀបរាប់អំពីស្ថានភាពរបស់រំដោះក្រៅពីរចនាសម្ព័ន្ធជាដើម គឺអត់មាននោះទេ។ ហើយនៅពេលនោះ គឺខ្ញុំមានការលំបាកទាក់ទងទៅនឹងទំនៀមទម្លាប់ប្រពៃណី ឧទាហរណ៍ ដូចជាការរៀបចំសហករណ៍ជាដើមអី គឺខ្ញុំមានការលំបាក មិនទទួលបានព័ត៌មានលម្អិតនោះទេ។

[១៣:៣៩:១៣]

**ស៖** ទោះជាយ៉ាងណាក្តី មិនមានការបន្ទោសបង្អាប់អ្វីលើរបៀបស៊ើបអង្កេតរបស់លោកនោះទេ។ ក្រៅពីទីក្រុងឧដុង្គ ហើយនិងនៅកំពង់ចាមដែលលោកបាននិយាយនោះ តើលោកមានបានទៅស៊ើបសួរនៅតំបន់រំដោះផ្សេងទៀតដែរឬទេ នៅសម័យនោះ?

**ឆ៖** ខ្ញុំបានទៅបាត់ដំបងផងដែរ។ ប៉ុន្តែបាត់ដំបងនៅពេលនោះ គឺថាតំបន់រំដោះនៅបាត់ដំបងគឺមានតិចតួចនៅឡើយ គឺវាហាក់ដូចជាមិនមានច្រើននោះទេ។ ដូច្នេះ នៅពេលដែលខ្ញុំទៅដល់បាត់ដំបងគឺថាស្ថានភាពរបស់តំបន់រំដោះនៅបាត់ដំបងគឺមានតិចតួចបំផុត។ ហើយខ្ញុំមិនបានទៅដល់កំពង់ចាមទេរហូតទៅដល់ពេលមួយគឺនៅពេលដែលខ្មែរក្រហមបានកាន់កាប់រួចទៅហើយ ទើបខ្ញុំបានទៅដល់ខេត្តកំពង់ចាម។ ខ្ញុំបាននិយាយជាមួយមនុស្សដែលនៅទីនោះដែរ ប៉ុន្តែភាគច្រើនអ្នកដែលខ្ញុំជួបគឺអ្នកដែលរស់នៅក្នុងទីរួមខេត្ត គឺអ្នកដែលគេបានរត់ចេញពីតំបន់រំដោះមកទីរួមខេត្តជាដើម។ ចំពោះតំបន់ឧដុង្គវិញ គឺខ្ញុំបានជួបមនុស្សតែពីរបីនាក់ប៉ុណ្ណោះ។

**ស៖** ខ្ញុំសូមអរគុណលោកសាក្សី។ ឥឡូវយើងឈប់និយាយពីរយៈពេលចន្លោះ៧៣-៧៥ ហើយយើងនឹងត្រឡប់មកនិយាយអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ដែលលោកបាននិយាយបន្តិចហើយជាមួយសហព្រះរាជអាជ្ញា៣ថ្ងៃចុងក្រោយនេះ ហើយសហព្រះរាជអាជ្ញាបានអានសម្រង់មួយនៃឯកសារ E3/1714។ គឺជាឯកសារដែលលោកបានសរសេរដោយឈរមូលដ្ឋានលើកិច្ចសម្ភាសន៍នូវជន

ភៀសខ្លួននៅដើមឆ្នាំ៨០។ ទាក់ទងទៅនឹងផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ព្រះរាជអាជ្ញាបានសក្ខីកម្មលេខ២៩។ អ៊ីចឹងខ្ញុំសូមអាន ឥឡូវនេះខ្ញុំសូមអានសក្ខីកម្មលេខ១៨ ដែលតាមកំណត់ហេតុរបស់លោក គឺជាមនុស្សម្នាក់ដែលមកពីខេត្តតាកែវ។ លេខ ERN ដូចតទៅនេះ ជាភាសាបារាំងគឺ 00648372 (*ស៊ីក*), អង់គ្លេស 001727(*ស៊ីក*) , ខ្មែរ 00224731 (*ស៊ីក*)។

[១៣:៤២:១៣]

ខ្ញុំអានខ្លីទេ អ៊ីចឹងលោកមិនចាំបាច់មើលលើឯកសារជាក្រដាសទេ។ បុគ្គលនេះរៀបរាប់ដូចតទៅនេះ ខ្ញុំសូមដកស្រង់ “ខ្ញុំមានអារម្មណ៍ថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺជាផ្នែកមួយនៃគោលនយោបាយដែលមានតាំងពីយូរមកហើយ ពីព្រោះថាយើងតែងតែធ្វើយ៉ាងដូច្នេះនៅពេលដែលយើងជម្លៀសមនុស្សចេញពីកន្លែងខ្មាំងសត្រូវ។ នៅក្នុងអតីតកាល យើងបានជម្លៀសមនុស្សចេញដោយសារយើងភ័យខ្លាចក្នុងការកាន់កាប់កន្លែងទាំងអស់នេះនៅពេលដែលមានការវាយបែកមកវិញ។ដូច្នេះគឺថាយើងខ្លាច យើងមិនមានលទ្ធភាពក្នុងការធានាសន្តិសុខឲ្យប្រជាជន។ ហើយមូលហេតុក៏មកផង --ក៏ថាដោយសារយើងខ្វះមនុស្សផងដែរ។ បើសិនជាយើងប្រមូលផ្តុំមនុស្សទាំងអស់នោះ គឺថាយើងនឹងមានកម្លាំងដើម្បីទប់នឹងខ្មាំង។

តាមខ្ញុំដឹង ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមានទិសដៅពីរ។ ១) គឺរក្សាសន្តិសុខដល់របបថ្មីយើង, ២) គឺដោះស្រាយបញ្ហាជីវភាពប្រជាជនថ្មីនេះ។ ដោយហេតុថានៅតាមជនបទមានស្រែចម្ការ ហើយនិងស្រូវ ហើយមានមនុស្សបង្កបង្កើនផលដើម្បីហូបចុក។ អ្វីដែលសំខាន់នោះ គឺថាយើងមិនអាចដឹងដោយច្បាស់ថាអ្នកណាជាមនុស្សមកពីទីក្រុងភ្នំពេញ ហើយយើងមិនដឹងថាអ្នកណាជានាយទាហានរបស់ លន់ នល់ ហើយនិងភ្នាក់ងារ សេ.អ៊ី.អា។ ដូច្នេះយើងខ្លាចខ្មាំងអាចក្រោកឈរប្រឆាំងនឹងយើងបាន”។ សូមបញ្ចប់ការដកស្រង់។ តើលោកអាចបញ្ជាក់អំពីសក្ខីកម្មនេះដែរឬទេ របស់កម្មាភិបាលខ្មែរក្រហមម្នាក់ហ្នឹង?

**ឆ៖** បាទ គឺថាចម្លើយហ្នឹងគឺវាស៊ីគ្នាជាមួយហ្នឹងអ្វីដែលខ្ញុំបានឃើញនៅក្នុងឯកសារ ក៏ដូចជាអ្វីដែលដែលខ្ញុំបានស្តាប់ឮពីការសម្ភាសនានាផងដែរ។

[១៣:៤៤:៣៨]

**ស៖** ខ្ញុំសូមអរគុណ។ លោកក៏បានលើកឡើងផងដែរនៅថ្ងៃទី១១ កក្កដា ទៅកាន់សហព្រះរាជ-អាជ្ញា។ កាលព្រឹកមិញក៏លោកបានលើកឡើងដដែលហ្នឹងដែរ ថាចាប់ពីចុងខែមេសា ៧៥ភ្លាម ហើយ

និងក្នុងសប្ដាហ៍ជាបន្តបន្ទាប់មកទៀត លោកបាននៅព្រំប្រទល់ថៃ ហើយពេលនោះលោកបាននិយាយជាមួយនឹងជនភៀសខ្លួន។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ដែលថាជនភៀសខ្លួនទាំងអស់នោះបានរៀបរាប់អ្វីខ្លះជូនលោក? ឥឡូវយើងចាប់ផ្ដើមនិយាយអំពីមូលហេតុដែលគេជម្លៀសពួកគាត់ចេញនោះ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ?

**ឆ៖** ពួកគាត់ភាគច្រើន គឺមកពីខេត្តបាត់ដំបង ឬក៏ពោធិ៍សាត់ ឬក៏សៀមរាបជាដើម ដែលតំបន់ទាំងនោះគឺវានៅជិតព្រំដែនថៃ ហើយពួកគាត់មួយចំនួនបានរៀបរាប់អំពីការកាប់សម្លាប់។ ជាពិសេសគឺការសម្លាប់មន្ត្រីរដ្ឋការ ឬមួយក៏ទាហានជាន់ខ្ពស់ ដែលមានឋានន្តរស័ក្តិខ្ពស់។ ប្រសិនបើខ្ញុំចាំមិនខុសទេ គឺថានៅកន្លែងទាំងអស់នោះ គឺមានការប្រើប្រាស់ការគំរាមកំហែងពីការទម្លាក់គ្រាប់បែកផងដែរ។ គឺថាវាអាចទៅរួច ដែលថាវាមានការទម្លាក់គ្រាប់បែក ដែលនៅសល់កម្លាំងពួកខ្មែរសាធារណរដ្ឋ ដែលអាចទម្លាក់គ្រាប់បែកបាន ក៏ដូចជាយន្តហោះរបស់ពួកខ្មែរសាធារណរដ្ឋជាដើម។

[១៣:៤៦:៤១]

ប៉ុន្តែនិយាយជាទូទៅ គឺថាពួកគាត់បានប្រាប់ខ្ញុំអំពី -- ការពន្យល់របស់ពួកគាត់ ថាហេតុអ្វីបានគាត់ចាំបាច់ត្រូវចាកចេញពីទីរួមខេត្ត? ដើម្បីឲ្យពួកខ្មែរក្រហមអាចបោសសម្អាតទីក្រុង ក៏ដូចជាការបោសសម្អាតកាកសំណល់ទាហានសាធារណរដ្ឋ។ គឺបោសសម្អាតពួកដែលមានចេតនាចង់ប្រឆាំងជាមួយខ្មែរក្រហម។ ដូច្នេះ នេះគឺគេមិនត្រឹមតែពីទីរួមខេត្តបាត់ដំបងទេ គឺគេបោសសម្អាតនៅគ្រប់កន្លែងនៅក្នុងខេត្តបាត់ដំបង។ ទោះបីថានៅពេលនោះវានៅសល់ វានៅក្នុងរបបខ្មែរសាធារណរដ្ឋនៅឡើយក៏ដោយ។

**សៈ** បាទ សូមអរគុណ។ តើពួកគាត់មានបាននិយាយអំពីលក្ខខណ្ឌនៃការជម្លៀសដែរឬទេ? របៀបជម្លៀសចេញ? ហើយតើគាត់អាចមានទទួលបានការផ្គត់ផ្គង់ផ្នែកចំណីអាហារហូបចុកពីកម្មាភិបាល ឬក៏យោធាខ្មែរក្រហមដែរឬទេ?

**ឆ៖** គឺថាមានការបង្គាប់បញ្ជាយ៉ាងម៉ឺងម៉ាត់ថា អ្នកទាំងអស់គ្នា មនុស្សទាំងអស់ត្រូវតែចាកចេញ ត្រូវតែប្ដូរទីលំនៅ។ ហើយគេធ្លាប់ប្រាប់ខ្ញុំអំពីករណីដែលថាមានការសម្លាប់ប្រសិនបើប្រជាជនមិនចាកចេញ។ ប៉ុន្តែ ខ្ញុំមិនចាំឲ្យច្បាស់លាស់ថាយ៉ាងម៉េចនោះទេ គឺមានការរៀបរាប់ប្រាប់ខ្ញុំអំពីការដែលមានទាហានចូលមកដល់ ហើយទាហានហ្នឹងបានបញ្ជាទៅប្រជាជនថា ប្រសិនបើប្រជាជនមិនចាកចេញ គឺនឹងមានការគំរាមកំហែងសម្លាប់ជាដើម។ ប៉ុន្តែ អ្វីនេះគឺវាកើតឡើងនៅទីក្រុងភ្នំពេញ ហើយប្រជាជនខ្លះគាត់ចង់ចាកចេញ គាត់ចង់ត្រឡប់ទៅទីជនបទ ហើយគាត់គិតថាចំពោះករណីនៅទីរួមខេត្ត គឺវាមាន

តិចជាងនៅភ្នំពេញទេ។ ដូច្នេះវាមិនមែនជាការបង្ខំទាំងស្រុង ឬក៏បង្ខំ១០០ភាគរយនោះទេ។ ដូច្នេះហើយគឺថា ខ្ញុំធ្លាប់បានប្រាប់ទៅដល់ព្រះរាជអាជ្ញារួចទៅហើយ ថាតើប្រជាជនគាត់គិតយ៉ាងម៉េចនៅពេលដំបូងនោះ។ មនុស្សខ្លះ ប្រជាជនខ្លះគាត់មិនគិតថាវាមានអ្វីកើតឡើងប្រសិនបើគាត់ត្រឡប់ទៅទីជនបទនោះទេ។ គាត់គិតថាប្រហែលគ្រាន់តែទៅមួយភ្លែត ឬក៏ត្រឡប់មកវិញជាដើមនោះ។

[១៣:៤៩:៥១]

**ស៖** លោក ឥឡូវនេះ ប្រហែលជាទើបតែនឹងឆ្លើយនឹងសំណួរដែលខ្ញុំរៀបនឹងសួរនេះហើយ។ តើអ្នកដែលភៀសខ្លួនចេញទៅបរទេសនោះ គាត់មានបានរៀបរាប់ពីមូលហេតុទេក្រៅពីលក្ខខណ្ឌដែលគួរឲ្យអាក្រក់នៅតាមជនបទនោះ ហេតុអីបានជាគាត់រត់ចេញទៅក្រៅគាត់មានបានប្រាប់លោកទេ?

**ឆ៖** ពួកគាត់ភាគច្រើនគឺជាអ្នកដែលមានឋានៈខ្ពស់ ទាំងមន្ត្រីរដ្ឋការ ឬក៏ទាហានឋានៈខ្ពស់នៅក្នុងរបបសាធារណរដ្ឋ ហើយអ្នកខ្លះគឺគាត់ជាមន្ត្រីសល់តាំងពីរបបសង្គមរាស្ត្រនិយម។ ដូច្នេះព័ត៌មាន គឺពាក្យចចាមអារ៉ាម វាចែករំលែក គឺថាវាខ្សឹបតៗគ្នាបានយ៉ាងលឿន ដែលនិយាយអំពីមន្ត្រីរដ្ឋការ ឬក៏ទាហានដែលគេប្រមូលផ្តុំយកទៅ ហើយគេប្រាប់ឲ្យស្វែងរកការងារចាស់ៗរបស់ខ្លួនធ្វើឡើងវិញជាដើម ហើយបន្ទាប់មកឮថាពួកគាត់ទាំងអស់នោះត្រូវបានគេយកទៅសម្លាប់ជាដើម។ អានេះគឺជារឿងរ៉ាវដែលគេជម្រាបប្រាប់ខ្ញុំអំពីការកាប់សម្លាប់ជាទ្រង់ទ្រាយធំនៅភ្នំធិបតីក្នុងខេត្តបាត់ដំបង ហើយដោយសារតែហេតុផលទាំងអស់នេះហើយដែលធ្វើឲ្យពួកគាត់ -- គឺពួកគាត់និយាយប្រាប់ខ្ញុំអំពីរឿងរ៉ាវទាំងអស់នេះគឺរឿងរ៉ាវនៃការប្រមូលផ្តុំទាហាននិងមន្ត្រីរដ្ឋការជាដើមនោះ។

[១៣:៥១:៤៣]

ហើយពួកគាត់ក៏បានប្រាប់ផងដែរអំពីករណីមួយចំនួន ដូចជា អតីតមន្ត្រីឬក៏ទាហានខ្មែរសាធារណរដ្ឋត្រូវបានគេសម្លាប់។ ប៉ុន្តែមិនមែនសម្លាប់ដោយពួកខ្មែរក្រហមទេ គឺសម្លាប់ដោយពួកទាហានខ្មែរសាធារណរដ្ឋគ្នាឯងនោះ។ ប៉ុន្តែអានេះវាជាហេតុការណ៍មួយកើតឡើងនៅក្នុងខេត្តសៀមរាប។ វាមិនមែនជាហេតុការណ៍ទូទៅនោះទេ។ ដូច្នេះ ខ្ញុំចង់បញ្ជាក់នៅពេលនេះ គឺថាមិនមែនការកាប់សម្លាប់ទាំងអស់សុទ្ធតែកើតឡើងដោយសារតែពួកខ្មែរក្រហមទេ គឺមានពួកទាហានខ្មែរសាធារណរដ្ឋក៏កាប់សម្លាប់គ្នាឯងផងដែរ។ ហើយក៏មានការកាប់សម្លាប់មួយចំនួនដោយសារតែអ្នកខ្លះគាត់មិនពេញចិត្តជាមួយខ្មែរពួកខ្មែរសាធារណរដ្ឋ ពួកលន់នល់ ជាដើមនោះ។ ដោយសារតែហេតុផលទាំងអស់នេះហើយទើបធ្វើឲ្យពួកគាត់មួយចំនួនគាត់រត់ភៀសខ្លួនពីប្រទេសកម្ពុជាចេញទៅបរទេស។

**ស៖** បាទ សូមអរគុណដែលបានធ្វើការបំភ្លឺទាំងអស់នេះ។ ដូចខ្ញុំបានធ្វើដូចសព្វដងដែរ ខ្ញុំសូមអានសម្រង់មួយនៃដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំនឹងចោទសំណួរទាក់ទងនឹងសម្រង់នេះ។ បាទជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺ D22/306 គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាយុ១៨ឆ្នាំនៅឆ្នាំ១៩៧៥។ ERN ដូចតទៅនេះ គឺជាភាសាបារាំង គឺ 00898083, ជាភាសាអង់គ្លេស គឺ 00864058, ជាភាសាខ្មែរគឺ 00484385 ដល់ 86។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនិយាយដូចតទៅនេះ -- គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។

[១៣:៥៣:៥០]

"នៅពេលដែលអង្គការ បានប្រាប់ឲ្យយើងរៀបចំអីវ៉ាន់ ក្រុមគ្រួសាររបស់ខ្ញុំបានចាប់ផ្តើមធ្វើរៀបចំអីវ៉ែអីវ៉ាន់ ហើយយើងចាកចេញភ្លាម។ យើងត្រៀមខ្លួនចេញពីផ្ទះយើងដោយមានអីវ៉ាន់បន្តិចបន្តួច ឧទាហរណ៍ដូចជាសម្លៀកបំពាក់អង្ករ ហើយនិងអំបិល។ ហើយបានចាប់ផ្តើមដើរទៅក្បាលថ្នល់លើផ្លូវទៅតាខ្មៅ ខេត្តកណ្តាល។ នៅថ្ងៃនោះ តាមផ្លូវមនុស្សច្រើនដែលចាកចេញពីផ្ទះរបស់ពួកគេ ហើយនិងចេញទៅគ្រប់ទិសទីទាំងអស់។ ផ្លូវខ្មៅងងឹតទៅដោយមនុស្សចាស់ ក្មេង បុរស ស្ត្រី ដែលមានស្ពាយ ឬក៏ដឹកអីវ៉ែអីវ៉ាន់ផ្ទាល់ខ្លួន។ អ្នកខ្លះដឹកតាមរទេះ ហើយឡាននិងម៉ូតូទៅមុខមិនរួចទេ។ កុមារក្មេងៗនោះយំដោយសារគេបែកពីឪពុកម្តាយគេ ហើយគួរឲ្យអាណិតពួកគេណាស់។ មនុស្សចាស់ៗដែលមិនអាចដើរទៅរួចនោះគាត់ដេកនៅតាមផ្លូវ។ ក្រុមគ្រួសាររបស់ខ្ញុំដើរអស់រយៈពេល៧ថ្ងៃដើម្បីទៅដល់រង្វង់មូលក្បាលថ្នល់។ នៅពេលដែលយើងទៅដល់រង្វង់មូលក្បាលថ្នល់ខ្ញុំឃើញសាកសពទាហានដែលហើមហើយខ្ញុំភ័យណាស់នៅពេលនោះ។ នៅតាមផ្លូវយើង -- មានទាហានរបស់អង្គការយាមយើងដែលស្លៀកពាក់ខោអាវខ្មៅ គេយាមការពារយើងកុំឲ្យយើងរត់ចូលទីក្រុងវិញ។ គ្រួសារខ្ញុំបានដើរបែកគ្នានៅម្តុំស្ពានក្បាលថ្នល់ហ្នឹង"។ លោកសាក្សី តើសម្រង់នេះមានព័ត៌មានលម្អិតដែលដូចអ្វីដែលលោកបានស្តាប់ជនភៀសខ្លួនដែរឬទេ?

**ឆ៖** ប្រសិនបើយើងនិយាយអំពីអ្វីដែលគេប្រាប់ខ្ញុំ ទាក់ទងនៅក្នុងខែមេសា ឆ្នាំ៧៥ គឺថានៅតាមព្រំដែនថៃនោះ គឺថាចម្លើយ គឺ "បាទ" គឺដូចគ្នា។

[១៣:៥៦:១៧]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមអានសម្រង់មួយទៀត ដែលសម្រង់នេះដកស្រង់ចេញពីប្រតិចារឹកថ្ងៃទី០៥ ធ្នូ ឆ្នាំ២០១២ គឺឯកសារ E1/148.1។ គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែល

បាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឃើញមនុស្សនៅតាមផ្លូវច្រើន គេដើរពីពេទ្យរុស្ស៊ី ខ្ញុំឃើញថាមានអ្នកជំងឺដែលនៅលើគ្រែ ដែលគេរុញ ហើយមានបណ្ដោងសេរ៉ូមផងដែរ ហើយអ្នកខ្លះហ្នឹងនៅតែមានព្យួរសេរ៉ូមនៅឡើយទេ ហើយពួកគេត្រូវតែទៅតាមផ្លូវទៅទិសដៅដូចគ្នាតែមួយគាត់។ យើងទៅមុខមិនលឿនទេ យើងឃើញមនុស្សពីរបីនាក់ដែលជិះកង់ ឬក៏ជិះស៊ីក្លូ អ្នកខ្លះដឹងអីវ៉ែអីវ៉ាន់ផ្ទាល់ខ្លួនរបស់ខ្លួន អ្នកខ្លះទៀតដើរ ហើយអ្នកខ្លះឈឺ ហើយយើងទាំងអស់គ្នាដើរទៅក្នុងទិសដៅដូចគ្នា។ បរិយាកាសនោះមានភាពតានតឹង ហើយខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងដើរដោយសេរីនោះទេ"។

ហើយនៅក្រោមហ្នឹងបន្តិច ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និយាយដូចតទៅនេះ -- ERN ជាភាសាបារាំងគឺ 008695(*ស៊ីក*), ភាសាអង់គ្លេសគឺ 00868140, ជាភាសាខ្មែរគឺ 00866941 ដល់ 42។ គេសួរគាត់ថា៖ "តើខ្មែរក្រហមផ្ដល់អាហារហូបចុក និងថ្នាំដែរឬទេ? គាត់ឆ្លើយថា៖ នៅតាម -- នៅពេលជម្លៀសនោះ ទាហានខ្មែរក្រហមមិនឲ្យអាហារហូបចុក មិនឲ្យទឹក មិនឲ្យជម្រកជ្រកកោននោះទេ។ យើងចេញទៅដោយគ្មានអ្វីជាប់នឹងខ្លួនទេ មិនមានអាហារគ្រប់គ្រាន់ ឬក៏របស់របរគ្រប់គ្រាន់នោះទេ។ ដូច្នេះ នៅពេលល្ងាច នៅពេលដែលយើងទៅដល់កន្លែងមួយនោះដែលយើងបានប្រើក្រណាត់យើងក្រាលនៅនឹងដី ហើយយើងឈប់សម្រាកនៅទីនោះតែប៉ុណ្ណឹង។ ចំណីអាហារដែលយើងយកទៅសម្រាប់រយៈពេល៣ថ្ងៃនោះជិតអស់ទៅហើយ"។

[១៣:៥៨:៥១]

តើត្រង់ចំណុចនេះលោកសាក្សី ក្នុងចំណោមអ្នកដែលលោកបានសម្ភាសនោះ នេះខ្ញុំមិនមែនយោងតែទៅលើឆ្នាំ៧៥ ដែលលោកបានសម្ភាសទេ គឺថាមនុស្សដែលលោកបានសម្ភាសទាំងអស់នោះតើដោយលម្អិតហ្នឹង លោកឃើញថាព័ត៌មានដែលអានអម្បាញ់មិញនេះ វាដូចនឹងអ្វីដែលលោកបានសម្ភាសទេ? ព័ត៌មានដែលលោកស្ដាប់ឮពេលលោកសម្ភាស។

**ឆ៖** គឺថាវាដូចទៅនឹងភាគច្រើននៃអ្នកដែលខ្ញុំបានសម្ភាស ហើយដែលខ្ញុំបានស្ដាប់ពួកគាត់នោះ ហើយវាមានអ្នកខ្លះទៀត គឺថាគាត់និយាយប្រាប់ខ្ញុំថាមានការបែងចែក ឬក៏មានការជួយជាការដឹកជញ្ជូនចំណីអាហារ ឬក៏ទឹកបរិភោគបានគ្រាន់បើជាង -- ដូចជាមិនមានអ្នកណានិយាយអំពីការផ្គត់ផ្គង់ឱសថវេជ្ជសាស្ត្រនោះទេ។ ប៉ុន្តែ អ្នកខ្លះគាត់ទទួលបានការស្វាគមន៍ប្រសើរជាងនៅពេលដែលពួកគាត់ទៅដល់កន្លែងដែលគាត់ត្រូវស្នាក់នៅ។ ដូច្នេះនេះគឺជារៀបរាប់ដែលគាត់បានប្រាប់មកខ្ញុំ។

ដូច្នេះ ខ្ញុំចង់និយាយអ្វីដែលលោកស្រីទើបតែបានអានអម្បាញ់មិញនេះ គឺវាមិនមែនកើតឡើង

គ្រប់ករណីទាំងអស់។ វាមិនមែនជាករណី១០០ភាគរយនោះទេ។ ប៉ុន្តែខ្ញុំអាចនិយាយបានថា នេះគឺជាព័ត៌មានដែលមានលក្ខណៈជាមធ្យម ឬជាទូទៅ ប៉ុន្តែវាមានករណីខ្លះដែលវាប្លែក ឬក៏វាផ្សេងពីនេះ អាចថានៅជនបទដែលគាត់ទៅដល់ហ្នឹងមានចំណីអាហារ មានទឹកបរិភោគ ហើយមានអ្នកដែលគេមកដល់ទីរួមខេត្ត ឬក៏មកដល់ទីជនបទហ្នឹង គឺថាវាអាចមានករណីប្រែប្រួលខ្លះៗដែរ។ ឧទាហរណ៍ដូចជានៅខាងពាយ័ព្យជាដើម។

[១៤:០១:០១]

ស្ថានភាពនៅខាងពាយ័ព្យវាមិនសូវជាធ្ងន់ប៉ុន្មានទេ។ នៅពេលដំបូង រហូតដល់ពេលដែលរដូវច្រូតកាត់វាមានការទិន្នផលធ្លាក់ទាប គឺនៅចុង៧៥ ប៉ុន្តែនៅត្រឹមឆ្នាំ៧៥ គឺថាមានចំណី ស្បៀងអាហារគ្រប់គ្រាន់សល់ពីឆ្នាំមុន។ ប៉ុន្តែ ដោយសារតែនៅពាយ័ព្យវាមានការផ្គង់ផ្គត់មិនបានគ្រប់គ្រាន់ ទើបវាធ្វើឲ្យមានបញ្ហា ហើយនៅពេលហ្នឹងស្ថានភាពវាកាន់អាក្រក់ឡើងៗ។ ហើយជាពិសេស គឺពេលដែលខាងបូព៌ានិងខាងនិរតី ដែលត្រូវបានគេបញ្ជូនមកខាងពាយ័ព្យនេះទៀត ធ្វើឲ្យស្ថានភាពវាកាន់តែអាក្រក់ឡើង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមឲ្យលោកនិយាយអំពីការជម្លៀសដោយបង្ខំទេ មិនឲ្យនិយាយអំពីស្ថានភាពក្រោយៗទៀតទេ ប្រហែលជាពាក់ព័ន្ធនឹងសំណួរក្រោយទៀតរបស់ខ្ញុំ។ ឥឡូវ ខ្ញុំសូមឲ្យលោកនិយាយតែអំពីការជម្លៀសដោយបង្ខំទេ។ ហើយសូមឲ្យលោកឆ្លើយខ្លីៗ ព្រោះខ្ញុំមានពេលវេលាតិចណាស់ សូមអរគុណលោកសាក្សី។ អរគុណជាមុន។

ខ្ញុំសូមអានសម្រង់មួយទៀត ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ។ សំណួររបស់ខ្ញុំទាក់ទងទៅនឹងដំណាក់កាលជម្លៀសដោយបង្ខំនេះឯង។ ដើមបណ្តឹងរដ្ឋប្បវេណីនេះ និយាយដូចតទៅនេះ -- គឺឯកសារ D246/16, ERN ជាភាសាបារាំងគឺ 00434834, ជាភាសាអង់គ្លេសគឺ 00400463, ជាភាសាខ្មែរគឺ 00390312។ គាត់លើកឡើងដូចតទៅនេះ គេសួរគាត់ដូចតទៅនេះ៖

[១៤:០៣:១១]

"ថ្ងៃនោះ តើលោកបានឃើញអ្វីនៅក្នុងទីក្រុងភ្នំពេញ? ចម្លើយ៖ នៅពេលដែលខ្ញុំទៅដល់ផ្សារដើមគ ខ្ញុំឃើញមនុស្សពីរបីនាក់ ត្រូវបានគេបាញ់សម្លាប់។ សំណួរ៖ តើលោកស្រីអាចពន្យល់ឲ្យបានច្បាស់លាស់ដែរឬទេ ថាអ្នកណាជាអ្នកបាញ់ទៅលើពួកគាត់ទាំងអស់នោះ? ហើយអ្នកដែលគេបាញ់ស្លាប់នោះជាអ្នកណា? ចម្លើយ៖ នៅពេលដែលយើងទៅដល់ទីនោះ មានខ្មែរក្រហមវាំងស្ទះយើង ដោយ

មានកាំភ្លើង គេមិនឲ្យយើងបន្តទៅមុខទៀតទេ។ ខ្ញុំឃើញទាហានខ្មែរក្រហមនេះ បានបាញ់សម្លាប់មនុស្សពីរបីនាក់ ហើយអ្នកទាំងពីរបីនោះ ប្រហែលជាម្ចាស់ផ្ទះហើយ ដែលមិនព្រមចេញពីផ្ទះរបស់ពួកគេ។ ខ្ញុំឃើញព្រឹត្តិការណ៍នេះផ្ទាល់នឹងភ្នែកតែម្តង។ សំណួរ៖ តើទាហានខ្មែរក្រហមនោះស្លៀកពាក់ឯកសណ្ឋានបែបណាដែរ? ចម្លើយ៖ ខ្ញុំឃើញពួកគេស្លៀកពាក់ខោអាវខ្មៅ មួកខ្មៅ។ សំណួរ៖ តើលោកបានឃើញមនុស្សជាច្រើននៅតាមដងផ្លូវក្នុងក្រុងភ្នំពេញ ធ្វើដំណើរចាកចេញពីទីក្រុងដែរឬទេ? ចម្លើយ៖ មនុស្សទាំងអស់នោះ ត្រូវចាកចេញពីទីក្រុងតាមការប្រកាសរបស់ពួកខ្មែរក្រហម។ ពួកគេប្រកាសថាប្រជាជនត្រូវតែចេញពីទីក្រុងភ្នំពេញក្នុងរយៈពេល៣ថ្ងៃសិន ដោយខ្លាចពួកអាមេរិកាំងទម្លាក់គ្រាប់បែក។ ពួកគេនឹងបោសសម្អាតឲ្យស្អាតសិន ហើយ៣ថ្ងៃក្រោយទើបប្រជាជនអាចត្រឡប់មកទីក្រុងវិញបាន"។

លោកសាក្សី តើលោកមានបានឮចម្លើយបែបនេះពីមាត់អ្នកដែលលោកសម្ភាសដែរឬទេ? ខ្ញុំគ្រាន់តែសួរថាបានឮ ឬក៏មិនបានឮតែប៉ុណ្ណោះទេ ដែលសម្ភាស លោកមិនបាច់ឆ្លើយវែងប៉ុន្មាន និយាយលម្អិតទេ។

[១៤:០៥:២១]

**ឆ៖** ខ្ញុំគិតថាវាមានករណីខ្លះដែលកើតឡើងនៅបាត់ដំបង ដែលថាមានការគំរាមកំហែងបាញ់សម្លាប់ដើម្បីឲ្យប្រជាជនចាកចេញពីផ្ទះនោះ។ ប៉ុន្តែនៅចំណុចខ្លះទៀត នៅត្រង់ករណីខ្លះទៀត ឧទាហរណ៍ ប្រសិនបើខ្ញុំចាំមិនខុសទេ ដូចជារយៈពេល៣ថ្ងៃហ្នឹង គឺមិនមានអ្វីបែបនេះកើតឡើងនោះទេ។ គឺមិនមានអ្វីនិយាយទាក់ទងទៅនឹងបញ្ហានៅខាងតំបន់នោះទេ។ ប៉ុន្តែក្នុងរយៈពេល៣ថ្ងៃហ្នឹង គឺគេគ្រាន់តែនិយាយថា៣ថ្ងៃ ហើយឲ្យត្រឡប់មកវិញហ្នឹង គឺខ្ញុំចាំថាដូចអត់មាននិយាយទេ អត់មានប្រើប្រាស់ទេនៅទីនោះ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងដកស្រង់ឯកសារមួយទៀតពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី១។ ខ្ញុំនឹងលើកឡើងនូវសម្រង់ពីរដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី៣០ ឧសភា ឆ្នាំ២០១៣ គឺឯកសារលេខ E1/199.1, គឺលោកស្រី ប៉ូ ឌីណា។ ERN ជាភាសាបារាំង 00917599, ជាភាសាអង់គ្លេស 00917721 ទៅដល់ 22, ជាភាសាខ្មែរគឺ 00917984។ បុគ្គលរូបនេះ គាត់បានរៀបរាប់អំពីហេតុការណ៍ជាក់លាក់មួយ។ ខ្ញុំសូមដកស្រង់៖ "ម្តងនេះ គឺថាយើងបានស្តាប់ឮតាមរយៈការប្រកាសតាមមីក្រូថា អ្នកដែលមកពីភ្នំពេញត្រូវតែចុះឈ្មោះ។ អ្នកខ្លះបានទៅចុះឈ្មោះ ប្តីរបស់ខ្ញុំចង់ទៅចុះឈ្មោះដែរ ក៏ប៉ុន្តែខ្ញុំបានប្រាប់ថាដូចជាមិនសូវស្រួលទេ ហើយកុំចុះឈ្មោះអីគួរតែ

បន្តដើរទៅទៀតទៅ។ ដូច្នេះយើងក៏បន្តដំណើរទៅមុខទៀត"។

[១៤:០៧:៤៥]

ហើយនៅ ERN បន្ទាប់ទៅទៀតជាភាសាបារាំង ERN ជាភាសាបារាំង ជាអង់គ្លេស ហើយនិងខ្មែរគឺដដែល។ "នៅពេលទៅដល់កន្លែងនោះ ជាថ្មីម្តងទៀត គេឲ្យគ្រួសារនីមួយៗចុះឈ្មោះ។ យើងបានចុះឈ្មោះសមាជិកគ្រួសារ។ ពួកគេបានដាក់យើងថាជាអ្នក១៧ មេសា។ គឺពួកគេហៅយើងអ៊ីចឹងថា១៧ មេសា។ ពួកគេបានប្រាប់យើងថា យើងជាអ្នក១៧ មេសា ហើយយើងមិនអាចឈប់នៅទីនោះបានទេ។ យើងត្រូវបន្តដំណើរទៅមុខទៀត។ ខ្ញុំសុំឲ្យពួកគេអនុញ្ញាតឲ្យពួកយើងសម្រាកសិន ក៏ប៉ុន្តែគេបដិសេធ។ គេថាភូមិនេះអត់មានម្ហូបអាហារទេ ត្រូវតែបន្តទៅមុខទៀតទៅ"។

ពាក់ព័ន្ធទៅនឹងការចុះឈ្មោះ ហើយនិងការធ្វើជំរឿននេះ តើលោកធ្លាប់ឮពីអ្នកដែលលោកបានស្តាប់ ពីលោកដែលអ្នកសម្ភាស គឺមិនត្រឹមតែនៅឆ្នាំ៧៥ ហើយនិងនៅខាងផ្នែកបស្ចិមនោះទេ។ តើលោកធ្លាប់ឮប្រជាជនជាទូទៅដែលលោកសម្ភាសនេះ បាននិយាយអំពីចំណុចនេះទេ?

**ឆ៖** ចំណុចនេះ អ្វីដែលខ្ញុំអាចនិយាយបានគឺថា គឺវា គេនៅលើពិភពលោកអាចដឹង។ ហើយជាពិសេសអ្នកនៅខាងលោកខាងលិចដែលបានដឹងថារដ្ឋបាលខ្មែរក្រហមនោះបានធ្វើយ៉ាងម៉េច គឺគេបានដឹងស្ទើតែគ្រប់ទីកន្លែង។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីផ្អាកបន្តិចសិន!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:០៨:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នៅពេលនេះខ្ញុំសូមជំទាស់ទៅលើវិធីដែលរៀបសំណួរសួរបែបនេះ។ យើងចូរចងចាំដោយខ្លួនឯងថា លោក ហេដឌ័រ នៅទីនេះជាសាក្សី ដូច្នេះសាក្សីមិនគួរយើងដឹកនាំឲ្យគាត់ឆ្លើយទៅតាមអ្វីដែលយើងចង់សួរនោះទេ។ មកទល់ពេលនេះ សហព្រះរាជអាជ្ញា គាត់សួរៗអំពីអត្តបទផ្ទាល់របស់គាត់ និងកិច្ចសម្ភាសន៍ផ្ទាល់របស់គាត់។ ក៏ប៉ុន្តែនៅពេលនេះយើងឃើញថាសាក្សីនេះត្រូវបានសួរអំពីចម្លើយរបស់សាក្សី និងសក្ខីកម្មរបស់អ្នកផ្សេងទៀត។ ហើយលោក ហេដឌ័រ នេះត្រូវសហព្រះរាជអាជ្ញាអញ្ជើញឲ្យផ្តល់ជាមតិយោបល់។ បញ្ហារួមពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំនោះ

គឺវាមិនមែនជាប្រធានបទដែលយើងពិភាក្សាដេញដោលជាក់លាក់នៅទីនេះនោះទេ។ ប៉ុន្តែចំណុចនេះមានសារៈសំខាន់ណាស់សម្រាប់មេធាវីការពារក្តី នួន ជា។ វាមានសារៈសំខាន់ណាស់ដែលថាសាក្សីគួរតែទទួលបានសំណួរ ដែលបើកចំហាចៀសវាងសំណួរដឹកមុខ។

[១៤:១០:៥៥]

នៅក្នុងពេលនេះផងដែរ ខ្ញុំក៏សូមលើកឡើងថា ខ្ញុំឮសាក្សីឆ្លើយរៀបរាប់ថាសាក្សី ឬក៏ការឆ្លើយរបស់សាក្សីនោះគឺជាការឆ្លើយដូច្នេះនៅទូទាំងពិភពលោក គឺគេបានដឹងដូច្នេះ។ ដូច្នេះខ្ញុំគិតថាគឺជាសាក្សីគួរកុំនិយាយបញ្ចេញមតិយោបល់ ហើយកុំសន្និតថាអ្វីដែលបានលើកឡើងដូច្នេះ វាកើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៥។

លោកប្រធាន លោក លោកស្រីចៅក្រមខ្ញុំសូមឲ្យរំឭកទៅដល់សាក្សី កុំឆ្លើយជាលក្ខណៈសកលថាអ្វីដែលបានកើតឡើង ពេលឆ្លើយដូច្នោះ វាកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅពេញមួយរបបនោះ។ ហើយខ្ញុំក៏សូមឲ្យអង្គជំនុំជម្រះបង្គាប់ទៅកាន់សាក្សីកុំឲ្យផ្តល់ជាមតិយោបល់ក្នុងនាមគាត់ជាអ្នកជំនាញនៅលើរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានកើតឡើងក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩ផងដែរ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ អស់រយៈពេលជាង១៨ខែមកហើយ ដែលខ្ញុំសួរសំណួរទៅកាន់សាក្សីរបៀបនេះនោះ ហើយថ្ងៃចុងក្រោយនោះគឺលោកសាក្សី ប៉ុងសូដ៍ ដែលកាត់ស្រដៀងគ្នាទៅនឹងលោក ហេងឆ័រ នេះដែរក្នុងឋានៈជាសាក្សីនោះ។ ខ្ញុំបានប្រើប្រាស់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីខ្ញុំមិនឲ្យគាត់ផ្តល់មតិអត្ថាធិប្បាយទេ ខ្ញុំគ្រាន់តែសួរគាត់ថា តើគាត់ធ្លាប់ស្តាប់ឮរឿងហេតុស្រដៀងគ្នាដែរឬទេ? ឬក៏ធ្លាប់ឃើញនូវហេតុការណ៍ស្រដៀងដែរឬទេ។ ខ្ញុំមិនសូមឲ្យគាត់ផ្តល់យោបល់ផ្ទាល់ខ្លួនទេខ្ញុំចង់ឲ្យលោក ហេងឆ័រ គាត់ជូនខ្ញុំនូវអ្វីដែលគាត់បានឃើញ ឬក៏គាត់ឮ ហើយបើគាត់មិនឮ មិនឃើញគាត់អាចឆ្លើយទៅថា អត់ឃើញ អត់ឮទេ។ ដូច្នេះខ្ញុំសូមបន្តទៅទៀតលោកប្រធាន ខ្ញុំឃើញថាមិនមានការជំទាស់តាំងពីមុនមកនោះ តាមរបៀបដែលខ្ញុំធ្វើនេះនោះ។ ព្រោះថាយើងគួរតែបន្តទៀតទៅនៅសល់តែប៉ុន្មានសប្តាហ៍ទៀតនោះទេ។

[១៤:១២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៀត។ ប៉ុន្តែសូមរំឭកដល់លោក ស៊ីវ ហេងឆ័រ សូមលោករៀបចំនូវការ

ចម្លើយតបរបស់លោកទៅនឹងសំណួរ។ ទី១ឲ្យខ្លី ឲ្យសមស្របនឹងភាពចាំបាច់នៃការឆ្លើយតបនឹងសំណួរបានហើយ ចៀសវាងការអត្ថាធិប្បាយវែងផុត ចេញផុតពីតម្រូវការចាំបាច់នៃការឆ្លើយតបនឹងសំណួរ។ នេះជាការត្រឹមត្រូវ ហើយនិងសមស្របនឹងពេលវេលាដែលអង្គជំនុំជម្រះកំណត់រយៈពេលខ្លីក្នុងការតាំងសំណួរដេញដោលចំពោះលោកផង។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ឥឡូវនេះ ខ្ញុំទៅនិយាយអំពីបញ្ហាប្រជាជនថ្មី ដែលលោកបានលើកឡើងជាមួយនឹងសហព្រះរាជអាជ្ញាកាលពីប៉ុន្មានថ្ងៃមុននេះ។ លោកបាននិយាយអំពីបញ្ហាប្រជាជនថ្មីនេះ តើក្នុងចំណោមអ្នកដែលលោកបានសម្ភាសអស់រយៈពេលជាច្រើនឆ្នាំមកហើយ គឺជាង៣០ឆ្នាំមកហើយ តើអ្នកទាំងអស់នោះមានបានរៀបរាប់ប្រាប់លោកជាក់លាក់អំពីការប្រព្រឹត្តចំពោះប្រជាជន ១៧មេសា ឬក៏ប្រជាជនថ្មីនេះដែរឬទេ?

[១៤:១៤:១១]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំហាក់ដូចជាភ័ន្តភាំងនឹងច្រឡំ ថាតើគួរតែឆ្លើយយ៉ាងម៉េច។ ជាការពិត ខ្ញុំបាននិយាយជាមួយនឹងអ្នកមួយចំនួន ដែលយើងចាត់ទុកថាគាត់នោះដែលគេសន្មតថាពួកគាត់នោះជាប្រជាជនថ្មី។ គេអាចសន្និដ្ឋានថាជារួមមក មានការប្រព្រឹត្តដូចដែលបានលើកឡើងដូច្នោះ។ ក៏ប៉ុន្តែ នៅពេលជាមួយគ្នានោះដែរ គឺថាមានការលើកឡើងខុសៗគ្នា។ ហើយខ្ញុំគិតថា ខ្ញុំនឹងនិយាយសង្ខេបត្រឹមណានោះទេ ហើយក៏មិនដឹងនិយាយជាក់លាក់ប៉ុនណាផងដែរ។

**ស៖** ខ្ញុំនឹង -- ដោយសារតែពេលវេលាខ្លី ខ្ញុំសូមអានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ គឺឯកសារលេខ E1/152.1, ERNជាភាសាបារាំង 00871393, ជាភាសាអង់គ្លេស 00871253, ជាភាសាខ្មែរគឺ 00867655 គឺលោកស្រី អាហ្វុងសូ ខ្មែរគឺ 00869655 គេចោទសំណួរទៅកាន់គាត់ លោកស្រី អាហ្វុងសូ លោកស្រីបានបញ្ជាក់អម្បាញ់មិញថា នៅក្នុងភូមិនោះមានការបែងចែករវាងប្រជាជនចាស់ និងប្រជាជនថ្មី គឺថាយើងមានការបែងចែកយ៉ាងច្បាស់ យ៉ាងដាច់ពីគ្នា។ តើលោកស្រីអាចលើកឡើងអំពីផលវិបាកដែលកើតចេញពីការបែងចែកនេះទេ? ចម្លើយ៖ បាទគឺ

មានអ៊ីចឹងមែន។ គឺថាដំបូងនោះគឺពាក់ព័ន្ធនឹងការបែងចែកស្រូវអង្ករ។ ចំពោះយើងគឺយើងទទួលបានមួយចំណែកទេ ពួកគេគឺពីរចំណែក ហើយស្ត្រីពួកគេអត់ធ្វើការទេ ប្រពន្ធពួកគេនោះគឺថាអាចបង្កើតកូនបានអាចញ៉ាំ អាចហូបចុកបានឆ្អែត ខ្ញុំឃើញស្ត្រីពីរនាក់គឺអ៊ីចឹង។ គាត់មានផ្ទៃពោះ ហើយគាត់អាចហូបឆ្អែតបានតាមចិត្ត។ ប៉ុន្តែយើងជាប្រជាជនថ្មីនោះគឺថាអត់មានម្ហូបអាហារគ្រប់គ្រាន់ទេ ពួកគេប្រជាជនចាស់គេមានសាច់ មានត្រី ក៏ប៉ុន្តែយើង យើងមានតែអំបិល និងអង្ករ ហើយយើងហូបតែបបរទេទាំងព្រឹកទាំងល្ងាច។ យើងទទួលបានអាហារតែពីរពេលទេក្នុង១ថ្ងៃ ហើយមួយពេលៗគឺថាបបរតែមួយវែកទេ។ ហើយយើងដើររកគីង្គក់ ដើររកកង្កែប ដើររកខ្យាដំរី ឲ្យតែឃើញអីយើងអាចរកបាននោះគឺថាខ្ញុំយកមកហូបទាំងអស់។ ជួនកាលទៅខ្ញុំហូបទាំងកន្លាតទៀត។ ដូច្នេះ នេះខ្ញុំចង់ជម្រាបថា ជួនកាលយើងអត់ឃ្លានដល់កម្រិតណា? យើងដូចជាសត្វធាតុអ៊ីចឹង យើងដណ្ដើមសូម្បីតែម្ហូបឆ្កែហ្នឹង ក៏យើងវៃឆ្កែយកម្ហូបដែរ ព្រោះឆ្កែស៊ីឆ្ងាញ់ជាងយើងទៅទៀត។ យើងអ្នកប្រជាជនថ្មីហ្នឹងហូបមិនបានប៉ុនឆ្កែផង។ អ៊ីចឹងលោក ហេងឌ័រ តើលោកអាចបញ្ជាក់បានទេថាតើចម្លើយនេះវាត្រូវនឹងអ្វីដែលលោកបានស្ដាប់ឮពីសំណាក់បុគ្គលដែលលោកបានសម្ភាស គឺថាខ្ញុំមិនចង់ឲ្យលោកនិយាយជាលក្ខណៈទូទៅទេ គឺអ្វីដែលលោកស្ដាប់ឮចេញពីអ្នកដែលលោកបានសម្ភាសនោះ?

[១៤:១៧:៥០]

**ឆ៖** ចម្លើយគឺថា មានខ្លះ ក៏ប្រហែលជាមានច្រើនដែរ។ បានន័យថាវាចន្លោះខ្លះ និងចន្លោះចំនួនច្រើននេះឯង។

**ស៖** សូមអរគុណចំពោះចម្លើយដ៏ច្បាស់ហើយនឹងខ្លី។ ពាក់ព័ន្ធទៅនឹងប្រជាជនថ្មី ក៏ដូចជាការឃោសនា ខ្ញុំសូមលើកឡើងនូវប្រតិចារឹកមួយគឺចម្លើយរបស់សាក្សី ៣៣៨ គឺលោកគឹម វុន ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២។ ឯកសារនោះគឺលេខ E1/112.1។ ERN ជាភាសាបារាំងគឺ 00841318, ជាភាសាអង់គ្លេស00841201 ទៅដល់ 02, ខ្មែរ 00839903 លោកគាត់ជាអ្នកសរសេរអត្ថបទមួយចំនួនហើយអត្ថបទនោះគឺមានផ្សព្វផ្សាយតាមវិទ្យុ។ គាត់បានឆ្លើយនៅពេលសវនាការនោះថា ខ្ញុំសូមដកស្រង់ "សំណួរ៖ ខ្ញុំនិយាយម្ដងទៀតអំពីប្រជាជនថ្មី។ តើលោកធ្លាប់សរសេរអត្ថបទទាក់ទងនឹងប្រជាជនថ្មីនេះដែរឬទេ?" ខ្ញុំសូមបញ្ជាក់ថាសាក្សីរូបនេះគឺគាត់មិនសរសេរសម្រាប់ទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត ឬក៏ទស្សនាវដ្ដីទង់បដិវត្តនោះទេ? គាត់ឆ្លើយថា៖ "ជាគោលនយោបាយនៃការផ្សព្វផ្សាយរបស់យើង យើងមិនដែលបែងចែកអ្នកថ្មី អ្នកចាស់នោះទេ។ ហើយក្នុងព័ត៌មាននោះ គឺគេមិនឲ្យយើងនិយាយអំពីការ

បែងចែកនេះតែម្ដង។ គឺយើងអាចនិយាយ -- គេនិយាយនៅក្នុងខ្លឹមសារទង់បដិវត្តអី ប៉ុន្តែដូចពួកខ្ញុំសរសេរនោះគឺថាអត់សរសេរបានទេ ព្រោះជួនកាលគេយកទៅផ្សាយវិទ្យុ។ ដូច្នេះ អត្ថបទហ្នឹងគឺយើងស្រង់យកពីកាសែតដែលយកទៅផ្សាយតាមវិទ្យុ ហើយយើងសរសេរតែជ្រុងណាដែលមើលទៅថាវាមិនប៉ះពាល់ដល់នយោបាយទេ ព្រោះកម្ពុជាប្រជាធិបតេយ្យគិតគូររឿងនយោបាយនូវការផ្សព្វផ្សាយហ្នឹងណាស់ ព្រោះការផ្សព្វផ្សាយថ្នាក់ដឹកនាំ គឺវាដូចជាកាំភ្លើងធំមួយដែរ បើបាញ់ចេញទៅហើយ គឺថាវាមានភាពធ្ងន់ធ្ងរណាស់។ ដូច្នេះគឺបញ្ជាក់អត្ថន័យវាអ៊ីចឹង ហើយនៅពេលនុ៎ង គឺថាការសរសេរត្រូវប្រយ័ត្នប្រែងណាស់ ហើយមានការឆ្លងមើលខ្លឹមសារហ្នឹងជិតដល់ណាស់ យើងមិនអាច យើងម្នាក់ឯងហ្នឹងអះអាងថាមានភាពពេញលេញទេ គេពិនិត្យទាំងពីរទស្សនៈរួមទៅលើបច្ចេកទេស លើឃ្លាប្រយោគ ហើយធ្វើដំបូងហ្នឹង ត្រូវឆ្លងកាត់ការពិនិត្យខ្លឹមសារហ្នឹងតែម្ដង ហើយគណៈនិពន្ធត្រូវតែកែឲ្យអស់ មិនឲ្យប៉ះពាល់ទេ”។ សំណួរ លោកបាននិយាយថា “ទស្សនាវដ្ដីទង់បដិវត្តបាននិយាយអំពីពាក្យប្រជាជនថ្មី តើលោកអាចប្រាប់បានទេថា ទង់បដិវត្តហ្នឹងនិយាយអីពាក់ព័ន្ធនឹងប្រជាជនថ្មី? ឆ្លើយ៖ ខ្ញុំមិនចាំថាយ៉ាងណាៗនោះទេ។ ខ្ញុំអត់បានឃើញដែរ ប៉ុន្តែខ្ញុំនិយាយអំពីសិទ្ធិទេ គឺសិទ្ធិខាងសរសេរទូលាយ ដែល -- និងសិទ្ធិដែលសម្ងាត់។ បើសម្ងាត់គេអាចសរសេរថា ប្រជាជនថ្មីហ្នឹងបាន ចាស់ថ្មីហ្នឹងបាន បែងចែកប្រភេទ ប៉ុន្តែសរសេរដូចនេះ គេមិនអាចបែងចែកប្រភេទអ៊ីចឹងបានទេ គឺប្រជាជនទូទៅ គឺនិយាយជាទូទៅ”។ សំណួរ ក្នុងចំណោមមនុស្សដែលលោកបានសម្ភាស ជាពិសេសគឺកម្មាភិបាលនិងសមាជិកបក្សកុម្មុយនីស្តកម្ពុជា តើលោកធ្លាប់ស្ដាប់ឮអំពីភាពខុសគ្នានៃការឃោសនាដែលសម្រាប់បក្ខជន និងការឃោសនាសម្រាប់ប្រជាជន ឬក៏ឃោសនាទៅខាងក្រៅនោះ លោកធ្លាប់ឮថាមានការបែងចែកខ្លឹមសារគ្នាបែបនេះទេ?

[១៤:២១:៥៣]

**ឆ៖** ជាការពិត គឺមានការបែងចែករវាងការឃោសនានិងការអប់រំ។ បើសិនយើងប្រើពាក្យឲ្យត្រឹមត្រូវនោះ គឺមានការបែងចែកនៅក្នុងជួរបក្ស។ នៅក្នុងបក្សហ្នឹងគេនិយាយថា មហាជន។ ចំពោះបញ្ហានេះ ខ្ញុំមិនប្រាកដថា តើខ្ញុំយល់ប្រាកដទៅលើអ្វីដែលសាក្សីបាននិយាយតាមដែលលោកស្រីលើកឡើង។ អ្វីដែលខ្ញុំទទួលបានតាមរយៈពេលព័ត៌មាននោះ គឺមានការកើតឡើង វាខុសគ្នារវាងប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន និងអ្នកនៅក្នុងបក្ស ហើយខ្ញុំមិនប្រាកដថាចំណុចនេះ គឺវាជាគោលនយោបាយដែលគេបានបង្កើតការបែងចែក ឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ គឺវាមានការខុសគ្នា

មែនចំពោះបញ្ហាមហាជន និងអ្នកដែលនៅក្នុងជួរបក្សជាដើម។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីខ្លាំង ហើយនិងជនក្បត់ដែលលោកធ្លាប់ឆ្លើយទៅនឹងសហព្រះរាជអាជ្ញារួចមកហើយ។ ជាពិសេសនោះលោកបានឆ្លើយថា ឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលគាត់បានលើកឡើងអំពីករណីមួយដូចជាថា ការលួចប៉ែលហើយសហព្រះរាជអាជ្ញាគាត់មានសួរលោកថា អ្នកដែលគ្រាន់តែលួចប៉ែលហ្នឹងក៏ត្រូវសម្លាប់ចោលដែរ គឺពេលហ្នឹងលោកឆ្លើយថា អ៊ីចឹង គឺនៅថ្ងៃទី១១ ខែកក្កដា។ ដូច្នេះ ខ្ញុំសូមអានន្ទូវសម្រង់តូចពីរចេញពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយលោកឆ្លើយថា តើលោកធ្លាប់ឬនៅហេតុការណ៍ដែលកើតឡើងរបៀបនេះទេ? សម្រង់ទី១នោះ គឺដកចេញមកពីឯកសារ D22/3765, ERN ជាភាសាបារាំងគឺ 00892711, ជាភាសាអង់គ្លេស 00892763, ជាភាសាខ្មែរ 00875010។

[១៤:២៤:២០]

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់បានឆ្លើយថា "ចំពោះខ្មែរផ្សេងទៀត ខ្ញុំឃើញខ្មែរក្រហមនាំយកទៅសម្លាប់ដោយគ្មានត្រាប្រណី ដោយគ្រាន់តែលួចបំពង់ឫស្សី ដែលលួចផឹកទឹកត្នោត ឬក៏លួចពងទា ឬក៏លួចមាន់។ អ្នកខ្លះហ្នឹងត្រូវបានគេចោទថា លួចបេះស្រូវ ហើយយកទៅហូប។ ពួកគេត្រូវបានសម្លាប់ចោទ ធ្វើទារុណកម្ម ឬវ៉ៃរហូតដល់ស្លាប់។ ខ្ញុំសូមបញ្ជាក់ថា កូនប្រុសពីររបស់ខ្ញុំត្រូវបានសម្លាប់ចោទដែរ ដោយសារតែពួកវាបានលួចម្ហូប លួចអាហារបន្តិចបន្តួច ដើម្បីកុំឲ្យឃ្លានពេក"។

សម្រង់មួយទៀតខ្លីទេ ខ្ញុំចង់អានដែរ គឺដកចេញពីប្រតិចារឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ គឺ E1/152.1 គឺសក្ខីកម្មរបស់លោកស្រី ដេនីស អាហ្វុងសូ គឺម៉ោង១៥:៣៨:៤៣ បន្តិច។ គេសួរគាត់អំពីកូនប្រុសរបស់គាត់ "ថាតើលោកស្រីដឹងទេថា ហេតុអីបានជាគេវ៉ៃកូនលោកស្រីដូច្នេះនោះ?" គាត់ឆ្លើយថា "បាទ គឺថាក្មេងៗដូចអាយុពួកដែរហ្នឹង ពេលហ្នឹង គឺថាទៅរកឈើ ហើយវាអត់ទៅកាប់ឈើទេ គឺវាលួចឈើរបស់គេដែលរកបាន។ ដូច្នេះគេក៏ចាប់វា។ ល្អបចាប់បាន ហើយគេប្រាប់ថា ឯងជាក្មេងពុករលួយ ឯងលួច។ ដូច្នេះ ត្រូវតែពិន័យឯង"។ សូមបញ្ចប់ការដកស្រង់។

លោក ហេងឌ័រ តើក្នុងចំណោមមនុស្សដែលលោកបានសម្ភាសនោះ លោកមានបានឮអ្នកទាំងអស់នោះ រៀបរាប់អំពីហេតុការណ៍ដែលស្រដៀងគ្នាទៅនឹងអ្វីដែលបានកើតឡើងនេះទេ?

**ឆ៖** បាទ គឺបានដឹងច្រើន មានអ៊ីចឹងមែន។

[១៤:២៦:៣២]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមនិយាយអំពីការជម្លៀសដោយបង្ខំដំណាក់កាលទី២ ដែលលោកបានឆ្លើយជូនសហព្រះរាជអាជ្ញាខ្លះៗរួចមកហើយ។ ក្នុងចំណោមអ្នកដែលលោកបានសម្ភាស តើពួកគាត់មានបានរៀបរាប់ប្រាប់លោកអំពីលក្ខខណ្ឌនៃការជម្លៀសដោយបង្ខំដែរឬទេ? ព្រឹកមិញនេះ លោកនិយាយអំពីមូលហេតុ ចុះលក្ខខណ្ឌវិញនោះ លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការជម្លៀសហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** លោកស្រីមានន័យថា លក្ខខណ្ឌនៃការដឹកជញ្ជូន ឬក៏យ៉ាងម៉េច?

**ស៖** លក្ខខណ្ឌទូទៅ តាំងពីការដឹកជញ្ជូន ម្ហូបអាហារ ការព្យាបាល ការប្រព្រឹត្តចំពោះអ្នកដែលត្រូវជម្លៀសចេញទាំងអស់ហ្នឹង?

**ឆ៖** តាមទូក ឡាន និងរថភ្លើង គឺវាមានមនុស្សណែនតាន់តាប់ ហើយមានភាពណែនតាន់តាប់។ នៅក្នុងកាលៈទេសៈមួយចំនួន គឺអ្នកដែលធ្វើដំណើរតាមបែបហ្នឹង គឺថាមិនអាចសម្រាក ឬក៏គេងនោះទេ។ ហើយអ្នកដែលគាត់ធ្វើដំណើរទៅហ្នឹង គឺថាកាន់តែទន់ខ្សោយ ហើយចាប់ផ្តើមឈឺ ហើយស្ថានភាពរបស់គេមានលក្ខណៈមិនប្រសើរទេ។ យើងដឹង យើងឃើញថាស្ថានភាពទាំងអស់នេះ គឺថាធ្វើឡើងការដឹកជញ្ជូននេះ ក្រោមការគ្រប់គ្រងរបស់យោធា និងអ្នកយាមកាម។ អ្នកដែលត្រូវបានដឹកជញ្ជូនពីកន្លែងយោធាមួយទៅកន្លែងយោធា ឧទាហរណ៍ថា ពីព្រំដែនភូមិភាគ ព្រំដែនតំបន់ទៅកាន់ព្រំតំបន់ភូមិភាគ និងតំបន់ផ្សេងទៀត គឺថាមានការគ្រប់គ្រងដោយផ្នែកយោធាដូច្នេះ។

[១៤:២៨:៤៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់ខ្លីៗពីរ ដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី២។ សម្រង់ទី១ គឺដកចេញមកពីដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/2068។ ERN ជាភាសាបារាំងគឺ 00923428, អង់គ្លេស 00893384, ខ្មែរ 00544541។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះគាត់បានឆ្លើយថា “នៅឆ្នាំ១៩៧៦ ដូចជាប្រជាជនភាគច្រើនដែរ ខ្ញុំត្រូវបានជម្លៀសតាមរទេះភ្លើងក្នុងខេត្តពោធិ៍សាត់។ យើងមានគ្នាជាច្រើន។ ឪពុកខ្ញុំឈ្មោះ វ៉ាយ ឃុត ម្តាយខ្ញុំ ឌី យ៉ែម ត្រូវបានជម្លៀសពីស្រុកស្អាង ទៅស្រុកបាទី ខេត្តតាកែវ។ តាំងពីពេលនោះមក ខ្ញុំបាត់ដំណឹងគាត់ឈឹង។ បងប្អូនរបស់ខ្ញុំគឺឈ្មោះ ឌី ខែន, ឌី យឿន, ឌី រ៉ុម ក៏ទៅជាមួយឪពុកម្តាយខ្ញុំនៅតាកែវដែរ។ ខ្ញុំធ្វើដំណើរតាមរថភ្លើងជាមួយកូនទាំងពីរនាក់រហូតទៅដល់ពោធិ៍សាត់។ រទេះភ្លើងនោះមានមនុស្សច្រើនណាស់ ខ្ញុំមិនដឹងថាតើមនុស្សទាំងអស់ហ្នឹងមកពីណាទេ។

ក្មេងៗស្រែកយំគ្រប់កន្លែងរកឪពុកម្ដាយរបស់ពួកវា ហើយមេក្រុមហ្នឹងគឺថាបោះចោលតាមបង្អួចរទេះភ្លើង ហើយឃើញរូបភាពហ្នឹង ខ្ញុំរន្ធត់មែនទែន ខ្ញុំឱបកូនខ្ញុំនៅក្នុងដៃ។ ហើយនៅពេលយប់នោះ រទេះភ្លើងអត់ឈប់ទេ ហើយយើងក៏អត់មានមុង អត់មានភួយ ដើម្បីការពារពីសត្វល្អិតដែលមកទិចខាំយើងដែរ។ ស្អែកព្រឹកឡើងនោះ យើងត្រូវបន្តដំណើររហូតទៀត គឺយើងត្រូវដើរ ដោយមានមនុស្សពីរនាក់កាន់កាំភ្លើងតាមយើងរហូត។ ពួកគេបានបែងចែកយើងទៅដាក់តាមសហករណ៍ផ្សេងៗ"។

[១៤:៣០:៤៨]

សម្រង់ទី២ គឺដកចេញមកពីកំណត់ហេតុនៃការស្ដាប់ចម្លើយ គឺឯកសារ D217/3។ ERN ជាភាសាបារាំង 00372053, អង់គ្លេស 00353702, ខ្មែរ 00349497 ទៅដល់ 98។ សម្រង់ដែលខ្ញុំអានជូនលោកនោះ គឺដូចតទៅ៖ "១៥ថ្ងៃក្រោយមក គឺថាមានការជម្លៀសប្រជាជន។ ប្រជាជនត្រូវបានគេដាក់នៅក្នុងកាណូតធំ ហើយប្រហែលជាមានរាប់រយនាក់នៅក្នុងកាណូតនីមួយៗ។ ហើយខ្ញុំឃើញកាណូតជាច្រើនពីព្រោះថាវាជាការជម្លៀសដ៏ធំ ដែលធ្វើឡើងនៅគ្រប់ភូមិស្រុកនៃល្វាឯម។ កាណូតឈប់នៅស្រុកពញាឮ បន្ទាប់មកទៀតគេយកទៅដាក់ក្នុងឡាន ហើយឡានហ្នឹងគេដឹកយើងទៅស្ថានីយរថភ្លើងដំណាក់ស្នាច់ យើងនៅទីនោះបាន១អាទិត្យ។ ពេលនោះ ខ្មែរក្រហមបានផ្ដល់របបអង្ករឲ្យយើង។ ១អាទិត្យក្រោយមក ខ្មែរក្រហមបានហៅឈ្មោះប្រជាជនឲ្យជិះរថភ្លើងទៅស្រុកបាកានខេត្តពោធិ៍សាត់"។

ជាថ្មីម្ដងទៀតលោក ហេងឌ័រ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ស្ដាប់ឮប្រជាជនដែលលោកសម្ភាសហ្នឹង រៀបរាប់អំពីហេតុការណ៍ដែលកើតឡើងស្រដៀងគ្នានេះសល់លោកទេ?

**ឆ៖** បាទ ជាថ្មីម្ដងទៀត គឺថាធ្លាប់ឮ ហើយក៏មានច្រើនដែរ។

[១៤:៣២:៣៨]

**ស៖** សូមអរគុណ។ ដោយសារតែខ្ញុំមិនសូវមានពេលច្រើននោះ ខ្ញុំសូមចូលទៅប្រធានបទផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងបញ្ហាភាសា។ លោកៗនិយាយខ្មែរបានស្ទាត់ជំនាញ ហើយលោកបានលើកឡើងនូវពាក្យពេចន៍មួយចំនួនជាមួយនឹងសហព្រះរាជអាជ្ញាជាភាសាបារាំងនោះខ្ញុំស្ដាប់ឮថា "ពង្រឹងប្រជាជន" ឬក៏ "ដកប្រជាជនពីខ្មាំង" ហើយលោកក៏បាននិយាយអំពីពាក្យ "ប្រជាជនថ្មី" ហើយនិងពាក្យថា "ដណ្ដើមយកប្រជាជន" "ទាញយក" ឬក៏ "ដកយកប្រជាជន"។ ខ្ញុំចង់សួរលោកថា ក្នុងចំណោមកិច្ចសម្ភាសន៍ដែលលោកបានធ្វើ តើលោកមានបានកត់សម្គាល់ឃើញថា នៅក្នុងកិច្ចសម្ភាសន៍ទាំងអស់នោះប្រជាជនគាត់ប្រើវាក្យសព្ទពិសេសដោយឡែក ដែលថាជាពាក្យពេចន៍ដែលប្រើនៅក្នុងរបប

កម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ដូចជាហៅអ្នកក្បត់អ៊ីចឹង គេហៅថាម៉េច? ហើយការប្រកប ការធ្វើស្រែចម្ការគេថាយ៉ាងម៉េច? ហើយរបបខ្មែរក្រហមអីហ្នឹងគេហៅយ៉ាងម៉េច? សូមលោកបញ្ជាក់ជូន។

[១៤:៣៣:៥៨]

**ឆ៖** ជាការពិតមានៗភាសានយោបាយដែលអាចសម្គាល់បានប្រើប្រាស់ដោយកម្មាភិបាល រួមទាំងប្រជាជនទូទៅ។ នៅក្រោមរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចគ្នាដែរបានន័យថាភាសានយោបាយនៅសម័យសម្តេច នរោត្តម សីហនុ និងភាសានយោបាយប្រើប្រាស់ក្នុងសម័យ លន់ នល់ នោះក៏គេមានការប្រើប្រាស់ខុសគ្នាដែរ។ ដូចគ្នាទេករណីហ្នឹង។

**ស៖** តើលោកអាចផ្តល់ជាឧទាហរណ៍ខ្លះៗ ដូចជា ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានស្តាប់ឮ ឧទាហរណ៍ដូចថា សកម្មភាពកសិកម្ម ការបង្កបង្កើនផល ការងារនៅក្នុងសហករណ៍អីជាដើមហ្នឹង គេប្រើពាក្យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមចាប់ផ្តើមពាក្យមួយចំនួនដូចថា "*ប្រយោកសិទ*" សំដៅលើការបង្កបង្កើនផល ដែលគេមិនប្រើពាក្យសាមញ្ញថា "ធ្វើស្រែ"ទេ។ ដូចគ្នាដែរពាក្យថា "*អ៊ុត*"ហ្នឹង គឺហូប។ គឺគេប្រើប្រាស់ទៅតាមវណ្ណៈថ្នាក់របស់សង្គមមនុស្ស ទៅតាមប្រភេទនៃមនុស្សបែបហ្នឹង។ ដូច្នេះ បើសិនជាអ្នកចម្ការអ៊ីចឹងជួនកាលគេប្រើពាក្យថា "ហូប" សំដៅលើពាក្យថា "*អ៊ុត*" ហ្នឹង។ ដូច្នេះ ពាក្យមួយចំនួននោះគឺថាគេសង្ឃឹមថាគេគិតថាចង់ឲ្យយើងនិយាយពាក្យសាមញ្ញទូទៅក្នុងភាសាខ្មែរ។ ក៏ប៉ុន្តែមានពាក្យមួយដុំ មួយសំណុំផ្សេងទៀតដែលគេបកប្រែចេញមកពីភាសាវៀតណាម។ ដូច្នេះបានន័យថា គេត្រូវប្រើភាសាក្រុមរបស់គេហ្នឹងដោយឡែកដើម្បីឲ្យវាមានលក្ខណៈផ្លូវការ។ កាលពីមុនសម័យមុនក៏ដូចគ្នា។

[១៤:៣៦:១៨]

**ស៖** សូមអរគុណ។ វាក្យស័ព្ទពិសេសនេះតើមានតែនៅក្នុងឯកសារដែលចេញមកពីមជ្ឈិមបក្ស ឧទាហរណ៍ដូចជា សុន្ទរកថា ឯកសារផ្លូវការរបស់បក្ស ឬក៏រដ្ឋធម្មនុញ្ញ កំណត់ហេតុប្រជុំ។ តើយើងឃើញវាក្យស័ព្ទទាំងអស់ហ្នឹងមានតែនៅក្នុងឯកសារ ឬឃើញមានគេប្រើជាផ្ទាល់មាត់ឧទាហរណ៍ដូចជាកម្មាភិបាលគាត់និយាយតាមថ្នាក់ផ្សេងៗគាត់មានប្រើវាក្យស័ព្ទហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប!

សូមអញ្ជើញមេធាវីវ៉ិចទ័រកូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ការសួរដូច្នេះ គឺសួរឲ្យសាក្សីនេះផ្តល់មតិយោបល់ក្នុងនាមជាអ្នកជំនាញ មិនមែនសួរទៅកាន់ក្នុងនាមជាសាក្សីនោះទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំមិនគិតថា ខ្ញុំឲ្យគាត់និយាយក្នុងនាមជាអ្នកជំនាញនោះទេ។ ខ្ញុំគ្រាន់តែឲ្យគាត់ប្រាប់ខ្ញុំពីអ្វីដែលគាត់បានស្តាប់ឮ គាត់បានឃើញ និងគាត់អាន។ ខ្ញុំដឹងថាគាត់អានឯកសារច្រើនណាស់ដែលជាឯកសារភស្តុតាងនោះ ហើយគាត់ក៏បានសម្ភាសមនុស្សជាច្រើន ជាពិសេសកម្មាភិបាលខ្មែរក្រហម។ ដូច្នេះខ្ញុំចង់ដឹងថា តាមអ្វីដែលគាត់ស្តាប់ឮ តើកម្មាភិបាលទាំងអស់នោះមាននិយាយពាក្យផ្ទាល់ៗមាត់នោះប្រើពាក្យដូចដែលពាក្យដែលប្រើនៅក្នុងឯកសារផ្លូវការនោះដែរឬទេ? ខ្ញុំមិនឲ្យគាត់ស្មាន ឬក៏ឲ្យគាត់ផ្តល់យោបល់ផ្ទាល់ខ្លួនរបស់គាត់ទេ គឺឲ្យគាត់បង្ហាញនូវការកត់សម្គាល់ឃើញរបស់គាត់។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:០៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា របៀបនៃការសួរសំណួរនេះ គឺថាមានលក្ខណៈសមស្របហើយ សូមលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរៀបចំនូវសំណួររបស់ខ្លួនឡើងវិញ។ ហើយការរៀបចំនូវសំណួរ សូមឲ្យគិតថា អង្គជំនុំជម្រះបានជម្រាបជូន និងរំឭកជូនតាំងពីដើមមកឲ្យកំណត់នូវឋានៈរបស់សាក្សីរបស់លោក ស្ទីវ ហេដឌ័រ ចំពោះមុខអង្គជំនុំជម្រះហ្នឹងក្នុងឋានៈជាសាក្សី មិនមែនឋានៈជាអ្នកជំនាញទេ។ ហើយសូមឲ្យរៀបចំនូវសំណួរហ្នឹងឲ្យមានលក្ខណៈច្បាស់លាស់ទៅខាងឋានៈជាសាក្សីតែម្តង។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេល នេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០២:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊្វីវ ហេងឆ័រ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** តាមពិតខ្ញុំសួរជិតចប់ហើយ ឥឡូវខ្ញុំសូមចោទសំណួរចុងក្រោយរបស់ខ្ញុំឡើងវិញ។ ខ្ញុំកាត់ផ្តាច់ជាពីរផ្នែក។ ឥឡូវនេះ លោកសាក្សី លោកបាននិយាយថាមានភាសាជាក់លាក់មួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើភាសាហ្នឹងលោកបានឃើញ បានអានដោយខ្លួនឯង ក្នុងឯកសារដែលចេញមកពីមជ្ឈិមបក្ស ដូចជា សុន្ទរកថា អត្ថបទកាសែត និងឯកសារចេញពីស្ថាប័ននានា។ តើលោកធ្លាប់បានជួបប្រទះឯកសារនេះចេញពីមជ្ឈិមបក្សដែរឬទេ?

**លោក ស៊្វីវ ហេងឆ័រ៖**

**ឆ៖** ពិតហើយ គឺខ្ញុំធ្លាប់ឃើញ។

**ស៖** អ៊ីចឹងសំណួរទី២របស់ខ្ញុំដូចតទៅនេះ តើពាក្យពេចន៍ពិសេសនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យទាក់ទងទៅនឹងប្រធានបទជាក់លាក់ ឬក៏ប្រធានបទផ្សេងៗ តើលោកធ្លាប់បានកត់សម្គាល់ឃើញថាមាននិយាយនៅក្នុងសុន្ទរកថារបស់កម្មាភិបាលខ្មែរក្រហម ឬក៏បក្ខជនខ្មែរក្រហមដែរឬទេ?

[១៥:០៤:០៣]

**ឆ៖** បាទ។ ហើយខ្ញុំសូមបន្ថែមទៀតថា សូម្បីតែនៅក្នុងប្រជាជនទូទៅក៏មានដែរទាំងអ្នកមូលដ្ឋាន ទាំងអ្នកថ្មី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមអរគុណ ព្រោះអម្បាញ់មិញនេះ ខ្ញុំចង់សួរសំណួរអំមិញហ្នឹងហើយ ប៉ុន្តែលោកបានឆ្លើយនឹងសំណួរដែលខ្ញុំរៀបនឹងសួរហើយ។ អ៊ីចឹងសូមអរគុណលោកច្រើន។ ហើយលោកមេធាវី ឡោ ជុនធី ចង់សួរបន្តបន្តិចទៀតលោកប្រធាន។ សូមអរគុណ។

**លោក ឡោ ជុនធី៖**

បាទ ខ្ញុំសូមជម្រាបសួរលោកចៅក្រម លោក លោកស្រីចៅក្រម ហើយសូមជម្រាបសួរសហភាគីទាំងអស់។ ហើយជម្រាបសួរលោក ស្មីវហ្វិន ហេដឌ័រ ផងដែរ។ ហើយខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំបាទធ្វើការងារនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ តទៅនេះ ខ្ញុំចង់ជម្រាបសួរលោកបន្តិចបន្តួចពាក់ព័ន្ធនឹងសំណួរបន្ថែម ក្រោយពីសហ -- ធ្វើការសាកសួរមកហើយ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** លោកជាអ្នកសិក្សាមួយរូប ហើយមានការតានដាននូវប្រវត្តិរបស់ប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៣។ តាមពិតលោកបានមកក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩60 ដូចជា៦៩ បាទ។ រហូតមកដល់ពេលនេះ លោកបានមកបំភ្លឺនៅក្នុងតុលាការទៀត។ ដូច្នេះ សំណួរទី១ដែលខ្ញុំចង់ដឹងនោះថានៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ភ្លាម។ នៅពេលនោះ គឺកម្ពុជាប្រជាធិបេតយ្យមានការប្រជុំមួយៗព្រះវិហារព្រះកែវមរតក។ តើលោកមានបានដឹងនូវព័ត៌មាននេះដែរអត់ទេបាទ?

[១៥:0៦:២៦]

**លោក ស្មីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំមិនប្រាកដទេ។ ខ្ញុំមិនប្រាកដថាអ្វីដែលលោកចង់និយាយហ្នឹងសំដៅទៅលើអ្វីឲ្យច្បាស់នៅវត្តព្រះកែវមរកត។ ខ្ញុំធ្លាប់ឮអំពីហេតុការណ៍នោះដែរ ប៉ុន្តែឥឡូវនេះខ្ញុំកំពុងតែគិតថា តើខ្ញុំឮដោយខ្លួនឯង ឬមួយក៏ខ្ញុំដឹងដោយសារតែខ្ញុំធ្វើការនៅទីនេះ? ឥឡូវនេះ គឺថាប្រហែលជាខ្ញុំដឹង ខ្ញុំធ្លាប់ឮដោយខ្លួនឯង។

**ស៖** ចំណុចនេះ ខ្ញុំចង់ជម្រាបសួរថា ការប្រជុំនោះគឺមានការប្រជុំ តើប្រសិនបើលោកបានឮដូចថា បានឮ បានដឹង ឬមួយតាមរយៈការស្រាវជ្រាវក៏ដោយ តាមរយៈអីក៏ដោយ តើមានធ្វើសេចក្តីសម្រេចមួយដែលចែងអំពីការអនុវត្តគោលនយោបាយ បន្ទាប់ពីការខ្មែរក្រហមបានរំដោះភ្លាមទេបាទ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ថា មានប្រជុំនៅខែឧសភា ឆ្នាំ៧៥ ឬក៏ខែ៩ ឆ្នាំ៧៥នោះទេ។ ព្រោះថា ប្រសិនបើនៅខែឧសភា ឆ្នាំ៧៥ នៅមជ្ឈមណ្ឌលបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត ប៉ុន្តែនៅវិហារព្រះកែវមរកត ដូចជានៅខែ៩នោះទេ។ ដូច្នេះខ្ញុំមិនប្រាកដ ថាតើមានសេចក្តីសម្រេចណាខ្លះដែលខ្ញុំអាចរៀបរាប់ទាក់ទងទៅនឹងការប្រជុំ ក៏ជាការអនុវត្តសេចក្តីសម្រេចទាំងអស់នោះទេ។

**ស៖** តើមានការ -- ចំណុចមួយដែលលើកនោះ គឺមានការបំបិទមិនឲ្យមានទីផ្សារ ឬមួយមានការចាយលុយ ចាយអីហ្នឹង តើអាហ្នឹងលោកដែលស្រាវជ្រាវបានជួបប្រទះដែរ?

**ឆ៖** បញ្ហាទីផ្សារ គឺគេចាប់ផ្តើមនៅឆ្នាំ៧៣ ហើយបើតាមខ្ញុំចាំគឺថា គឺនៅការបញ្ឈប់ការប្រើប្រាស់រូបិយប័ណ្ណរបស់ខាងខ្មែរសាធារណរដ្ឋ ហើយគេមិនមានគម្រោងថាហ្នឹងជំនួសលុយអ្វីផ្សេងនោះទេ ប៉ុន្តែអានេះគឺកើតឡើងនៅក្នុងឆ្នាំ៧៣។ ប៉ុន្តែថ្ងៃ១៧ មេសា ឆ្នាំ៧៥វិញ គឺជាការបន្តគោលនយោបាយដែលបានធ្វើពីមុនរួចមកហើយទាក់ទងទៅនឹងតំបន់រំដោះ។ ហើយគេប្រើប្រាស់នៅទូទាំងប្រទេសតែម្តង គឺគោលការណ៍ទាក់ទងទៅនឹងទីផ្សារ និងលុយកាក់នេះ។

[១៥:០៩:៥៦]

**ស៖** បាទ លោកអម្បាញ់មិញ បានលើកឡើងពាក់ព័ន្ធនឹងការប្រជុំមួយ ដែលជាការប្រជុំនៅសាលាមិត្តភាពកម្ពុជា-សូវៀត នៅខែឧសភា។ ខ្ញុំចង់ដឹងថា តើការប្រជុំនោះប្រជុំលើកឡើងពីអ្វីខ្លះ? ហើយតើមាននរណាខ្លះដែលបានចូលរួមពេលប្រជុំនោះដែរបាទ?

**ឆ៖** ប្រសិនបើខ្ញុំចាំមិនខុសទេ គឺការប្រជុំរបស់កម្មាភិបាលនៅក្រោមថ្នាក់មជ្ឈិម គឺមកពីទូទាំងប្រទេសមកចូលរួមប្រជុំ ហើយមានការប្រជុំបែបនេះច្រើន ហើយការប្រជុំហ្នឹងមានទាំងកម្មាភិបាលមកពីភូមិភាគតំបន់ និងថ្នាក់ស្រុកផងដែរ។ ហើយបើតាមខ្ញុំចាំ គឺវាហាក់ដូចជាការប្រជុំដើម្បីផ្សព្វផ្សាយពីគោលនយោបាយ។ ហើយបើតាមដែលពាក្យគេនិយាយ គឺជាការប្រជុំដើម្បីធ្វើសេចក្តីសម្រេចទៅលើគោនយោបាយនានា។

**ស៖** ចុះចំពោះអ្វីដែលក្រោយពីការប្រជុំហើយ ហើយធ្វើការដើម្បីអនុវត្តនូវគោលនយោបាយទាំងនោះ តើគេធ្វើយ៉ាងដូចម្តេចដែរបាទ?

[១៥:១១:៤២]

**ឆ៖** ខ្ញុំគិតថា នេះគឺជាចម្ងល់មួយយ៉ាងច្រើនទាក់ទងទៅនឹងគោលនយោបាយ ដូចជាគោល-នយោបាយនៃការជម្លៀស គឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ ហ្នឹង ហើយក៏បន្តទៅទៀត គឺនិយាយអំពី

គោលនយោបាយនៃការមិនប្រើប្រាស់លុយកាក់ ដើម្បីជំរុញទៅដល់ល្បឿននៃការអនុវត្តគោលនយោបាយ ហើយបន្ទាប់មកទៀត គឺគោលនយោបាយទាក់ទងទៅនឹងព្រះពុទ្ធសាសនា ទាក់ទងទៅនឹងព្រះសង្ឃ និង គោលនយោបាយមួយទៀត គឺជាគោលនយោបាយក្នុងការស្វែងរកក៏ដូចជាការកំណត់ ក៏ដូចជាសម្លាប់ ទៅដល់មន្ត្រីរដ្ឋការ ឬក៏យោធារបស់របបចាស់នោះ។ ហើយនេះ អ្វីដែលគេធ្វើនេះ គេធ្វើបន្ទាប់ដើម្បី ចម្រាញ់បន្ទាប់អ្នកដែលគេមិនបានសម្លាប់នៅពេលសប្តាហ៍ដំបូងៗនៃខែមេសានោះ គឺគេសម្លាប់បន្តនៅ ពេលក្រោយ។

**ស៖** ពាក់ព័ន្ធនឹងការប្រជុំហ្នឹងដែរ តើលោកអាចផ្តល់ជាថ្ងៃ អាចថាបានដឹងថាថ្ងៃប្រជុំ ថ្ងៃណា ឬមួយពាក់ព័ន្ធឯកសារអីដែរ?

**ឆ៖** ដូចដែលខ្ញុំបាននិយាយអ៊ីចឹង គឺថាមិនមែនការប្រជុំតែមួយទេ គឺមានការប្រជុំជាបន្តបន្ទាប់ ច្រើនៗៗតគ្នា។ ហើយវាកើតឡើងនៅក្នុងចុងខែឧសភា ឆ្នាំ៧៥ ហើយបន្តទៅដល់ខែមិថុនា ឆ្នាំ៧៥ បន្តទៅទៀត។

[១៥:១៣:៤៣]

**ស៖** លោកអម្បាញ់មិញលើក -- មានបានលើកពាក់ព័ន្ធនឹងគោលនយោបាយផ្សេងៗ ហើយក្នុង នោះខ្ញុំចង់ដឹងថាតើនៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង អ្វីដែលលោកបានស្រាវជ្រាវ តើលោកបានដឹងទេ ពីបញ្ហាជនជាតិចាមមួយចំនួនដែលត្រូវគេធ្វើទុក្ខបុកម្នេញនោះបាទ?

**ឆ៖** បាទ គឺថាដំណើរការហ្នឹងគឺវាបន្តទៅមុខ គឺថាបន្តពីថ្ងៃ មុនថ្ងៃ១៧ មេសា ៧៥ ហើយបន្ត មកទៀត គឺវាចាប់ផ្តើមបន្តពីខែ៩ ខែ១០ ឆ្នាំ៧៥ ហើយកាន់តែធ្ងន់ធ្ងរទៀតនៅក្នុងឆ្នាំ៧៦-៧៧ បន្តរហូត ទៅដល់៧៨។ គឺលក្ខខណ្ឌស្ថានភាពហ្នឹង វាកាន់តែធ្ងន់ធ្ងរឡើងៗពី១ឆ្នាំទៅ១ឆ្នាំ។

**ស៖** ខ្ញុំចង់បញ្ជាក់ថា តើលោកក្រោយពីលោកបានស្រាវជ្រាវ តើគេបានប្រព្រឹត្តទៅលើជនជាតិ ចាមហ្នឹងយ៉ាងដូចម្តេច ថាវាពាក់ព័ន្ធនឹងសាសនាដែលគាត់បានប្រារព្ធ ឬមួយយ៉ាងម៉េចបាទ?

**ឆ៖** គឺថាចាប់តាំងពីឆ្នាំ -- ដើម៧៣មក ខ្ញុំចាំថាវាគឺជាការរារាំង ឬក៏ការមិនជំរុញឲ្យមានការ អនុវត្តសាសនា ក៏ដូចជាការរារាំងទៅលើសាសនា ហើយកន្លែងខ្លះទៀតគឺដែលថាមានជនជាតិចាមហ្នឹង គឺមិននៅជាដុំ ជារួមគ្នានោះទេនៅក្នុងតំបន់ខ្លះ។ ដូច្នេះនៅតាមតំបន់ខ្លះគឺមានជនជាតិចាមដែលគាត់មាន តួនាទី ឬក៏មានសិទ្ធិអំណាចផ្នែករដ្ឋអំណាចនានា ប៉ុន្តែទាំងអស់នេះគឺកើតឡើងមុនឆ្នាំ៧៥ ហើយនិង បន្តបន្តិចដែររហូតដល់ក្រោយឆ្នាំ៧៥។ ប៉ុន្តែចំពោះគោលនយោបាយក្នុងការកម្ទេច ឬក៏បំផ្លាញជនជាតិ

ចាមទាំងមូលគឺមិនច្បាស់លាស់ ហើយវាហាក់ដូចជាកើតឡើងរហូតដល់ចុងឆ្នាំ៧៥។ ហើយវាមានបញ្ហានេះកើតឡើងបន្តរហូតដល់ពាក់កណ្តាលឆ្នាំ៧៨ ទៅតាមស្ថានភាព ទៅតាមបញ្ហាជាក់ស្តែងដែលកើតឡើង។

[១៥:១៧:០៨]

**ស៖** ថាតើការអនុវត្តគោលនយោបាយនេះ គឺធ្វើឲ្យប៉ះពាល់ទៅដល់ប្រជាជនហ្នឹងដល់កម្រិតណា? ដែលធ្វើឲ្យគាត់មានការបាក់ស្បាត ឬមួយមានការឈឺចាប់មានការរងគ្រោះរហូតដល់ មានការស្លាប់ អត់អាហារ ឬមួយយ៉ាងម៉េច? ហើយតើគោលនយោបាយទាំងអស់នោះវាផ្តល់ផលវិបាកយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោកខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះដោយហេតុថាសំណួរនេះវាធ្វើឲ្យសាក្សីធ្វើការវិភាគ ដែលមិនមានជាសមាសភាពរបស់សាក្សីក្នុងឋានៈជាសាក្សីនោះទេ។ អ៊ីចឹងគាត់មិនអាចប្រើប្រាស់ការវិភាគក្នុងនាមជាសាក្សីជំនាញឡើយនៅក្នុងពេលនេះ។ បាទ សូមអរគុណ។

**លោក ឡោ ជុនធី៖**

បាទ លោកប្រធាន ខ្ញុំសូមបញ្ជាក់បន្តិច។ អ្វីដែលសំណួររបស់ខ្ញុំ ខ្ញុំចង់បញ្ជាក់ថាអ្វីដែលគាត់បានស្រាវជ្រាវ អ្វីដែលគាត់បានជួបប្រទះ អ្វីដែលគាត់បានសម្ភាសទៅលើអ្នកដែលបានរងគ្រោះហ្នឹង តើបានជួបប្រទះនូវការដែលគាត់បាននិយាយហ្នឹងឈឺចាប់យ៉ាងម៉េច? រងគ្រោះយ៉ាងម៉េច? នេះគឺជាព័ត៌មានទេ មិនមែនជាការវែកញែករបស់គាត់ទេ។

[១៥:១៨:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីរបស់លោកខៀវ សំផន ចំពោះសំណួរនេះត្រឹមត្រូវណាស់។ លោកគិតឲ្យបានច្បាស់លាស់ ឋានៈលោក ស៊ីវិន ហេដឌ័រ នៅចំពោះមុខអង្គជំនុំជម្រះនេះ គឺសាក្សី មិនមែនឋានៈជាអ្នកជំនាញទេ។

**លោក ឡៅ ជុនធី៖**

**ស៖** សំណួរបន្តខ្ញុំ -- អ្វីដែលលោកបានសម្ភាសប្រជាជនដែលភៀសខ្លួនទៅខាងព្រំដែនកម្ពុជាថៃនោះខ្ញុំចង់ដឹងថាតើការសម្ភាសហ្នឹងសម្ភាសចេញពីប្រភពប្រជាជនណាខ្លះបាទ?

**ឆ៖** ខ្ញុំគិតថាភាគច្រើននៃពួកគាត់ គឺជាអ្នកដែលមានឋានៈខ្ពស់នៅក្នុងរបបខ្មែរសាធារណរដ្ឋជាយោធាឬក៏ជាមន្ត្រីរដ្ឋការដែលមកពីទិសខាងបូព៌ា ឬក៏ខាងបស្ចិម ខ្ញុំគិតថាពួកគាត់អ្នកខ្លះមកពីភ្នំពេញផងដែរ។ បើតាមខ្ញុំចាំ ខ្ញុំបាននិយាយអំពីបញ្ហាមួយនេះ គឺបញ្ហាជនភៀសខ្លួន ហើយបុគ្គលនុំងគាត់មកពីទីក្រុងភ្នំពេញ ហើយអ្នកខ្លះទៀត ហើយមានម្នាក់នុំងគាត់មកពីភ្នំពេញ បាទ នៅម្តុំព្រែកក្តាម ហើយគាត់ផ្លាយមកដល់ព្រំដែនថៃ ប៉ុន្តែយ៉ាងណាក៏ដោយប្រភេទពួកគាត់ហ្នឹងគឺមានចំនួនតិចតួចទេ គឺថាអ្នកដែលខ្ញុំបានជួបសម្ភាសនៅព្រំដែនថៃ មុនពេលដែលខ្ញុំបានមកខាងប្រទេសឡាវបន្តទៀត។

**ស៖** បាទ អរគុណ។ តើនៅក្នុងអំឡុងឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ តើលោកបានដឹងអ្វីខ្លះអំពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំចង់ជម្រាបសួរថា ក្នុងអំឡុងពេលនោះ តើនៅក្នុងការចាប់អារម្មណ៍ជាអន្តរជាតិហ្នឹង នៅក្នុងឆាកអន្តរជាតិហ្នឹង តើគេមានការចាប់អារម្មណ៍អ្វីខ្លះដែរ អំពីកម្ពុជាប្រជាធិប-តេយ្យនឹងបាទ?

[១៥:២១:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។

អម្បាញ់មិញនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកទីសំណួរទៅសាក្សី។ ទី១ ទាក់ទងទៅនឹងការដែលសាក្សីបានដឹងនូវអ្វីដែលកើតឡើងនៅរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ៧៩។ ចំណុចនេះវាទូលំទូលាយពេក បើសម្រាប់សាក្សីធ្វើការឆ្លើយបញ្ជាក់ទៅលើចំណុចនេះវាពុំមានភាពច្បាស់លាស់ទេ ហើយមេធាវីគួរបញ្ជាក់លម្អិតទៅលើចំណុចណាស់ដែលខ្លួនចង់បាន។ ទី២ ទាក់ទងទៅនឹងចំណុចដែលសារព័ត៌មានអន្តរជាតិធ្វើការចាប់អារម្មណ៍អំពីព្រឹត្តិការណ៍នៅប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ វាបង្ហាញពីគំនិតនៃការធ្វើវិភាគរបស់សាក្សីរូបនេះទៀតហើយ។ ដូច្នេះ

ខ្ញុំសូមជំទាស់។ សូមអរគុណ។

[១៥:២២:០២]

**លោក ឡោ ជុនធី៖**

អ៊ីចេះ ដោយសារខ្ញុំលើកសំណួរនេះ យើងមើលទៅថាវាលាតសន្ធឹងធំណាស់ ប៉ុន្តែអ្វីសំណួរដែលខ្ញុំចាប់អារម្មណ៍ចុងក្រោយ គឺថាចង់ឲ្យគាត់លើកឡើងតែបន្តិចទេថា តើអ្វីដែលការចាប់អារម្មណ៍ជាអន្តរជាតិហ្នឹង មានលក្ខណៈយ៉ាងម៉េចនៅពេលដែលកម្ពុជាប្រជាធិបតេយ្យត្រូវបិទព័ត៌មានឈឹងហ្នឹងបាទ។ តែប៉ុណ្ណឹងទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មានលក្ខណៈសមស្របហើយ។ សំណួរនេះ គឺអាចសួរបានក្នុងនាមឋានៈគាត់ជាអ្នកជំនាញ ប៉ុន្តែជាសាក្សីមិនអាចតាំងសំណួរបែបនេះបានទេ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំសូមមួយសំណួរទៀតចុងក្រោយដែលពាក់ព័ន្ធនឹង -- នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានការទំនាក់ទំនងប្រាស្រ័យទាក់ទងគ្នាពីលើទៅក្រោម។ ខ្ញុំចង់ដឹងថា តើការទំនាក់ទំនងគេហ្នឹងតាមមធ្យោបាយអីខ្លះបាទ?

[១៥:២៣:៣៧]

**លោក ស៊ីវ ហេងផ័រ៖**

**ឆ៖** ទៅតាមដែលខ្ញុំដឹង គឺមានការទំនាក់ទំនងតាមទូរលេខទៅវិញទៅមក។ មានការទំនាក់ទំនងជាលាយលក្ខណ៍អក្សរពីលើ -- ពីក្រោមទៅលើ ពីលើទៅក្រោម ហើយមានការប្រជុំពិភាក្សាគ្នាដើម្បីចែករំលែកនូវព័ត៌មានពីខាងលើមកក្រោម និងពីក្រោមទៅលើ ហើយនិងមានករណីខ្លះទៀត គឺការនិយាយគ្នា ឬក៏ការទំនាក់ទំនងដោយផ្ទាល់មាត់តែម្តង គឺថាមានមធ្យោបាយក្នុងការទាក់ទង ទី១ គឺសារទូរលេខ។ ទី២ គឺការទំនាក់ទំនងជាលាយលក្ខណៈអក្សរ ដែលគេហៅថា “របាយការណ៍” ហើយនិងការទំនាក់ទំនងដោយផ្ទាល់មាត់ ដូចជាការប្រជុំពិភាក្សាគ្នាជាដើម។

**លោក ឡោ ជុនធី៖**

បាទ ខ្ញុំអស់សំណួរហើយ ខ្ញុំអរគុណលោកជាច្រើន ហើយលោកប្រធាន អរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៥:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ស្ទីវ ហេដឌ័រ។ ហើយដោយសារអង្គជំនុំជម្រះមានកិច្ចការមួយទៀត ដែលអង្គជំនុំជម្រះត្រូវការពេលវេលាដើម្បីស្តាប់ភាគីធ្វើសារណាតបទៅនឹងសំណើសុំរបស់លោកក្រុមមេធាវីការពារក្តីលោក នួន ជា ដែលបានរំឭកដល់អង្គជំនុំជម្រះកាលពីមុននេះបន្តិចនោះ។ ហើយដូច្នេះពេលវេលាដែលនៅសេសសល់នេះ ទំនងជាមិនអាចបន្តសវនាការស្តាប់សក្ខីកម្មសាក្សី ស្ទីវ ហេដឌ័រ បានទៀតទេនៅរសៀលនេះ។ ដូច្នេះគឺអង្គជំនុំជម្រះថាកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺសមរម្យជិតដល់ពេលសម្រាកហើយ ហើយដោយសារអង្គជំនុំជម្រះត្រូវមានកិច្ចការមួយត្រូវធ្វើទៀត។ ដូច្នេះអង្គជំនុំជម្រះសូមជម្រាបជូនលោក ស្ទីវ ហេដឌ័រ ថាការស្តាប់សក្ខីកម្មរបស់លោកនៅរសៀលនេះ អង្គជំនុំជម្រះសម្រេចផ្អាកត្រឹមនេះសិន។ ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកបន្តធ្វើនៅថ្ងៃស្អែកទៀតវេលាម៉ោងប្រាំបួនព្រឹក។ ដូច្នេះ អង្គជំនុំជម្រះសូមកោះអញ្ជើញលោក ស្ទីវ ហេដឌ័រ មកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតនៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស្ទីវ ហេដឌ័រ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបាននៅម៉ោងប្រាំបួនព្រឹក។

លោក ស្ទីវ ហេដឌ័រ អាចចាកចេញបានហើយ សូមអញ្ជើញលោកចាកចេញទៅចុះ!

[១៥:២៧:២៣]

បាទ អង្គជំនុំជម្រះបានទទួលនូវសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា សូមឲ្យអង្គជំនុំជម្រះទទួលយកនូវភស្តុតាងថ្មី ដោយការស្តាប់នូវសក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-382។ ឯកសារ E294 ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ ថាអង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនទៅភាគីដែលពាក់ព័ន្ធ ដូចជាសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសារណារផ្ទាល់មាត់ឆ្លើយតបនៅក្នុងកិច្ចដំណើរការសវនាការនេះបន្ទាប់ពីការស្តាប់សក្ខីកម្មដែលលោក ស្ទីវ ហេដឌ័រ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចប់។

ឥឡូវនេះ បានចប់ហើយ ដូច្នេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការធ្វើសារណាតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ដែលមានខ្លឹមសារដូចនៅក្នុងឯកសារ E294។

[១៥:២៨:៣៨]

លោកតំណាងសហព្រះរាជអាជ្ញាអាចសម្រាកសិន មានការជំទាស់តវ៉ាពីមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែធ្វើសំណើមួយ ចង់ដឹងថាតើលោកប្រធានធ្វើដំណាក់កាលយ៉ាងដូចម្តេច? ព្រោះថាក្រុម ខៀវ សំផន មិនទាន់បានទៅធ្វើការកត់សម្គាល់លើសំណើរបស់ក្រុម នួន ជា ដែលយើងគាំទ្រនោះទេ។ តើលោកប្រធានចង់ឲ្យខ្ញុំធ្វើការកត់សម្គាល់ដោយសង្ខេប មុនពេលដែលសហព្រះរាជអាជ្ញា ហើយនិងមេធាវីនាំមុខនោះចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួន ឬក៏យ៉ាងណា? អ៊ីចឹងខ្ញុំសូមឲ្យលោកប្រធានឲ្យជាយោបល់ ថាឲ្យខ្ញុំធ្វើយ៉ាងម៉េច?

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៩:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ បើក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងដូច្នេះ សូមអញ្ជើញបាទ ដើម្បីសម្រួលដល់នីតិវិធីនៃការប្រព្រឹត្តទៅដែលមានភាពប្រាកដប្រជានៅលើសំណើសុំ ហើយនិងបញ្ចាក់ជំហរនៅលើសំណើសុំជាមុនៗនឹងភាគីម្ខាងទៀតបង្ហាញនូវមតិយោបល់របស់ខ្លួន។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំឥឡូវយល់ថាលោកប្រធានអនុញ្ញាតឲ្យខ្ញុំធ្វើការកត់សម្គាល់ហើយឥឡូវនេះ។ សូមអរគុណ ខ្ញុំឃើញលោកចៅក្រម ឡាវែន៍ គាត់ធ្វើសញ្ញាយល់ព្រម។ ជាគោលការណ៍ ខ្ញុំគាំទ្រអំណះអំណាងរបស់ក្រុម នួន ជា ទាំងស្រុង ដោយហេតុថា ដោយសារភស្តុតាងថ្មីទាំងអស់នេះ ដែលជាកុន ខ្សែភាពយន្តទាក់ទងទៅនឹងអង្គហេតុនៅទួលពោធិ៍ជ្រៃ ហើយសំណើសុំស្តាប់សាក្សី TCW-382។ យើងសូមគាំទ្រក្រុមមេធាវីរបស់ នួន ជា។ ហេតុអ្វីបានយើងគាំទ្រ ហេតុផលដូចតទៅនេះ តាំងពីដើមមកក្នុងសវនាការទាក់ទងនឹងឯកសារ ជាពិសេសពិសេសទាក់ទងទៅនឹងខ្សែភាពយន្ត យើងតែងតែលើកឡើងថា នៅពេល

ដែលយើងពុំមានខ្សែភាពយន្តស្រុងនោះទេ ព្រោះថាមានការកាត់ត អង្គជំនុំជម្រះចាំហើយសវនាការតាំងពីដើមមកនោះ ទាក់ទងទៅនឹងសម្រង់កិច្ចសម្ភាសន៍វីដេអូរបស់លោក ខៀវ សំផន នោះបានដាក់បញ្ចូលនៅក្នុងសំណុំរឿងហើយ។ យើងបានពន្យល់ហើយកាលនោះថា នៅពេលដែលមានត្រឹមតែសម្រង់ទេ យើងមិនមានន័យគ្រប់គ្រាន់ទាំងស្រុងទេ។ ហើយអ៊ីចឹងនៅក្នុងករណីនេះ ដែលយើងមានសម្រង់ខ្សែភាពយន្តមួយចំនួនពុំមានបរិបទច្បាស់លាស់ ដកចេញពីការថតអស់រយៈពេលច្រើនម៉ោង ហើយនិងពាក្យពេចន៍ទាំងអស់ដែលគេបាននិយាយឡើងហ្នឹង ហើយដែលផលិតករ សមិទ្ធករ បើសិនគាត់មិនអាចមកពន្យល់អំពីរបៀបកាត់ត ឬក៏លក្ខខណ្ឌដែលអ្នកដែលគេសម្ភាសទាំងអស់នោះ គាត់មាននិយាយអីលើសពីហ្នឹងទៀត។ តើអ្នកផ្សេងទៀត អ្នកដែលគេបានសម្ភាសហ្នឹង គាត់បានលើកបង្ហាញអំពីភស្តុតាងដោះបន្ទុកនោះ។ អ៊ីចឹងមិនអាចទៅរួចទេ ត្រូវតែគិតពិចារណាអំពីបញ្ហានេះទាំងអស់។

[១៥:៣២:៤០]

ក្រុម នួន ជា បានលើកឡើងថា ខ្លួនត្រូវតែលើកឡើងរឿងនេះ ព្រោះថាជារឿង ជាមានព័ត៌មានដោះបន្ទុកជាច្រើន។ ហើយទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួមនេះ គឺអ្វីដែលព័ត៌មានទាំងឡាយដែលថាអាចដោះបន្ទុកលោក ខៀវ សំផន ដែរ អ៊ីចឹងហើយបានយើងសុំគាំទ្រទាំងស្រុងទៅសំណើរបស់ក្រុម នួន ជា ហើយយើងបានផ្ទុះបង្ហាញតាំងពីដើមមកហើយ គឺថាពេលខ្លះហ្នឹងនៅពេលដែលយើងមានព័ត៌មានដែលពុំមានបរិបទនោះ គឺថាយើងមិនអាចយល់គ្រប់ជ្រោយទេ។ ហើយសព្វថ្ងៃ ឥឡូវនេះនៅពេលដែលថាយើងអាចកោះហៅសមិទ្ធករ ហើយឬផលិតករហ្នឹងមកនោះ ហើយយើងត្រូវតែអញ្ជើញគាត់មកដើម្បីឱ្យបានព័ត៌មានទាំងអស់នេះឱ្យមានព័ត៌មានគ្រប់ជ្រុងជ្រោយ ជាឱកាសដ៏ល្អសម្រាប់យើងហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសឡើងធ្វើសារណាតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តី។

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ តាំងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញា ជាបឋមខ្ញុំសូមលើកឡើងថា ដើម្បីបញ្ជាក់ មានចំណុចចំនួនបីនៅក្នុងសំណើសុំនេះ។ ទី១ គឺស្នើសុំឱ្យទទួលយកអ៊ីម៉ែលចូលមកធ្វើជាភស្តុតាង។ សំណើទី២ ឱ្យអង្គ -- ស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការស៊ើបអង្កេតអនុលោមតាម

វិធាន៩៣។ ហើយសំណើសុំទី៣ ដូចដែលមេធាវីការពារក្តីអម្បាញ់មិញបានលើកឡើង គឺសំណើពាក់ព័ន្ធទៅនឹងការស្នើសុំឱ្យកោះហៅបុគ្គលមួយរូបដែលមានឈ្មោះរហស្សនាម TCW-382។ ដូច្នេះ ខ្ញុំសូមហៅបុគ្គលរូបនេះថា TCW-382 ដែលគាត់ជាអ្នកផ្ញើអ៊ីម៉ែលទទួលបានកាលពីសប្តាហ៍មុន។

[១៥:៣៥:០៦]

ចំណុចដែលពាក់ព័ន្ធផងដែរ គឺ TCW-720 ដែលជាបុគ្គលមួយរូបទៀតពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការរៀបចំខ្សែវីដេអូដូចដែលបានលើកឡើងយោងអម្បាញ់មិញនេះ។ មុនពេលដែលខ្ញុំឆ្លើយតប ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា កាលពីរសៀលម្សិលមិញ គឺយើងខ្ញុំបានបញ្ជូនទៅអង្គជំនុំជម្រះ តាមរយៈមន្ត្រីច្បាប់របស់យើង ហើយក៏បានបញ្ជូនទៅមេធាវីការពារក្តីសំណុំឯកសារចំនួនប្រាំបួនដែលជាឯកសារកំណត់ហេតុស្តាប់ចម្លើយសាធារណៈដែលពាក់ព័ន្ធទៅនឹងបុគ្គលស្នើសុំនេះ។ ជាសង្ខេប មុនពេលដែលយើងខ្ញុំឆ្លើយតបសំណើសុំដោយសង្ខេប តំណាងសហព្រះរាជអាជ្ញាសូមជំទាស់ចំពោះសំណើសុំពីរចំណុចក្នុងចំណោមបី ជាពិសេសយើងខ្ញុំសូមជំទាស់ការស្នើសុំឱ្យទទួលយកអ៊ីម៉ែល ហើយយើងខ្ញុំសូមជំទាស់ការស្នើសុំសាក្សី TCW-382 ឱ្យមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី។

យើងឯកភាពត្រង់ផ្នែកខ្លះទៅលើសំណើសុំនេះ ក្រោយពីបានកែប្រែរួចមកហើយដោយមេធាវីការពារក្តី ហើយខ្ញុំលើកឡើងចំណុចនេះក្នុងពេលបន្តិចទៀត។ តាមរយៈសេចក្តីផ្តើមយើងខ្ញុំសូមលើកឡើងជូនអង្គជំនុំជម្រះថា ប្រហែលជាដូចអង្គជំនុំជម្រះបានជ្រាបយើងខ្ញុំមានការភ្ញាក់ផ្អើលណាស់ នៅពេលដែលមានការបញ្ជូនការឆ្លើយឆ្លងពីបុគ្គលមួយរូបនេះ ដែលកាលពីមុនគាត់បដិសេធមិនសហការជាមួយតុលាការនេះឡើយ នៅពេលដែលស្នើសុំគាត់ឱ្យផ្តល់នូវសម្ភារៈឯកសារនានាដែលគាត់បានផ្សព្វផ្សាយក្នុងជាសាធារណៈ។ ដូច្នេះ យើងត្រូវយល់អំពីហេតុអ្វីបានជាស្នើសុំសំណើដូច្នេះក្នុងពេលនេះ។ ហើយប្រហែលជាធ្វើយ៉ាងណាឱ្យយើងយល់ឱ្យបានត្រឹមត្រូវ ថាគាត់គួរតែផ្តល់ព័ត៌មានតាមច្រកណាមួយផ្លូវការមកជូនតុលាការតាមរយៈភាគីណាផ្សេងដែលគាត់យល់ថាសមស្រប។ យើងខ្ញុំសូមសន្និដ្ឋានថាបុគ្គលរូបនេះទោះបីជាមានព័ត៌មានក៏ដោយ គឺមានព័ត៌មានតិចតួចណាស់ក្នុងនាមជាសាក្សី មិនមែនជាអ្នកជំនាញទេ ហើយវាពាក់ព័ន្ធដែលយើងត្រូវពិនិត្យមើលថាតើបុគ្គលរូបនេះគាត់បានចូលរួមនៅក្នុងការប្រមូលភស្តុតាងណាខ្លះដែលស្នើសុំថាមានភាពពាក់ព័ន្ធនោះ ហើយយើងគួរតែពិនិត្យគុណវុឌ្ឍិ និងបទពិសោធន៍របស់គាត់ តើគាត់មានគុណវុឌ្ឍិ បទពិសោធន៍អ្វីខ្លះ? បុគ្គលរូបនេះគឺជាអ្នកមានជំនាញក្នុងការបង្កើតផលិតខ្សែវីដេអូ ក៏ប៉ុន្តែគាត់មិនមានជំនាញនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម ឬក៏អំពីរចនា

សម្ព័ន្ធអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងគោលនយោបាយនោះទេ។

[១៥:៣៨:២៤]

ប្រសិនបើយើងមើលឯកសារលេខ៧ និងឯកសារ៦ ដែលយើងខ្ញុំបានបញ្ជូនរួចហើយនោះ ដោយមិនចាំបាច់លើកឡើងចំណុចលម្អិតទាំងអស់នោះទេ។ ឯកសារទាំងអស់នេះបានបង្ហាញថាសាវតារ របស់គាត់ដំបូងជាអ្នកភ្លេង បន្ទាប់មកគាត់ជាអ្នករៀបចំចងក្រងខ្សែវីដេអូដែលថតទៅលើរឿងជាច្រើន ប្រធានបទ។ ហើយគឺគាត់បានធ្វើការផលិតរឿងចំនួនពីរដែលវាពាក់ព័ន្ធទៅនឹងបញ្ហាប្រទេសកម្ពុជា។ គាត់មិនមានគុណវុឌ្ឍិ វិជ្ជាជីវៈតាមដែលយើងដឹងនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម ឬក្នុងចលនាខ្មែរ ក្រហមនោះទេ។ ហើយជាពិសេសតាមអ្វីដែលខ្ញុំអាចបានប្រាប់ នោះគាត់មិនដែលធ្វើការស្រាវជ្រាវលើ ប្រវត្តិខ្មែរក្រហមប្រវត្តិសាស្ត្រនោះទេ។ គាត់គ្មានជំនាញក្រៅពីការងារដែលដឹកនាំដោយ TCW-720 នោះទេ។ ដូច្នេះតាមរយៈភស្តុតាងឯកសារដែលមាននៅជាសាធារណៈគាត់មានទស្សនៈតិចតួចតែប៉ុណ្ណោះ នៅក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំសូមលើកជាឧទាហរណ៍មួយដែលជាការបង្ហាញនៅ ក្នុងករណីនេះ។

នៅក្នុងឯកសារលេខ១ ទំព័រដំបូងគឺ ជាកិច្ចសម្ភាសន៍តាមវ៉ាដ្យូ គាត់បានសួរថាតើ TCW-720 បានទទួលបានអ្វីខ្លះ? គឺខ្ញុំសូមដកស្រង់ "គាត់បានទទួលការយល់ច្រើននឹងព័ត៌មានច្រើនអំពីខ្មែរក្រហម របបខ្មែរក្រហម ហើយធ្លាប់បានប្រមូលព័ត៌មានទាំងអស់នេះកាលពីលើកមុន"។ បុគ្គលរូបនេះ គឺគាត់ មិនបានដឹងនូវសេចក្តីថ្លែងការណ៍ជាតិជាងមួយរយដែលធ្វើឡើងដោយមេធាវី -- ដែលធ្វើឡើងដោយ មេដឹកនាំខ្មែរក្រហមដូចដែរលោក ស្ទីវិន ហេដឌ័រ បានធ្លាប់ស្រាវជ្រាវ ដេវីដ ឆេនឌ័ល័រ, ដេវីដ ហក, ប៊ែន ឃៀរនិន, ម៉ៃខល វីឃើរី, ហ្វីលីព ស្សូត និងអ្នកដទៃៗទៀតនោះទេ។ គឺគាត់មិនដែលធ្លាប់បាន ប្រមូលព័ត៌មានដូចដែលបុគ្គលទាំងអស់រូបនោះឡើយ។ ខ្ញុំមិនមែននិយាយក្នុងនាមអ្នកទាំងនេះនោះទេ ក៏ប៉ុន្តែអ្នកទាំងអស់នេះ គឺធ្លាប់មានបទពិសោធន៍ជាច្រើនឆ្នាំ ស្រាវជ្រាវអំពីបញ្ហាខ្មែរក្រហម។

[១៥:៤១:១៤]

មានការលើកឡើងខុសផងដែរ នៅក្នុងអ៊ីម៉ែលរបស់បុគ្គលរូបនេះ ដែលវាពាក់ព័ន្ធទៅនឹងភាព ទុកចិត្តទៅលើបុគ្គលរូបនេះ ដែលយើងអាចពិចារណាទៅលើបញ្ហាភស្តុតាងតាមរយៈអ៊ីម៉ែលដែលមេធាវី ការពារក្តីយល់ឃើញថាវាអាចមានតម្លៃជាភស្តុតាង។ នៅក្នុងកថាខណ្ឌទី២ នៅឯកសារ E294 យើង មានអ៊ីម៉ែលរួចមកហើយ ដែលបុគ្គលរូបនេះជាអ្នកជួយបញ្ជូនអ៊ីម៉ែលនោះ លើកឡើងអំពីបញ្ហា នួន ជា។

សូមដកស្រង់ "គាត់មិនឯកភាពថា មន្ត្រី លន់ នល់ នោះត្រូវបានសម្លាប់នោះទេ។ អ្វីដែលគាត់និយាយគឺមានមួយចំនួន មន្ត្រីជាន់ខ្ពស់ លន់ នល់ មួយចំនួនត្រូវបានផ្តងកាត់បដិវត្តន៍ ហើយត្រូវបានចោទទោសរហូតដល់ស្លាប់ដោយសាលាក្តីយោធា។ តាមការចងចាំ នួន ជា មិនមែនជាសមាជិករបស់សាលាក្តីយោធានោះទេ។ នេះគឺជាការចោទប្រកាន់នូវអ្វីដែល នួន ជា លើកឡើងនៅក្នុងឌីវីឌី។ នៅលើ នៅក្នុងឌីវីឌីនោះ នៅក្នុងចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ", ឯកសារ E186.1.1R ត្រង់នាទី២០នាទីការជជែកគ្នា មានសរសេរ មានលើកឡើងដូចតទៅ៖ "អ៊ំ តើការបញ្ហារបស់មេដឹកនាំនៅរបបនោះ គឺយ៉ាងណាដែរ?" នួន ជា៖ គឺពួកគេគួរតែទទួលទោស ពួកគេក្បត់ជាតិ ដើម្បីចូលជាមួយនឹងជនបរទេស"។

[១៥:៤៣:០០]

ដូច្នេះ ចំណុចត្រង់នេះ អ្វីដែលអង្គជំនុំជម្រះបានឃើញ សាក្សី TCW-382 គឺគាត់មានភស្តុតាងដោះបន្ទុកច្រើនជាង នួន ជា ទៅទៀតប្រសិនបើមើលទៅតាមអ្វីដែលគាត់លើកឡើងនេះ។ ដោយមិនចាំបាច់មើលហេតុផល ដែលគាត់ហេតុអ្វីបានជាបញ្ជូនអ៊ីម៉ែលនេះមក គាត់ពិតជាខុសតាមរយៈដែលយើងពិនិត្យមើលទៅលើឌីវីឌីរបស់គាត់។

ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ សមត្ថភាពស្រាវជ្រាវរបស់បុគ្គលរូបនេះ ដែលវាជាទឡ្ហីករណ៍យើងខ្ញុំជំទាស់ទៅលើការកោះហៅបុគ្គលរូបនេះជាសាក្សី ឬអ្នកជំនាញនោះ។ ឯកសារនេះបាន -- ដែលបានបញ្ជូនមក គឺបានបង្ហាញថា យ៉ាងហោចណាស់បំផុតនោះ គឺគាត់គ្រាន់តែជាអ្នកធ្វើដំណើរទេសចរណ៍ ហើយធ្វើជាអ្នកផលិតខ្សែវីដេអូ ដើរប្រមូលព័ត៌មានតែប៉ុណ្ណោះ។ ឯកសារលេខ៥ និង៦ មានសេចក្តីថ្លែងការណ៍របស់ TCW-382 បានបញ្ជាក់ថា គាត់មកប្រទេសកម្ពុជានៅក្នុងឆ្នាំ២០០៦ ដើម្បីមករៀបចំថតខ្សែវីដេអូតែប៉ុណ្ណោះ គាត់និយាយដូច្នេះ។

[១៥:៤៤:១៨]

នៅពេលនោះហើយដែលលោកបានជួបជាមួយនឹង TCW-720 ដែល TCW-720 នេះបានធ្វើការងារហ្នឹងប្រាំមួយ-ប្រាំពីរឆ្នាំរួចមកហើយ។ បន្ទាប់មក គឺគាត់បានចូលរួមគម្រោងខ្សែវីដេអូរបស់បុគ្គល TCW-720។ ទោះបីជាគាត់ចូលរួមក៏ដោយ គាត់ក៏មិនមានវត្តមាននៅក្នុងកិច្ចសម្ភាសន៍សំខាន់ៗនោះឡើយ។ ទាំងអស់នេះហើយគឺជាចំណុចដែលលើកឡើងនៅក្នុងពាក្យសុំរបស់មេធាវីការពារក្តី។ ប្រសិនយើងមើលសំណុំឯកសារលេខ១ ហើយខ្ញុំបានលើកឡើងមុនរួចមកហើយ គឺកិច្ចសម្ភាសន៍តាមវិទ្យុ។ តាមរយៈការទទួលស្គាល់របស់បុគ្គលរូបនេះ គឺគាត់ៗមិនមានអ្វីដែលពាក់ព័ន្ធសំខាន់ជាមួយនឹង

ការសម្ភាសនៅក្នុងខ្សែវីដេអូនោះទេ។ ខ្ញុំនឹងអានចំណុចនេះ ដោយសារតែមានសារៈសំខាន់នៅក្នុងសំណើរបស់ខ្ញុំ។ "សំណួរ៖ TCW-720 បានរៀបចំជាច្រើនមកហើយ ដើម្បីឱ្យបុគ្គលនេះជឿជាក់? ឆ្លើយ៖ អត់ទេ ជាទូទៅ ការដែលលាតត្រដាងឱ្យបានដឹងនៅក្នុងខ្សែវីដេអូនេះ បានរៀបចំឡើងដោយគាត់តែប៉ុណ្ណោះ"។ ក្រោមបន្ថិច "ក៏ប៉ុន្តែចំពោះបញ្ហាសម្ងាត់ជាមួយនឹង នួន ជា ហើយនិងមានទ្រឹស្តីមួយនៅក្នុងខ្សែវីដេអូ នួន ជា។ នៅពេលដែល នួន ជា ជួបជាមួយនឹងសម្លាប់ ថាហេតុអ្វីបានជាពួកគេចូលរួមនឹងការសម្លាប់?" ចំណុចនេះ គឺសាក្សី TCW-720 ដែលជាជនជាតិកម្ពុជានោះ ដែលគាត់បានទៅស្រាវជ្រាវហើយសួរទៅលើបុគ្គលទាំងអស់នេះ។ ទាំងអស់នេះគឺជាព័ត៌មាន ហើយបានបង្ហាញថាTCW-382 មិនមានវត្តមាននោះទេនៅក្នុងពេលដែលសម្ភាស នួន ជា នៅក្នុងចំណុចសំខាន់ៗនៅក្នុងខ្សែវីដេអូសម្ភាសនោះ។

[១៥:៤៦:២៣]

ចំពោះការដឹងឮអំពីបញ្ហាទួលពោធិ៍ជ្រៃ វីដេអូនោះគឺបានបង្ហាញនៅត្រង់នាទី៤៨វិនាទីថា TCW-720 ជាអ្នកធ្វើការស៊ើបអង្កេតការសម្លាប់រង្គាលជាច្រើនឆ្នាំកន្លងមក ហើយជាអ្នកដើររកបុគ្គលដែលអាចយកមកសម្ភាសលើបញ្ហាសម្លាប់រង្គាលនេះ។

ដូច្នេះការពិតទៅបុគ្គល TCW-382 នេះ គឺមិនមានជំនាញ ឬក៏បានដឹងអង្គហេតុអ្វី ដែលសមនឹងកោះហៅមកឱ្យរៀបរាប់ជូនអង្គជំនុំជម្រះនូវអ្វីដែលបុគ្គលទាំងឡាយបានលើកឡើង និងឆ្លើយកន្លងមកនោះទេ។

មានហេតុផលដទៃទៀត ហេតុអ្វីបានជាយើងខ្ញុំមានការស្នាក់ស្ទើរដូច្នេះ ឬក៏មានការព្រួយបារម្ភអំពីលទ្ធភាពដែលតុលាការ និងបណ្តាញព័ត៌មានពីបុគ្គលរូបនេះ។ យើងគួរតែមើលសេចក្តីថ្លែងការណ៍របស់បុគ្គលរូបនេះ ដែលបានធ្វើឡើងកាលពីអតីតកាលកន្លងមក។ ប្រសិនបើយើងមើលឯកសារលេខ២ ត្រង់ទី១ បុគ្គលរូបនេះបានបញ្ជាក់ឱ្យច្បាស់ថា គឺគាត់យល់ឃើញថា កិច្ចដំណើរការនីតិវិធីនេះ មិនសមនឹងការលាតត្រដាងនូវការពិតនោះទេ តាមអ្វីដែលគាត់សង្កេត។ ហើយគាត់បានលើកឡើងថា សំណួរគ្រាន់តែសួរថា តើចង់បានការពិត ឬក៏យុត្តិធម៌? គឺគេមិនអាចមានតាំងពីនោះទេ។ នេះជាអ្វី -- នេះជាចំណុចដែលបុគ្គលនេះលើកឡើង ឱ្យយើងជាអ្នកវិនិច្ឆ័យរៀងៗខ្លួនទៅ។

[១៥:៤៨:២៣]

លើសពីនេះ នៅក្នុងឯកសារលេខ៣ ត្រង់ទំព័រទី១ កិច្ចសម្ភាសន៍ឯករាជ្យជាមួយនឹងបុគ្គលឯករាជ្យ

TCW-382 បានបញ្ជាក់ថា ព័ត៌មានទាំងឡាយដែល TCW-720 ទទួលបាន គឺទទួលបានក្នុងលក្ខខណ្ឌថាមិនយកមកប្រើប្រាស់ដាក់បន្ទុកលើ នួន ជា។ ហើយគាត់បានលើកឡើងពាក់ព័ន្ធអ្នកដែលត្រូវសម្ភាសនោះ គឺខ្ញុំសូមដកស្រង់៖ “ពួកគេចូលរួមសម្ភាសជាមួយនឹងពួកគេ ក៏ប៉ុន្តែត្រូវតែរក្សាសន្យា។ ហើយខ្មែរក្រហមដទៃទៀត បាននិយាយជាមួយយើងខ្ញុំ ហើយពួកគេមិនចង់មកថ្លែងនៅក្នុងតុលាការនោះទេ”។ TCW-720 បញ្ជាក់ជំហររបស់គាត់ ថាគាត់រក្សាសន្យាហ្នឹងនៅក្នុងឯកសារលេខ៤ ដែលគាត់និយាយនៅក្នុងទំព័រ២ថា៖ “ប្រសិនបើខ្ញុំឲ្យឯកសារនេះទៅតុលាការ មានន័យថា ខ្ញុំជាអ្នកក្បត់ នួន ជា”។

ដូច្នេះ អង្គជំនុំជម្រះជាទីគោរព! យើងខ្ញុំមានមន្ទិលសង្ស័យអំពីឆន្ទៈរបស់បុគ្គលរូបនេះក្នុងការផ្តល់ព័ត៌មានទាំងឡាយដែលអង្គជំនុំជម្រះចង់បាន។ ហើយចំណុចនេះហើយ ធ្វើឲ្យខ្ញុំអាចនៅសង្ខេបនូវជំហររបស់ខ្ញុំ និងសេចក្តីបញ្ចប់របស់ខ្ញុំត្រឹមចំណុចនេះ។ ចំណុចទី១ ពាក់ព័ន្ធទៅនឹងអ៊ីម៉ែល យើងខ្ញុំជំទាស់កុំឲ្យទទួលយក មិនសមក្នុងការបង្ហាញការពិតនោះទេ។ វាគ្រាន់តែជាសេចក្តីថ្លែងការណ៍ដែលបុគ្គលនេះលើកឡើងថា នួន ជា បាននិយាយអ្វីខ្លះ។ នួន ជា នៅក្នុងតុលាការនេះ គាត់អាចនិយាយដោយខ្លួនឯងបាន។ ហើយខ្ញុំសូមបង្ហាញជូនអង្គជំនុំជម្រះថា បុគ្គលនេះការបកស្រាយបុគ្គលនេះទៅលើពាក្យ នួន ជា នោះ គ្មានអ្វីដែលយើងអាចឲ្យយើងទុកចិត្តបាននោះទេ។

[១៥:៥០:៣៣]

បន្ថែមលើចំណុចនេះ វាមិនសមស្របទាំងស្រុងក្នុងការទទួលយកអ៊ីម៉ែលនូវអ្វីដែលបុគ្គលម្នាក់បានលើកឡើង។ បុគ្គល -- នៅពេលដែលបុគ្គលរូបនេះមិនព្រមផ្តល់នូវខ្សែវីដេអូដើមតាំងពីដំបូង ដែលវាអាចមានចម្លើយនានាជាប្រយោជន៍ទៅដល់យើងទាំងអស់គ្នា។ ដូច្នេះ អ៊ីម៉ែលមិនអាចទុកចិត្តបានទេ ហើយវាមិនអាចសមនឹងបង្ហាញការពិតដែលតុលាការជាអ្នករកការពិតនោះទេ។ ហេតុដូច្នេះហើយ យើងមិនគួរទទួលយកអ៊ីម៉ែលនោះទេ។ វាគ្មានតម្លៃអ្វីជាភស្តុតាងឡើយ។

ចំពោះការកោះហៅបុគ្គលរូបនេះវិញ ដូចដែលហេតុផលដូចដែលខ្ញុំបានបង្ហាញរួចមកហើយ យើងខ្ញុំជំទាស់ថាបុគ្គលរូបនេះគ្មានដឹងការពិតអ្វីនោះទេ។ យើងមិនអាចយកបុគ្គលរូបនេះទៅប្រៀបធៀបជាមួយនឹង ស្ទីវ ហេដឌ័រ, ហ្វ្រង់ស្វ័រ ប៉ុងសូដ៍, ហ្វីលីព ស្សូត និងអ្នកជំនាញផ្សេងទៀតនោះទេ ដែលអ្នកជំនាញទាំងអស់ សាក្សីទាំងអស់នេះបានធ្វើការស្រាវជ្រាវជាច្រើនឆ្នាំរួចមកហើយ។

ប៉ុងសូដ៍ គឺជាសាក្សីបង្ហាញនូវអង្គហេតុការពិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បុគ្គលរូបនេះទាំងអស់បានស្ម័គ្រចិត្តផ្តល់ឯកសារដែលពួកគេមាន ហើយគឺគាត់ស្ម័គ្រចិត្តនឹងមកផ្តល់សក្ខីកម្មទៅ

លើឯកសារដែលគាត់មាន និងផ្តល់សក្ខីកម្មជូនដល់តុលាការ។ ដូច្នេះ ខ្ញុំសូមលើកឡើងសាជាថ្មី TCW-382 នេះមិនមែនអ្នកដែលមានជំនាញអ្វីនោះទេ។

[១៥:៥២:០៥]

ចំពោះទិដ្ឋភាពទី៣នៃពាក្យសុំស្នើសុំឱ្យមានការស៊ើបអង្កេត ខ្ញុំលើកឡើងដូចតទៅ៖ "យើងគាំទ្រក្រុមមេធាវីការពារក្តី នួន ជា ដូចក្រុមមេធាវីការពារក្តី ខៀវ សំផន ផងដែរ ប្រសិនបើគាត់ដាក់សំណើសមហេតុណាមួយស្នើសុំព័ត៌មាន ហើយសំណើនោះ គឺមានភាពពាក់ព័ន្ធ ហើយមានតម្លៃ។ ជាពិសេសប្រសិនបើគាត់ស្នើសុំឱ្យមានលក្ខណៈសមស្របស្នើសុំភស្តុតាងដោះបន្ទុកនោះ។

យើងខ្ញុំសូមជំទាស់ចំពោះការស្នើសុំយកព័ត៌មានពីបុគ្គលរូបនេះ ហើយនិងពី TCW-720។ យើងខ្ញុំលើកឡើងថា អ្នកទាំងអស់នោះ គឺយើងអាចស្នើសុំគាត់បាន ក៏ប៉ុន្តែមិនមែនឱ្យគាត់ធ្វើការបកស្រាយអ្វីដែលគាត់យល់នោះទេ គឺយើងអាចស្នើសុំឯកសារសម្ភារៈដែលគាត់មាន។ ប្រសិនបើគាត់មានវីដេអូ *ហ្វូតថេក* ខ្សែវីដេអូ ឬក៏សេចក្តីថ្លែងការណ៍ចម្លើយណាមួយនោះ គឺថាយើងខ្ញុំឯកសារថាឱ្យអង្គជំនុំជម្រះធ្វើការស្នើសុំឯកសារសម្ភារៈទាំងអស់នោះ។

ដូច្នេះ ដូចដែលខ្ញុំលើកឡើងពីដំបូងអ៊ីចឹង យើងខ្ញុំមានការព្រួយបារម្ភណាស់នៅពេលដែលយើងយើងពិនិត្យទៅលើការពិតដែលបានលើកឡើងថា ស្នើសុំព័ត៌មានពីបុគ្គលរូបនេះ ដូចដែលខ្ញុំបានបញ្ជាក់ហេតុផលរួចមកហើយ។

[១៥:៥៣:៣៣]

ខ្ញុំគួរតែបញ្ជាក់ដើម្បីឱ្យបានច្បាស់លាស់។ សំណើសុំនេះ យើងគួរតែស្នើសុំគាត់ គឺខ្សែវីដេអូទាំងស្រុងតែម្តង មិនមែនកាត់យកចំណុចដែលពាក់ព័ន្ធតែប៉ុណ្ណោះ ហើយក៏យើងអាចស្នើសុំទៅលើកំណត់ត្រាដែលគាត់រៀបចំជាមុនៗពេលដែលគាត់ផលិតជាខ្សែវីដេអូ។

នៅពេលដែលសម្ភារៈឯកសារទាំងអស់នេះបានទទួលរួចមកហើយ យើងខ្ញុំលើកឡើងថាអង្គជំនុំជម្រះអាចរៀបចំទៅតាមគោលការណ៍រក្សាការសម្ងាត់ ហើយផ្តល់ជូនទៅកាន់ភាគី ឬក៏ចៀសវាងកុំឱ្យមានការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មដើម្បីឱ្យ -- ដើម្បីរារាំងបុគ្គលដែលគាត់ផ្តល់ឯកសារនេះ មិនឱ្យទទួលនូវប្រយោជន៍សម្រាប់គាត់។

ដូច្នេះ ដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង យើងខ្ញុំជំទាស់មិនឱ្យទទួលយកអ៊ីម៉ែលនេះទេ ហើយនិងជំទាស់កុំឱ្យកោះហៅបុគ្គលរូបនេះ។ ដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង ទោះបីជំទាស់ក៏ដោយ យើងខ្ញុំនៅតែរក្សា

សិទ្ធិ និងឯកសារភាពឲ្យស្នើសុំឯកសារសម្ភារៈដែលយើងអាចស្នើសុំពីគាត់។ ហើយយើងខ្ញុំស្នើសុំថា អង្គជំនុំជម្រះគួរតែឆ្លើយតបទៅនឹងសំណើបញ្ហានេះឲ្យបានជាបន្ទាន់។ ហើយយើងគួរតែស្នើសុំទៅដល់គាត់ប្រសិនបើគាត់នោះមិនអាចផ្តល់ពេលវេលា -- មិនអាចផ្តល់ព័ត៌មានណាមួយក្នុងពេលវេលាសមស្របនោះ គឺថាយើងមិនអាចយល់ឃើញថាអ្វីដែលគាត់លើកឡើងនោះជាភស្តុតាងនោះទេ។ ទាំងអស់នេះគឺជាសេចក្តីសន្និដ្ឋាន និងការលើកឡើងរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ ហើយចុះក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី? សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ខ្ញុំមិនមានអ្វីនឹងលើកច្រើនទេ គ្រាន់តែសុំបញ្ជាក់ថា ពីសប្តាហ៍មុនលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត បានបញ្ជាក់អំពីគោលជំហរខាងយើងខ្ញុំរួចហើយ ហើយខ្ញុំគ្រាន់តែចង់សូមបញ្ជាក់ទៀតថា ខ្លឹមសារនៃអ៊ីម៉ែលរបស់សាក្សីដែលស្នើឡើងនេះនិយាយផ្តោតលើបញ្ហាពីរ។ ទី១ គឺគាត់និយាយបកស្រាយពីអ្វីដែល នួន ជា បាននិយាយនៅក្នុងវីដេអូ ហើយទី២ និយាយអំពីការវាយតម្លៃទៅលើភស្តុតាងដែលត្រូវបានបង្ហាញនៅចំពោះមុខតុលាការនេះពាក់ព័ន្ធទៅនឹងវីដេអូដែលលោកបានធ្វើ។ ខ្ញុំចង់សូមបញ្ជាក់ថា បុគ្គលដែលស្នើឡើងនោះគាត់មិនមែនជាអ្នកជំនាញទេ។ ហេតុដូច្នេះ ការដែលគាត់ធ្វើការបកស្រាយទៅលើខ្លឹមសារដោយបញ្ជាក់ថា ពិត ឬមិនពិតអំពីអ្វីដែលលោក នួន ជា បាននិយាយនោះ គឺជាការមិនសមហេតុផលទេ។ ដូច្នេះ ផ្នែកជាច្រើននៃអ៊ីម៉ែលរបស់គាត់មិនគួរ និងអាចទទួលយកបានទេ ហើយការបកស្រាយបែបនេះគឺជាចរិតលក្ខណៈនៃអ្នកជំនាញ។ ហើយម្យ៉ាងទៀត គាត់បានឈានចូលទៅដល់ធ្វើការវាយតម្លៃអំពីភស្តុតាងដែលបានលើកឡើងដែលជាផ្នែកមួយនៅក្នុងអ៊ីម៉ែលរបស់គាត់ ហើយដែលនេះមិនមែនជាតួនាទីរបស់គាត់ទៅទៀត។ ដូច្នេះពាក់ព័ន្ធទៅនឹងអ៊ីម៉ែលនេះ ខ្ញុំសូមស្នើថា ដូចសហព្រះរាជអាជ្ញាដែរ គឺសុំឲ្យបដិសេធចំពោះអ៊ីម៉ែលនេះ។ ហើយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងធ្វើការលើកជាមតិបន្ថែម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី។

[១៥:៥៧:២៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បាទ លោកប្រធានខ្ញុំនិយាយដោយខ្លីទេដើម្បីបន្ថែមទៅលើអ្វីដែលសហព្រះរាជអាជ្ញា និងសហភាតារបស់ខ្ញុំលើកឡើង។ ខ្ញុំគ្រាន់តែចង់បន្ថែមថា បើនិយាយពីផ្លូវច្បាប់វិញ បើខ្ញុំមិនច្រឡំទេគឺថាការធ្វើសេចក្ដីស្នើនោះថាវាមានសំណើចម្បងមួយដែលត្រូវបានទទួលស្គាល់ជាភស្តុតាងថ្មីហើយគឺមាន អ៊ីម៉ែលមួយដែលទទួលបានពីលោក លឹមគីន ហើយដែលអនុលោមទៅតាមវិធាន ៨៧.៤ ហើយនិងមានសំណើមួយវគ្គទៀតដែលចេញពីសំណើចម្បងនោះ ដែលសុំឲ្យគាត់មកធ្វើជាអ្នកជំនាញ ឬក៏អ្នកសាក្សី។ ហើយសំណើមួយទៀតដែលចេញពីសំណើហ្នឹង គឺថាសុំឲ្យធ្វើការស៊ើបអង្កេតថ្មីអនុលោមទៅតាមវិធាន ៩៣។ អ៊ីចឹងខ្ញុំទទួលតែសំណើចម្បងទេ។ ហើយបើសិនជាសំណើទី១នោះមិនត្រូវបានទទួលយល់ស្របទេ សំណើទីពីរ វាស្វ័យប្រវត្តិមិនអាចទទួលយកបានដែរ។ ហើយចំពោះអ៊ីម៉ែលនោះអនុលោមទៅតាមវិធាន៨៧(៣) គឺអ៊ីម៉ែលនេះពុំមានភាពពាក់ព័ន្ធទេ ហើយមិនអាចបង្ហាញអំពីអង្គហេតុបានទេ។ ខ្ញុំសូមកត់សម្គាល់ថា បុគ្គលរូបនេះមិនដឹងថាអ្វីដែលគេនិយាយនៅទីនេះទេ គាត់ផ្អែកទៅលើតែកាសែតភ្នំពេញប៉ុស្តិ៍តែប៉ុណ្ណោះ។ អ៊ីចឹងគំនិតរបស់គាត់នោះមានអ្វីដែលនៅគេនិយាយក្រៅពីសាលសវនាការនេះទេ។ គាត់យោងទៅលើចំណុចទាំងអស់នេះ។ អ៊ីចឹងលោកបុគ្គលរូបនេះ គាត់យល់ឃើញថា អ្វីដែលលោក នួន ជា និយាយនៅក្នុងរឿងនោះជាភាសាខ្មែរនោះ តាមពិតទៅមិនមែនជាពាក្យសម្ដីរបស់លោក នួន ជា ទេ គឺថាគាត់សំដៅនិយាយទៅលើអ្វីដែលនិយាយក្រៅពីនៅក្នុងរឿងខ្សែភាពយន្តនោះទេ។ បុគ្គលរូបនេះគាត់ដូចចង់និយាយអំពីអ្វីដែលភ្នំពេញប៉ុស្តិ៍លើកឡើងដោយស្រពិចស្រពិល។ អ៊ីចឹង សំណើរទី១ សំណើចម្បងទី១ នោះគ្រាន់តែបញ្ចូលអ៊ីម៉ែលក្នុងសំណុំរឿងនោះមិនមានលក្ខណៈហ្មត់ចត់ទេ។ អ៊ីចឹង មិនអាចចាត់ទុកថាអ៊ីម៉ែលនេះមានភាពពាក់ព័ន្ធ ហើយនិងបង្ហាញពីអង្គហេតុទេ។ អ៊ីចឹងទាក់ទងនឹងសំណើទី១នេះបើសិនជាតុលាការបដិសេធសំណើនេះ ត្រូវតែបដិសេធសំណើទាំងពីរផ្សេងទៀតនោះ ដែលគ្រាន់តែជាផ្នែកនៃសំណើចម្បងទី១នេះ។ លោក លឹមគីន មិនមែនជាសាក្សីទេ មិនមែនជាអ្នកជំនាញទេ។ ដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញហើយ គឺថាអ៊ីម៉ែលរបស់គាត់នេះមានលក្ខណៈស្រពេចស្រពិល អ៊ីចឹង យើងមិនគិតថាគាត់មកផ្ដល់សក្ខីកម្មនេះវាមានលក្ខណៈចាំបាច់ទេ។

[១៦:០០:៤៦]

ខ្ញុំសូមកត់សម្គាល់អំពីការសំណើបន្ថែមមួយទៀត គឺថា ខាងការពារក្ដីមិនដែលធ្វើសំណើហ្នឹងទេ

ពីមុនមក ហើយគ្រាន់តែធ្វើសំណើតាមរយៈអ៊ីម៉ែលហ្នឹងទេ។ អ៊ីចឹងបើសិនជាលោក នួន ជា នោះគាត់ខ្លួនគាត់ផ្ទាល់នោះ គាត់អស់រយៈ១ឆ្នាំមកហើយ បើគាត់យល់ឃើញថាសម្រង់វីដេអូទាំងអស់ហ្នឹងដែលត្រូវបានចាក់បង្ហាញនៅសវនាការនេះ វាផ្ទុះបញ្ចាំងពីពាក្យពេចន៍ដែលគាត់មិនបាននិយាយនោះ ហេតុអីក៏មេធាវីការពារគាត់មិនបានសុំដោយអនុលោមតាមវិធានផ្ទៃក្នុងហ្នឹង វិធាន៩៣នេះ ហើយហេតុអីក៏រហូតដល់ថ្ងៃនេះហើយបានមកហៅសាក្សីមក ដោយយកអ៊ីម៉ែលនោះទៅជា ធ្វើជាមូលដ្ឋាន។ អ៊ីចឹងឃើញថា វាគ្មានភាពពាក់ព័ន្ធអីទាំងអស់ ដោយសារមិនបាច់បង្ហាញពីអង្គហេតុអ្វីនោះទេ។ អ៊ីចឹងខ្ញុំសូមឲ្យ សូមបដិសេធសំណើទាំងបីហ្នឹងតែម្តង សំណើចម្បងទី១ ហើយនិងសំណើពីរបន្ទាប់មកទៀតដែលជាសំណើដែលចេញពីសំណើចម្បងមួយហ្នឹង ហើយសំណើហ្នឹងមិនសមស្របទាស់តែសោះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមអរគុណចំពោះមតិយោបល់គាំទ្រលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី។ សូមអញ្ជើញលោកមេធាវី!

[១៦:០២:២៣]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់អំពីបញ្ហានេះ ប៉ុន្តែថាតើខ្ញុំអាចឆ្លើយតបទៅនឹងសារណាទាំងអស់ដែលទើបតែបានលើកឡើង ឬមួយក៏ទុកឲ្យខ្ញុំធ្វើនៅថ្ងៃស្អែកដោយសារតែឥឡូវនេះ យើងដល់ពេលវេលាហើយ។ ប៉ុន្តែ ខ្ញុំ កន្លងមកខ្ញុំស្តាប់ឮរឿងឥតប្រយោជន៍ច្រើនណាស់។ ដូច្នេះ ឥឡូវនេះខ្ញុំចង់ឆ្លើយមែនទែននៅពេលឥឡូវនេះ។ ប៉ុន្តែខ្ញុំមើលទៅលោកចៅក្រម ខាតវ៉ាយថ៍ គាត់បញ្ជាក់ច្បាស់ហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៣:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត លោកមេធាវីការពារក្តី។ តាមធម្មតាគឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើទេ ប៉ុន្តែឥឡូវនេះ តាមសំណើសុំរបស់លោកអង្គជំនុំជម្រះយល់ឃើញថា មានលក្ខណៈសមស្របអង្គជំនុំជម្រះអនុញ្ញាត។ សូមលោកប្រើរយៈពេលខ្លីទៅបានហើយ ជៀសវាងលើការលើកឡើងលើបញ្ហានេះនៅសវនាការនៅថ្ងៃស្អែកទៀត។ បាទ សមស្រប គឺថាអាច ៥នាទីទៅបានហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេប។ លោកប្រធាន ជាដំបូងនេះ ខ្ញុំចង់និយាយអំពីអ្វីដែលកើតឡើងកាលពីថ្ងៃអង្គារ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបញ្ជាក់ឈ្មោះគាត់តែម្តង ព្រោះថា ខាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងប្រាំដងទៅហើយទាក់ទងទៅនឹងឈ្មោះនោះ គឺថា លោក រ៉ប់ លឹមគិន *(Rob Lemkin)* បានអានព័ត៌មានមួយនៅក្នុងសារព័ត៌មានភ្នំពេញប៉ុស្តិ៍ ហើយវាព័ត៌មាននោះវាមិនត្រឹមត្រូវ ដោយសារហេតុការណ៍ដែលកើតឡើងហ្នឹងវាមិនត្រឹមត្រូវ ដូចដែលកាសែតបានព័ត៌មាន។

[១៦:០៤:៤៣]

លោកចង់ជម្រាបមកយើងថា អ្វីដែលគាត់អានទៅលើព័ត៌មានហ្នឹង គឺបានលើកឡើងវាខុសពីអ្វីដែលគាត់ដឹង ខុសពីអ្វីដែលគាត់បានឃើញទាក់ទងទៅនឹងខ្សែភាពយន្តនេះ។ គាត់មិនស្នើសុំតាំងខ្លួនជាអ្នកជំនាញអ្វីនោះទេ។ ដូច្នេះហើយគាត់គ្រាន់តែចង់ឲ្យមានការកែប្រែទៅលើអ្វីដែលដំណើរការនៅក្នុងសវនាការនេះតែប៉ុណ្ណោះ។ ដូច្នេះ ជាការសំខាន់ដែលយើងត្រូវដឹងថាលោក រ៉ប់ លឹមគិន មិនមែនជាមនុស្សដែលចូលរួមដោយប្រយោលនៅក្នុងខ្សែភាពយន្តដែលយើងកំពុងនិយាយនោះទេ។ ប្រសិនបើយើងមើលតាមគេហទំព័រ ទៅដោយព័ត៌មាននានា គាត់គឺជាសហនិពន្ធ ក៏ដូចជាសហផលិតកររបស់ខ្សែភាពយន្តនេះ។

ដូច្នេះ ខ្ញុំគិតថាអស់លោក លោកស្រី ប្រហែលជាដឹងហើយ អំពីខ្សែភាពយន្តនេះ។ ហើយខ្សែភាពយន្តនេះ ត្រូវបានគេដកស្រង់យកមកបង្ហាញម្តងហើយម្តងទៀត ជាច្រើនដង នៅក្នុងបទបង្ហាញឯកសារគន្លឹះរបស់ខាងព្រះរាជអាជ្ញា។

[១៦:០៥:៥១]

ដូច្នេះចំពោះព្រះរាជអាជ្ញាខ្សែភាពយន្តនេះ គឺជាខ្សែភាពយន្តមួយដ៏សំខាន់នៅក្នុងការស្វែងរកការពិត ហើយជាភស្តុតាងគន្លឹះផងដែរ សម្រាប់ខាងមេធាវី នួន ជា។ ប្រសិនបើយើងពិនិត្យមើលទៅលើការដកស្រង់មួយទាក់ទងទៅនឹងការសម្ភាសនៅក្នុងខ្សែភាពយន្តនេះ គឺថាគាត់ ហើយនិងសហផលិតករសហអ្នកនិពន្ធ គឺថាមាននូវវីដេអូជាង១៦០ម៉ោង ហើយនិងខ្សែអាត់សំឡេងជាង១០០០។ ដូច្នេះ អ្វីដែលគាត់ចង់និយាយ គឺថាវា គឺថាមានខ្សែវីដេអូតិចតួចបំផុតដែលគាត់យកមកដាក់ចូលទៅក្នុងខ្សែភាពយន្តរបស់គាត់។ ដូច្នេះហើយវាមិនមាននៅគ្រប់ចំណុចទាំងអស់ដែលបានយកមកបង្ហាញ ឬក៏ដូចជាហេតុ

ការណ៍ដែលបានកើតឡើងទាំងអស់នៅភូមិភាគពាយ័ព្យ នៅក្នុងឆ្នាំ៧៥នោះទេ។ ដូច្នេះ គាត់ចង់និយាយថា ខ្ញុំមានខ្សែវីដេអូដែលបញ្ជាក់ច្បាស់ថា សកម្មភាពនៅខាងពាយ័ព្យ គឺធ្វើឡើងដោយពួកតំបន់ ពួកប្រធានតំបន់ គឺប្រធានភូមិភាគ គឺ រស់ ញឹម នោះទេ។

ដូច្នេះ ពាក់ព័ន្ធទៅនឹងពីរបីកថាខណ្ឌខាងដើមនៃអ៊ីម៉ែលរបស់គាត់ គឺកថាខណ្ឌចុងក្រោយនៃសារអេឡិចត្រូនិករបស់គាត់ គឺផ្ដល់នូវព័ត៌មានលម្អិតមួយ ហើយខ្ញុំបានបញ្ជាក់រួចហើយ កាលពីសប្ដាហ៍មុន គឺគាត់និយាយថា ខ្ញុំគិតថា លោក លោកស្រី ដឹងហើយ ដើម្បីជាសាធារណៈ លោក លឹមគិន និយាយថា "ម្យ៉ាងទៀត ពាក់ព័ន្ធទៅនឹងពោធិ៍ជ្រៃនេះ គឺជាការកាប់សម្លាប់ដែលបញ្ជាឡើងដោយ រស់ ញឹម មិនមែនដោយមជ្ឈិមនោះទេ។ យើងមាននូវព័ត៌មានភស្តុតាងជាច្រើនអំពីរបៀបវារៈរបស់ រស់ ញឹម ដែលកន្លងមកមិនបានបញ្ចប់ ដោយសារតែ ថេត សម្បត្តិ ទៅប្រទេសអាមេរិក"។ ដូច្នេះ យើងឃើញថា គាត់មាននូវខ្សែវីដូអូជាច្រើន ដូចដែលខ្ញុំបានបញ្ជាក់ពីដើមរួចមកហើយ។

[១៦:០៨:០៣]

បទដ្ឋានដែលយើងប្រើប្រាស់ គឺថាយើងប្រើប្រាស់ដូចបទដ្ឋានដែលព្រះរាជអាជ្ញាបានប្រើប្រាស់ដែរ គឺថាជាបទដ្ឋានដែលបង្ហាញអំពីតម្លៃនៃភស្តុតាង។ គ្រាន់តែឥឡូវនេះ យើងយកមកប្រើប្រាស់នៅក្នុងលក្ខណៈមួយផ្សេងពីមុន គឺថាជាប្រើប្រាស់ជាលក្ខណៈជាអ៊ីម៉ែលទៅវិញ។

ដូច្នេះ ចង់ដឹងថាតើឯកសារហ្នឹង វាមិនច្បាស់លាស់ ឬក៏វាបានមកពីណា? ឬក៏ដោយសារអ្វីនោះ គឺថា ថាតើសាក្សី ឬក៏អ្នកជំនាញហ្នឹង គាត់ដឹងអ្វី? ឬក៏គាត់មិនដឹងអ្វី? គាត់អាចសន្និដ្ឋានអ្វី? ឬក៏ធ្វើអ្វីខ្លះ? ទាំងអស់គឺថានៅពេលដែលយើងទទួលស្គាល់នូវបទដ្ឋានហ្នឹងទៅ គឺយើងអាចដឹងទាំងអស់គ្នាហើយ។

អ្វីដែលយើងខ្ញុំចង់លើកជាសំខាន់ គឺថាយើងដឹងច្បាស់ហើយថា លោក រ៉ប់ លឹមគិន បានមកជួបជាមួយយើងខ្ញុំ គឺថាគាត់ទាក់ទងមកខ្ញុំដោយផ្ញើអ៊ីម៉ែល។ ហើយគាត់មិនមានបញ្ហាអ្វីនោះទេក្នុងការបង្ហាញក៏ដូចជាក្នុងការផ្ដល់នូវព័ត៌មានទាំងអស់នេះ។ ដូច្នេះអានេះគឺជាអ្វីដែលខ្ញុំយល់តាមអ៊ីម៉ែលរបស់គាត់។

[១៦:០៩:១៧]

ដូច្នេះ មិនដូចទៅនឹងអ្វីដែលថាគាត់មិនសហការផ្ដល់ព័ត៌មានទៅឲ្យសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែគាត់សហការជាមួយខាង នួន ជា វិញ។ ហើយសហការផ្ដល់នូវខ្សែវីដេអូ ប្រសិនបើអង្គជំនុំជម្រះចង់បាន។ ដូច្នេះ ឥឡូវនេះយើងមានស្ថានភាពផ្សេងមួយទៀត ដោយសារគាត់មានព័ត៌មានមួយដែលថាជាភស្តុតាងដោះបន្ទុកសម្រាប់ នួន ជា។ ហើយប្រសិនបើលោក នួន ជា មិនមានបញ្ហា គឺថា

លោក លឹមគិន ហើយនិងសហផលិតកររបស់លោកអាចផ្តល់នូវភស្តុតាងទាំងអស់នេះបាន។ ហេតុដូច្នេះហើយ វាមិនមានមូលហេតុអ្វី ឬក៏មិនមានបញ្ហាអ្វីដែលថា មិនឲ្យ រ៉ប់ លឹមគិន ហ្នឹងផ្តល់នូវខ្សែវីដេអូទាំងអស់នោះមកទេ។ គឺអានេះគឺវាខុសពីអ្វីដែលកើតឡើងនៅឆ្នាំ២០១១ ដែលសហផលិតករទាំងពីររូបគាត់បដិសេធមិនផ្តល់ឲ្យ ប៉ុន្តែឥឡូវនេះគាត់ឯកភាព។ គឺថាយើងស្ថានភាពវាប្រែប្រួលដូចបាតដៃខ្នងដៃហើយឥឡូវនេះ គឺគាត់សហការផ្តល់មកឲ្យយើងវិញ។

ហើយប្រសិនបើកូនក្តីរបស់ខ្ញុំឆ្លើយថា មិនមានបញ្ហាអ្វីទេ មិនមានការជំទាស់អ្វីទេ។ ដូច្នេះ ខ្សែវីដេអូទាំងអស់ហ្នឹង គឺថាអាចប្រគល់ទៅអង្គជំនុំជម្រះបាន។ ដូច្នេះ វិធីសាស្ត្រដ៏ងាយស្រួលគឺថាគ្រាន់តែអង្គជំនុំជម្រះសួរទៅលោក លឹមគិន ថាតើលោក លឹមគិន គាត់យល់ព្រមផ្តល់ខ្សែវីដេអូទាំងអស់នេះទៅអង្គជំនុំជម្រះឬក៏អត់?

[១៦:១០:៤៣]

ខ្ញុំគិតថាសវនាការរបស់យើងជិតដល់ទីបញ្ចប់ហើយទៅហើយ ហើយឥឡូវនេះយើងដឹងថាវាមានករណីមួយ គឺថានៅពេលចុងក្រោយនេះ គឺវាមានការចង្អុលបង្ហាញអំពីវត្តមានដ៏សំខាន់នៃភស្តុតាងដោះបន្ទុក។ ហេតុដូច្នេះហើយ ទោះបីថាយើងនៅដំណាក់កាលចុងក្រោយនៃសវនាការក៏ដោយ ប៉ុន្តែមិនមែនបានន័យថាយើងមិនត្រូវយកចិត្តទុកដាក់ទៅលើបញ្ហានេះនោះទេ។

ខ្ញុំគិតថាវាជាករណីកម្រនៅក្នុងករណីបែបនេះហើយ ដែលថាសហផលិតករ គឺលោក រ៉ប់ លឹមគិន គាត់សហការ គាត់ស្ម័គ្រចិត្តផ្តល់ខ្សែវីដេអូទៅឲ្យអង្គជំនុំជម្រះ។ ដូច្នេះ វាជារឿងមួយដែលវាកម្រ។ ខ្ញុំមិនមែនចង់ជម្រាបជាការព្រួលអង្គជំនុំជម្រះទេ ខ្ញុំចង់ជម្រាបទៅដល់ព្រះរាជអាជ្ញាថា អង្គជំនុំជម្រះ ក៏ដូចជាសវនាការទាំងអស់នេះ គឺយើងព្យាយាមស្វែងរកការពិត ហើយយើងកំពុងតែរកការពិត។ ហើយឥឡូវនេះ យើងជួបមនុស្សម្នាក់ដែលគាត់បញ្ជាក់ហើយថា គាត់មានខ្សែវីដេអូរាប់សិបម៉ោង រាប់រយម៉ោង ជាសម្ភារៈ ជាឯកសារដ៏សំខាន់ដែលពាក់ព័ន្ធបំផុតទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះចង់ជំនុំជម្រះ។

ហើយខ្សែវីដេអូហ្នឹងគឺវាពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ។ ហើយព្រះរាជអាជ្ញាចង់ស្នើសុំឲ្យទទួលស្គាល់ជាទួលពោធិ៍ជ្រៃជាទីតាំងឧក្រិដ្ឋ។ ដូច្នេះហើយខ្សែវីដេអូនេះពិតជាសំខាន់មែនទែន។ ហើយខាងព្រះរាជអាជ្ញាជាម្តងហើយម្តងទៀតៗបានបង្ហាញនូវខ្សែវីដេអូទាក់ទងនឹងទួលពោធិ៍ជ្រៃដដែលៗ។ ដូច្នេះហើយខ្ញុំគិតថា គ្រាន់ថាវាជារឿងមួយផ្សេងដែលថាការពីមុនវាអ៊ីចេះ ឥឡូវវាផ្សេងអ៊ីចេះមកវិញ។

[១៦:១២:៣៤]

ដូច្នេះ អង្គជំនុំជម្រះគួរតែធ្វើយ៉ាងណាបង្ហាញឲ្យឃើញថា ខ្សែវីដេអូទាំងអស់ហ្នឹងគឺៗវាអាចនឹងយកមកប្រើប្រាស់ដោយបានជាប្រយោជន៍ដល់គ្រប់ភាគីទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កូប៉េ លោកបានបញ្ជាក់រួចហើយថាផលិតកររូបនេះគាត់ផ្តល់សហការផ្តល់មកអង្គជំនុំជម្រះ ឬមួយក៏គ្រាន់តែជាការគិតរបស់លោក? ព្រោះថាតាមដែលអ៊ីម៉ែលគឺវាហាក់ដូចជាផ្ទុយទៅនឹងអ្វីដែលបានកើតឡើង។ ព្រោះថាចៅក្រមស៊ើបអង្កេតស្នើសុំ តែគាត់មិនឲ្យ។ ដូច្នេះតើឥឡូវលោកអាចបញ្ជាក់បានច្បាស់ទេ ថាតើបញ្ហានេះយ៉ាងម៉េចដែរ?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំយល់ទៅតាមអ៊ីម៉ែលរបស់គាត់។ គាត់ដឹងយើងជាមេធាវីការពារក្តី នួន ជា ហើយគាត់ធ្វើការតាមដានកិច្ចដំណើរការនីតិវិធីនេះ ហើយគាត់ដឹងថាខ្សែភាពយន្តរបស់គាត់ គឺជាប្រធានបទសំខាន់នៃការពិភាក្សាដេញដោល។ ដូច្នេះ តាមដែលខ្ញុំដឹង តាមរយៈការជជែកជាមួយកូនក្តីរបស់ខ្ញុំផង គឺថាវាមានការព្រមព្រៀងរវាងកូនក្តីខ្ញុំ ជាមួយសហផលិតករ ដែលថាមិនអនុញ្ញាតឲ្យផ្តល់ឯកសារទាំងអស់នេះមកអង្គជំនុំជម្រះ។ គឺជាកិច្ចព្រមព្រៀងមួយដែលគាត់ធ្វើតាំងពីមុនឆ្នាំ២០០៧មកម្ល៉េះ។

[១៦:១៤:១៥]

ដូច្នេះហើយគឺថាយើងអាចនិយាយបានថា មិនមែនថាគាត់រំលោភទៅលើកិច្ចព្រមព្រៀងអីទេ ប៉ុន្តែឥឡូវនេះគឺយើងនិយាយអំពីសំអាងហេតុ និងនិយាយអំពីមូលហេតុវិញ ប្រសិនបើកូនក្តីខ្ញុំនិយាយថាគាត់មិនមានបញ្ហាអ្វីទេ ដើម្បីឲ្យសហផលិតករផ្តល់ខ្សែភាពយន្តទៅអង្គជំនុំជម្រះ។ ដូច្នេះ ខ្ញុំអាចបកស្រាយថា ផ្អែកតាមអ៊ីម៉ែល ក៏ដូចជាអ្វីដែលកូនក្តីខ្ញុំបាននិយាយ គឺថាផលិតករគាត់មានចេតនាផ្តល់ខ្សែវីដេអូហ្នឹងទៅដល់អង្គជំនុំជម្រះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ចុះអំពីក្រមសីលធម៌អ្នកសារព័ត៌មានដែលគាត់តែងតែនិយាយដដែលៗហ្នឹង។ តើលោក កូប៉េ ឆ្លើយយ៉ាងម៉េចដែរ?

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំយល់អំពីបញ្ហានេះ ហើយយើងគោរពទៅលើក្រមសីលធម៌របស់អ្នកសារព័ត៌មាន។ គឺថាអ្នកសារព័ត៌មានត្រូវការពារប្រភពព័ត៌មានរបស់គាត់។ ប្រសិនបើសួរថាតើប្រភពសារព័ត៌មានលោកជាអ្នកណា អ្នកណាជាអ្នកផ្តល់ព័ត៌មានរបស់គាត់ អាហ្នឹងគឺជាមួយខុស វាខុសទៅនឹងមាត្រា១០នៃអនុសញ្ញាស្តីពីការការពារប្រភពព័ត៌មាន ក៏ដូចជាសេរីភាពក្នុងការបញ្ចេញមតិផងដែរ។ ប៉ុន្តែក្នុងពេលឥឡូវនេះប្រភពព័ត៌មានគាត់និយាយហើយ ថាគាត់អត់មានបញ្ហាទេ ផ្តល់ព័ត៌មានបាន។ ហេតុដូច្នេះហើយគឺថាតាមខ្ញុំយល់ គឺថាអ្នកសារព័ត៌មានខ្លួនគាត់ផ្ទាល់ គឺអត់មានជាការរំលោភបំពានទៅលើសេរីភាព ក៏ដូចជាក្រមសីលធម៌ការពារព័ត៌មានអ្វីនោះទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឬមួយក៏ជាការគិតរបស់លោក លោក កូប៉េ? ចុះអំពីប្រធានបទដទៃទៀត ថាតើអ្នកដទៃទៀតអ្នកនៅក្នុងខ្សែភាពយន្តដទៃទៀត ក្រៅពីកូនក្តីរបស់លោក តើពួកគាត់ហ្នឹងលះបង់សិទ្ធិ ឬមួយការយល់ដូចម្តេចដែរ ឬមួយក៏លោកគ្រាន់តែសន្និដ្ឋាន?

[១៦:១៦:០៥]

**លោក វ៉ិចទ័រ កូប៉េះ**

អាហ្នឹងគឺអាស្រ័យទៅលើពួកគាត់ និងអាស្រ័យទៅលើលោក រ៉ប់ លឹមគិន ផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់របស់ភាគី គឺមានសារណាការពារនូវសំណើសុំរបស់ខ្លួន ហើយសារណាគាំទ្រនូវសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ហើយនិងសារណាជំទាស់តបរបស់ក្រុមសហតំណាងសហព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយបន្ទាប់ពីការស្តាប់នូវសារណារបស់ភាគីពាក់ព័ន្ធនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា គឺលើឯកសារ E294 ហើយនិងសំណើសុំបន្ថែម ហើយនាពេលនេះគឺអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណា ហើយនិងសម្រេចនៅក្នុងពេលវេលាឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅពេលខ្លីខាងមុខនេះ។

[១៦:១៧:១០]

បាទ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះ

ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៦ ខែកក្កដា ឆ្នាំ២០១៣។ ហើយនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឌ័រ ដែលនិងសួរដេញដោលក្រុមមេធាវីការពារក្ដី។ ហើយសូមភាគីនៃរឿងក្ដី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និង លោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៨ នាទី)*